# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រម

២២-១២-២០០៦ -ព្រះរាជក្រម នស/រកម/១២០៦/០៣២ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាទីក្រុងវីយែនស្តីពីកិច្ចការពារស្រទាប់អូហ្សូន ១៦៩

២២-១២-២០០៦ -ព្រះរាជក្រម នស/រកម/១២០៦/០៣៣ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមលើពិធីសារក្យូតូនៃអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ ២២២

### ២-ព្រះរាជក្រឹត្យ

២៦-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៥០៩ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០៣ រូប ២៦៩

២៦-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៥១០ ស្តីពីការធ្វើសមាហរណកម្ម ទៅក្នុងឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេសនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់របស់ក្រសួងសុខាភិបាល ចំនួន ០២ រូប ២៧០

២៦-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៥១១ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **ចាំង យ៉េនហ្វាន** (JANG YENFAN) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តជុងសាន ប្រទេសចិន ២៧១

២៦-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៥១២ ស្តីពីការប្រោសព្រះរាជទានចំពោះ ឯកឧត្តម **ណវ ម៉ារឌី** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ២៧២

២៦-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៥១៣ ស្តីពីការតែងតាំងឯកឧត្តម **គីម វឌ្ឍនា** ជាអគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានឋានៈស្មើរដ្ឋលេខាធិការ ២៧៣

២៧-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៥១៥ ស្តីពីការតែងតាំងឯកឧត្តម **ជួម សុគន្ធី** ជាអនុរដ្ឋលេខាធិការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន ២៧៤

២៧-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៥១៦ ស្តីពីការប្រោសព្រះរាជទានចំពោះColonel Andrie T U Sutarno.MDS នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ២៧៥

២៧-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៥១៧ ស្តីពីការប្រោសព្រះរាជទានចំពោះ ឯកឧត្តម **គោស៊ី សារៀត** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ២៧៦

២៧-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៥១៨ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំនួន ១០ រូប ២៧៧

៣០-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៥២១ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់មហាសេនា ជូនលោកជំទាវជាសប្បុរសជន ចំនួន ០៣ រូប ២៧៨

៣០-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៥២២ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជាកិច្ចបច្ឆាមរណៈ ជូនចំពោះសពលោកវរសេនីយ៍ឯក **ឡាវ៉ៃ ម៉ិនថា** នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ២៧៩

៣០-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៥២៣ ស្តីពីការតែងតាំង ឯកឧត្តម **ស៊ីន សុខណា** ជាទីប្រឹក្សាឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើ រដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បៀវត្ស ២៨០

៣០-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៥២៤ ស្តីពីការតែងតាំង និងតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិជាន់ខ្ពស់ ២៨១

៣០-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៥២៦ ស្តីពីការតែងតាំង ឯកឧត្តម **ម៉ម ម៉ិននាង** ជាទីប្រឹក្សាអមរាជរដ្ឋាភិបាលមានឋានៈស្មើ រដ្ឋមន្ត្រី ២៨៣

៣០-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៥២៧ ស្តីពីការតម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ជូនចំពោះសពនាយទាហានជាន់ខ្ពស់ ចំនួន ០៥ រូប ២៨៤

៣០-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៥២៥ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ជូននាយទាហានចំនួន ១៨ រូប ២៨៥

៣០-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៥៣២ ស្តីពីការកំណត់ជាក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិវរៈមន្ត្រី ,អនុមន្ត្រី និងមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នូវមន្ត្រីរាជការស៊ីវិលរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ២៨៧


## II~ក្រុមប្រឹក្សាធម្មនុញ្ញ


០៥-០១-២០០៧ -សេចក្តីសម្រេចលេខ ០៩០/០០១/២០០៧ កបធ.ច ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៧ ៣០៣

០៥-០១-២០០៧ -សេចក្តីសម្រេចលេខ ០៩១/០០២/២០០៧ កបធ.ច ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៧ ៣០៥

## III~រាជរដ្ឋាភិបាល

### អនុក្រឹត្យ


០៣-០១-២០០៧ -អនុក្រឹត្យលេខ ១១ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣០៨

០៣-០១-២០០៧ -អនុក្រឹត្យលេខ ១២ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣០៩

០៣-០១-២០០៧ -អនុក្រឹត្យលេខ ១៣ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣១១

០៣-០១-២០០៧ -អនុក្រឹត្យលេខ ១៤ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣១២

០៣-០១-២០០៧ -អនុក្រឹត្យលេខ ១៥ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣១៣

០៣-០១-២០០៧ -អនុក្រឹត្យលេខ ១៦ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣១៤

០៣-០១-២០០៧ -អនុក្រឹត្យលេខ ១៧ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣១៥

០៤-០១-២០០៧ -អនុក្រឹត្យលេខ ១៨ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣១៦

០៤-០១-២០០៧ -អនុក្រឹត្យលេខ ១៩ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣១៧

០៤-០១-២០០៧ -អនុក្រឹត្យលេខ ២០ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ៣១៨

០៤-០១-២០០៧ -អនុក្រឹត្យលេខ ២១ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ៣១៩

០៤-០១-២០០៧ -អនុក្រឹត្យលេខ ២២ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីសង្ឃ និងមន្ត្រីរាជការ ៣២០

០៥-០១-២០០៧ -អនុក្រឹត្យលេខ ២៣ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣២២

០៥-០១-២០០៧ -អនុក្រឹត្យលេខ ២៤ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣២៣

០៥-០១-២០០៧ -អនុក្រឹត្យលេខ ២៥ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣២៤

០៥-០១-២០០៧ -អនុក្រឹត្យលេខ ២៦ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣២៥


## IV~ការងារបណ្ដាក្រសួង

### ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


១២-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៣៦៦ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **កសិដ្ឋាន កែវ សម្បត្តិ ឧត្តរ** ៣២៧

១៣-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៣៦៧ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អូ អិម អូ អេនើជី (ខេមបូឌា) ខូ អិលធីឌី** ៣២៩

១៣-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៣៧១ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខា ទណ្ណះឯល សំអឿន (ខេមបូឌា) ម៊ីត** ៣៣១

១៥-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៣៩១ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជេ អេស អិម អេមប៊ីស៊ី សេនធ័រ ខូ អិលធីឌី** ៣៣៣

១៥-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤០៣ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឃើម គ្លូបិល** ៣៣៤

# ព្រះរាជក្រម

នស/រកម/១២០៦/០៣២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាទីក្រុងវីយ៉ែនស្តីពីកិច្ចការពារស្រទាប់អូហ្សូន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ តុលា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

13

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញាទីក្រុងវីយែនស្តីពីកិច្ចការពារស្រទាប់អូហ្សូន

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាទីក្រុងវីយែនស្តីពីកិច្ចការពារស្រទាប់អូហ្សូន ដែលធ្វើនៅទីក្រុងវីយែន ប្រទេសអូទ្រីស នាថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៨៥ ហើយដែលមានអត្ថបទទាំងស្រុង ភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

រាជធានីភ្នំពេញថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់

៣ល. ០៦១២.៥៣៧

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

លេខៈ ៤៨៥ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០០៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ជិនកេន**

1/3

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧១ ឧទឯ.សបច

# សេចក្តីថ្លែងហេតុ

# នៃសេចក្តីព្រាងច្បាប់

# ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាទីក្រុងវីយែន

# ស្តីពីកិច្ចការពារស្រទាប់អូហ្សូន

ស្រទាប់អូហ្សូនត្រូវបានគេរកឃើញស្ថិតនៅចន្លោះបរិយាកាសរវាង ១០ទៅ១៥ គីឡូម៉ែត្រពីផែនដីដែលវាមានសារប្រយោជន៍សំខាន់ណាស់ក្នុងការការពារខ្លួនយើងពីការប៉ះពាល់ដោយកាំរស្មីពណ៌ស្វាយ (UV) នៃពន្លឺព្រះអាទិត្យ ។ ការធ្លុះធ្លាយស្រទាប់អូហ្សូននឹងធ្វើឱ្យមានការកើនឡើងកាំរស្មីពណ៌ស្វាយមកលើផែនដីយើងដែលនឹងធ្វើឱ្យប៉ះពាល់មកលើស្បែក និងប្រព័ន្ធការពាររាងកាយរបស់យើងព្រមទាំងមានឥទ្ធិពលអាក្រក់ដល់ភ្នែក រុក្ខជាតិ សត្វ និងវត្ថុធាតុប្លាស្ទិកទាំងឡាយ ។

នៅក្នុងអំឡុងប៉ុន្មានឆ្នាំចុងក្រោយនេះ ការធ្លុះធ្លាយនូវស្រទាប់អូហ្សូន បានធ្វើឱ្យពិភពលោក មានការចាប់អារម្មណ៍ និងព្រួយបារម្ភខ្លាំង។ មូលហេតុចម្បងនៃការធ្លុះធ្លាយនោះ គឺត្រូវបានគេរកឃើញថា បណ្តាលមកពីការបំផ្លាញ ដោយសារសារធាតុក្លរ៉ូ-ភ្លុយអរ៉ូកាបូន Chlorofluorocarbons (CFCs) ។ សារធាតុនេះត្រូវបាន គេរកឃើញ និងប្រើប្រាស់នៅឆ្នាំ១៩២៨ ជាសារធាតុដែលធ្វើឱ្យត្រជាក់ក្នុងម៉ាស៊ីនត្រជាក់ ជាសារធាតុរំលាយ ជាសារធាតុពន្លត់អគ្គិភ័យ។ល។ សារធាតុក្លរ៉ូ-ភ្លុយអរ៉ូកាបូន អាចមានអាយុកាលដ៏វែង ហើយងាយនឹងសាយភាយ ក្នុងរយៈចម្ងាយដ៏ឆ្ងាយឆ្ពោះទៅរកស្រទាប់អូហ្សូននៃបរិយាកាសដែលនៅទីនោះសារធាតុក្លរ៉ូ-ភ្លុយអរ៉ូកាបូន បានធ្វើប្រតិកម្មបំផ្លាញស្រទាប់អូហ្សូន។ ការបាត់បង់ស្រទាប់អូហ្សូន ត្រូវបានគេរកឃើញនៅតំបន់អង់តាក់ទិកនាឆ្នាំ១៩៨៥ ដែលតាំងពីនោះមក ការបាត់បង់នេះ ត្រូវបានគេរកឃើញនៅក្នុងរយៈកម្ពស់មធ្យម និងរយៈកម្ពស់ខ្ពស់នៃស្រទាប់បរិយាកាស ។

បច្ចុប្បន្ននេះ ស្រទាប់អូហ្សូននៃបរិយាកាសកំពុងតែមាននិន្នាការផ្លាស់ប្តូរទៅរកការអន្តរាយយ៉ាងធ្ងន់ធ្ងរដោយសារតែសកម្មភាពរបស់មនុស្សបង្កឡើង ។ ការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញថា ផលវិបាកដ៏ធំបំផុត ដែលកើតចេញពីការបំផ្លាញស្រទាប់អូហ្សូន គឺភាពមិនប្រក្រតីនៃការប្រែប្រួលអាកាសធាតុលើភពផែនដី ដែលវាជះឥទ្ធិពលជាអវិជ្ជមានយ៉ាងធ្ងន់ធ្ងរទៅលើសុខភាពមនុស្ស ហើយបានបង្កឱ្យមានការខូចខាតយ៉ាងខ្លាំងដល់ផលិតភាពរបស់ប្រព័ន្ធធម្មជាតិ ប្រព័ន្ធសង្គម ព្រមទាំងកត្តារូបវ័ន្តផ្សេងៗទៀតដែលបម្រើជាប្រយោជន៍សម្រាប់មនុស្សជាតិ ។ និន្នាការនេះកំពុងត្រូវបានតាមដាន និងត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ ពីសំណាក់អ្នកឯកទេសវិទ្យាសាស្ត្រផ្នែកបរិស្ថានពិភពលោក ដើម្បីដាក់ចេញនូវវិធានការជាបន្ទាន់នានា ក្នុងទិសដៅកាត់បន្ថយ និងឈានទៅបំបាត់ចោលការប្រើប្រាស់សារធាតុ ដែលបំផ្លាញស្រទាប់អូហ្សូននៅក្នុងពេលអនាគត ។

ដោយពិនិត្យឃើញនូវផលលំបាកនៃការបាត់បង់នូវស្រទាប់អូហ្សូនដោយសកម្មភាពរបស់មនុស្ស អង្គការកម្មវិធីបរិស្ថាន សហប្រជាជាតិបានផ្តួចផ្តើមរៀបចំសេចក្តីព្រាងអនុសញ្ញាការពារស្រទាប់អូហ្សូននាឆ្នាំ១៩៧៧ហើយដែលត្រូវបានបណ្តាប្រទេសនៅលើពិភពលោកបានចូលរួមពិភាក្សា និងអនុម័តលើសេចក្តីព្រាងនោះនៅទីក្រុងវីយែនឆ្នាំ១៩៨៥។ តាមរយៈអនុសញ្ញាវីយែនស្តីពីការការពារស្រទាប់អូហ្សូន បានសហការជួយគ្នាទៅវិញទៅមកក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដើម្បីពង្រីកការយល់ដឹងពីដំណើរការវិវត្តរបស់បរិយាកាស ។

ដើម្បីជំរុញកាត់បន្ថយសារធាតុបំផ្លាញស្រទាប់អូហ្សូន និងការអនុវត្តអនុសញ្ញាវីយែនឱ្យមានប្រសិទ្ធភាព នៅឆ្នាំ១៩៨៧ អង្គការកម្មវិធីបរិស្ថានសហប្រជាជាតិ និងប្រតិភូមកពីប្រទេសជាច្រើនលើពិភពលោក បានមកជួបប្រជុំគ្នានៅទីក្រុងម៉ុងរ៉េអាល់ ដើម្បីអនុម័តពិធីសារម៉ុងរ៉េអាល់ ស្តីពីសារធាតុដែលបំផ្លាញស្រទាប់អូហ្សូន។ ដើម្បីជំរុញការអនុវត្តក្នុងការកាត់បន្ថយការសាយភាយសារធាតុបំផ្លាញស្រទាប់អូហ្សូន ពិធីសារម៉ុងរ៉េអាល់ត្រូវបានធ្វើវិសោធនកម្មចំនួន ៤លើក ជាបន្តបន្ទាប់រួមមាន :

-វិសោធនកម្មនៅទីក្រុងឡុង ឆ្នាំ ១៩៩០
-វិសោធនកម្មនៅទីក្រុងកូប៉េនហាហ្គេន ឆ្នាំ ១៩៩២
-វិសោធនកម្មនៅទីក្រុងម៉ុងរ៉េអាល់ ឆ្នាំ ១៩៩៧
-និងវិសោធនកម្មនៅទីក្រុងប៉េកាំង ឆ្នាំ ១៩៩៩ ។

ដោយពិនិត្យឃើញថា កិច្ចការពារស្រទាប់អូហ្សូន ជាកាតព្វកិច្ចរួមដ៏ចាំបាច់របស់ប្រជាពលរដ្ឋទូទាំងពិភពលោក និងដោយឈរលើទស្សនៈថា "**ការការពារស្រទាប់អូហ្សូន គឺជាការការពារអាយុជីវិតមនុស្ស និងបរិស្ថាន**"

មកដល់ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០០២នេះ មានប្រទេសចំនួន ១៨៤ បានផ្តល់សច្ចាប័នលើអនុសញ្ញាវីយែន និងប្រទេសចំនួន ១៨៣ បានផ្តល់សច្ចាប័នលើពិធីសារម៉ុងរ៉េអាល់រួចហើយ ដែលក្នុងនោះរាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាសុំចូលជាសមាជិកនៃអនុសញ្ញាវីយែនស្តីពីកិច្ចការពារស្រទាប់អូហ្សូន និងពិធីសារម៉ុងរ៉េអាល់ ស្តីពីសារធាតុដែលបំផ្លាញស្រទាប់អូហ្សូនកាលពីថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០១ ។ ប៉ុន្តែកម្ពុជាមិនទាន់បានចុះហត្ថលេខាផ្តល់សច្ចាប័នលើវិសោធនកម្មណាមួយក្នុងចំណោមវិសោធនកម្មទាំង ៤ ខាងលើនៅឡើយទេ ។

យោងទៅលើការសិក្សាឯកសារ និងបទពិសោធន៍ពីប្រទេសនានានៅក្នុងតំបន់ ក្នុងការផ្តល់សច្ចាប័នលើអនុសញ្ញាវីយែន ស្តីពីកិច្ចការពារស្រទាប់អូហ្សូន និងពិធីសារម៉ុងរ៉េអាល់ ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន កម្ពុជានឹងទទួលបានសារប្រយោជន៍ដូចខាងក្រោមនេះ :

១-ក្នុងនាមជាសមាជិកនៃអនុសញ្ញា និងពិធីសារនេះប្រទេសកម្ពុជានឹងពុំត្រូវបង់ថវិកា ឬចំណាយណាមួយឡើយ ។

២-ក្នុងនាមជាសមាជិកនៃអនុសញ្ញា និងពិធីសារនេះ ប្រទេសកម្ពុជាមានកាតព្វកិច្ចចូលរួមជាមួយសហគមអន្តរជាតិ ក្នុងការទប់ស្កាត់នូវការរេចរឹលនៃស្រទាប់អូហ្សូន ដែលបង្កដោយសារធាតុបំផ្លាញ ស្រទាប់អូហ្សូនដោយកាត់បន្ថយ និងលប់បំបាត់សារធាតុដែលបំផ្លាញស្រទាប់អូហ្សូន តាមរយៈការទប់ស្កាត់ និងកាត់បន្ថយការនាំចូល ការប្រើប្រាស់ ការកែច្នៃ និងការផលិតសារធាតុបំផ្លាញស្រទាប់អូហ្សូន និងឧបករណ៍ ឬគ្រឿងបរិក្ខាដែលប្រើប្រាស់សារធាតុទាំងនេះ ហើយដែលឧបករណ៍ទាំងនោះ ភាគច្រើនកំពុងត្រូវបានគេស្វះស្វែងរកកន្លែងបោះចោល ពីព្រោះឧបករណ៍ទាំងនោះនឹងត្រូវបញ្ឈប់ឱ្យប្រើប្រាស់តទៅទៀតបន្ទាប់ពីឆ្នាំ២០១០ ខាងមុខនេះ។

៣-ទទួលផលចំណេញផ្នែកនយោបាយ :

-បង្ហាញពីទស្សនៈ ឆន្ទៈរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងការរួមចំណែកដោះស្រាយបញ្ហាបរិស្ថានជាមួយសហគមន៍អន្តរជាតិ ។

-លើកកម្ពស់កិត្យានុភាពជាតិ តាមរយៈការចូលរួមប្រជុំ ដែលរៀបចំឡើងសម្រាប់ពិភាក្សាដោះស្រាយបញ្ហាកាត់បន្ថយសារធាតុដែលបំផ្លាញស្រទាប់អូហ្សូន ។

៤-ទទួលផលចំណេញផ្នែកបរិស្ថាន :

-ក្នុងនាមជាសមាជិកនៃអនុសញ្ញា និងពិធីសារនេះ ប្រទេសកម្ពុជានឹងទទួលបាននូវការកាត់បន្ថយនូវឥទ្ធិពលនៃការកើនកម្តៅដែលធ្វើឱ្យខូចបរិស្ថានធម្មជាតិ និងការប៉ះពាល់លើសុខភាពសាធារណៈដោយសារការ

ធុះផ្លាយស្រទាប់អូហ្សូន ។

-ទទួលបាននូវការគាំទ្រលើជំនួយបច្ចេកទេស ក្នុងការបណ្តុះបណ្តាលការផ្តល់នូវបច្ចេកវិទ្យា និងការទទួលព័ត៌មាន និងជំនួយជាថវិកាសម្រាប់អនុវត្តគម្រោង ដែលទាក់ទងនឹងការអនុវត្តអនុសញ្ញា និងពិធីសារនេះ ដូចជាការកែច្នៃ ការត្រួតពិនិត្យការនាំចូលនូវឧបករណ៍ និងសារធាតុបំផ្លាញស្រទាប់អូហ្សូនប្រកបដោយសុវត្ថិភាព ដែលបច្ចុប្បន្ននេះ យើងទទួលបានជំនួយផ្នែកពង្រឹងសមត្ថភាព និងការរៀបចំធ្វើកម្មវិធីជាតិ ដើម្បីកាត់បន្ថយ និងលុបបំបាត់សារធាតុដែលបំផ្លាញស្រទាប់អូហ្សូន ។

៥-ផលចំណេញផ្នែកសេដ្ឋកិច្ច :

-ដោយសារកម្ពុជាយើងមិនមែនជាប្រទេសអ្នកផលិត ឬអ្នកនាំចេញឧបករណ៍ និងសារធាតុបំផ្លាញស្រទាប់អូហ្សូន ដូច្នេះការចូលជាសមាជិកវានឹងមិនបង្កផលប៉ះពាល់ជាអវិជ្ជមានដល់កម្ពុជាយើងទេ

-អាចចូលរួមក្នុងការអនុវត្តគម្រោងផ្នែកការប្រើប្រាស់ឡើងវិញ ការកែច្នៃសារធាតុដែលបំផ្លាញស្រទាប់អូហ្សូន ដែលថវិកាទាំងនេះនឹងទទួលបានពីថវិកាពហុភាគី

-អាចទទួលបានថវិកាក្នុងការរៀបចំប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណ ក្នុងការត្រួតពិនិត្យការនាំចេញ នាំចូលដោយប្រើប្រព័ន្ធព័ត៌មានវិទ្យាទំនើប ដែលអាចទប់ស្កាត់ចរាចរទំនិញខុសច្បាប់បានដោយមានប្រសិទ្ធភាព។

ពិនិត្យជារួម ការចូលជាសមាជិកនៃអនុសញ្ញាវីយ៉ែន និងពិធីសារម៉ុងរ៉េអាល់ នឹងពុំនាំមកនូវផលវិបាកជាអវិជ្ជមានណាមួយដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមរបស់កម្ពុជាឡើយ ។ ផ្ទុយទៅវិញវា គឺជាឱកាសដ៏ល្អមួយដែលអនុញ្ញាតឱ្យកម្ពុជាទទួលបាននូវផលចំណេញលើគ្រប់វិស័យ ដូចបានរៀបរាប់ខាងលើ ដែលជាចុំណុចយ៉ាងសំខាន់សម្រាប់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តកម្មវិធីកាត់បន្ថយភាពក្រីក្រ ការពារបរិស្ថាន និងធនធានធម្មជាតិ ឆ្ពោះទៅសម្រេចបាននូវការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព ។

អាស្រ័យសេចក្តីដូចបានទូលថ្វាយ និងជម្រាបជូនខាងលើ សូមរដ្ឋសភាមេត្តាពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាទីក្រុងវីយ៉ែន ស្តីពីកិច្ចការពារស្រទាប់អូហ្សូននេះ ដោយអនុគ្រោះ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ (ធ្នូ?) ឆ្នាំ២០០៥

ហ៊ុន សែន

# អនុសញ្ញាទីក្រុងវីយែន ស្តីពីកិច្ចការពារស្រទាប់អូសូន ១៩៨៥

(Vienna Convention for the Protection of the Ozone Layer (1985)

ចូលជាធរមានថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩៨៨

## បុព្វកថា

ភាគីទាំងអស់នៃអនុសញ្ញានេះ :

ដោយយល់ដឹងច្បាស់ពីឥទ្ធិពលប្រកបដោយគ្រោះថ្នាក់ ដែលអាចមានទៅលើសុខភាពមនុស្ស និងបរិស្ថាន បណ្តាលមកពីការកែប្រែស្រទាប់អូសូន ។

ដោយរំលឹកឃើញពីខពាក់ព័ន្ធ ដែលមាននៅក្នុងសេចក្តីប្រកាសរបស់សន្និសិទសហប្រជាជាតិ ស្តីពីបរិស្ថានមនុស្ស ដែលចែងថា "អនុលោមទៅតាមធម្មនុញ្ញរបស់សហប្រជាជាតិ និងគោលការណ៍នានានៃច្បាប់អន្តរជាតិ ប្រទេសទាំងអស់មានសិទ្ធិមិនអាចប៉ះពាល់បាន ក្នុងការធ្វើអាជីវកម្មលើធនធានរបស់ខ្លួន យោងទៅតាមគោលនយោបាយបរិស្ថានរបស់ខ្លួនផ្ទាល់ និងការទទួលខុសត្រូវ ដើម្បីធានាថា សកម្មភាពនានាដែលស្ថិតនៅក្រោមសិទ្ធិអំណាច ឬការត្រួតត្រារបស់ខ្លួននឹងមិនបណ្តាលឱ្យមានការខូចខាតដល់បរិស្ថានរបស់ប្រទេសផ្សេងទៀត ឬដល់តំបន់ដែលស្ថិតនៅក្រៅសិទ្ធិអំណាចត្រួតត្រារបស់ខ្លួន ។

ដោយគិតគូរពិចារណាដល់លក្ខខណ្ឌ និងការទាមទាររបស់ប្រទេសកំពុងអភិវឌ្ឍន៍ ។

ដោយយកចិត្តទុកដាក់ដល់កិច្ចការ និងការសិក្សានានា ដែលធ្វើឡើងនៅក្នុងអង្គការជាតិ និងអន្តរជាតិ ជាពិសេសគឺផែនការសកម្មភាពពិភពលោក ស្តីពីស្រទាប់អូសូនរបស់កម្មវិធីបរិស្ថានសហប្រជាជាតិ ។

ដោយយកចិត្តទុកដាក់ដល់វិធានការការពារទុកជាមុន ក្នុងកិច្ចការពារស្រទាប់អូសូន ដែលត្រូវបានចាត់រួចហើយទាំងនៅថ្នាក់ជាតិ ក៏ដូចជានៅថ្នាក់អន្តរជាតិ ។

ដោយយល់ថា វិធានការការពារស្រទាប់អូសូនពីការកែប្រែដោយសារសកម្មភាពមនុស្ស ទាមទារឱ្យមានកិច្ចសហប្រតិបត្តិការ និងសកម្មភាពជាអន្តរជាតិ ហើយត្រូវតែផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកទេសត្រឹមត្រូវ ។

ដោយយល់ពីតម្រូវការចាំបាច់នៃការស្រាវជ្រាវបន្តទៀត និងការសង្កេតពិនិត្យជាប្រចាំ ដើម្បីបង្កបង្កើនចំណេះដឹងស្តីពីស្រទាប់អូសូន និងពីឥទ្ធិពលអវិជ្ជមានដែលអាចកើតមាន បណ្តាលមកពីការកែប្រែស្រទាប់អូសូន ។

ដោយប្តេជ្ញាចិត្តការពារសុខភាពមនុស្ស និងបរិស្ថាន ប្រឆាំងនឹងឥទ្ធិពលអវិជ្ជមាន ដែលបណ្តាលមកពីការកែប្រែស្រទាប់អូសូន ។

បានព្រមព្រៀងគ្នាដូចខាងក្រោម :

## មាត្រា ១
## និយមន័យ

នៅក្នុងអនុសញ្ញានេះ :

១. "ស្រទាប់អូសូន" មានន័យថា ជាស្រទាប់អូសូនបរិយាកាស នៅពីលើស្រទាប់ព្រំប្រទល់របស់ផែនដី ។

២. "ឥទ្ធិពលអវិជ្ជមាន" មានន័យថា ការប្រែប្រួលនៅក្នុងបរិស្ថានរូបសាស្ត្រ ឬបរិស្ថានជីវសាស្ត្រ ដែលរួមទាំងការប្រែប្រួលនៅក្នុងអាកាសធាតុ ដែលមានឥទ្ធិពលបំផ្លិចបំផ្លាញធ្ងន់ធ្ងរលើសុខភាពមនុស្ស ឬលើសមាសភាព ភាពរឹងមាំ និងផលិតភាពរបស់ស្ថានប្រព័ន្ធធម្មជាតិ ឬស្ថានប្រព័ន្ធដែលមនុស្សគ្រប់គ្រង ព្រមទាំងលើសំភារៈដែលមានប្រយោជន៍ដល់មនុស្សជាតិ ។

៣. "បច្ចេកវិទ្យា ឬឧបករណ៍ជំនួស" (alternative technologies or equipment) មានន័យថា បច្ចេកវិទ្យា ឬ ឧបករណ៍ ដែលការប្រើប្រាស់វា អាចឱ្យគេកាត់បន្ថយ ឬបំបាត់ប្រកបដោយប្រសិទ្ធិភាព នូវការបញ្ចេញចោល សារធាតុនានា ដែលមាន ឬអាចមានឥទ្ធិពលអវិជ្ជមានដល់ស្រទាប់អូសូន ។

៤. "សារធាតុជំនួស" មានន័យថា សារធាតុដែលកាត់បន្ថយ បំបាត់ ឬចៀសវាងឥទ្ធិពលអវិជ្ជមានដល់ស្រទាប់ អូសូន ។

៥. "ភាគី" មានន័យថា ភាគី (សមាជិក) នៃអនុសញ្ញានេះ ក្នុងករណីដែលពុំមានការបញ្ជាក់ដោយឡែក ។

៦. "អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់" មានន័យថា អង្គការមួយដែលរួមមានរដ្ឋអធិបតេយ្យនានា នៅតំបន់ណា មួយ ហើយដែលមានសមត្ថកិច្ចនៅក្នុងកិច្ចការទាក់ទងនឹងអនុសញ្ញា ឬពិធីសារនានារបស់អនុសញ្ញានេះ ព្រមទាំង ត្រូវបានផ្តល់សិទ្ធិអំណាច យោងតាមនីតិវិធីផ្ទៃក្នុងរបស់ខ្លួន ក្នុងការចុះហត្ថលេខា ផ្តល់សច្ចាប័ន ទទួលយក អនុម័ត ឬចូលជាសមាជិកនៃលិខិតពាក់ព័ន្ធនានា ។

## មាត្រា ២
## កាតព្វកិច្ចទូទៅ

១. ភាគីទាំងអស់ត្រូវតែចាត់វិធានការសមស្រប យោងទៅតាមខនានារបស់អនុសញ្ញានេះ និងរបស់ពិធីសារទាំងឡាយ ដែលចូលជាធរមាន ហើយដែលខ្លួនជាសមាជិក សំដៅការពារសុខភាពមនុស្ស និងបរិស្ថាន ប្រឆាំងនឹងឥទ្ធិពល អវិជ្ជមាន ដែលបណ្តាលមកពី ឬក៏ប្រហែលបណ្តាលមកពីសកម្មភាពមនុស្ស ដែលកែប្រែស្រទាប់អូសូន ។

២. យោងតាមមធ្យោបាយ និងសមត្ថភាពដែលខ្លួនមាន ភាគីទាំងអស់ត្រូវ :

ក. សហប្រតិបត្តិការតាមរយៈការសង្កេតពិនិត្យជាប្រចាំ ការស្រាវជ្រាវ និងការផ្លាស់ប្តូរពត៌មាន សំដៅស្វែង យល់ និងវាយតំលៃពីឥទ្ធិពលនៃសកម្មភាពមនុស្ស ទៅលើស្រទាប់អូសូន និងពីឥទ្ធិពលទៅលើសុខភាព មនុស្ស និងបរិស្ថាន បណ្តាលមកពីការកែប្រែស្រទាប់អូសូន ។

ខ. ទទួលយកវិធានការច្បាប់ និងវិធានការរដ្ឋបាលសមស្រប និងសហការក្នុងការសំរបសំរួលគោលនយោបាយ សមស្រប សំដៅត្រួតពិនិត្យ ដាក់កំរិត កាត់បន្ថយ ឬបញ្ចៀសនូវសកម្មភាពមនុស្ស ដែលស្ថិតនៅក្រោម សិទ្ធិអំណាច ឬការត្រួតត្រារបស់ខ្លួន ប្រសិនណាបើគេរកឃើញថា សកម្មភាពទាំងនេះមាន ឬក៏ប្រហែលជា មានឥទ្ធិពលអវិជ្ជមាន ដែលបណ្តាលឱ្យមានការកែប្រែ ឬក៏ប្រហែលជាឱ្យមានការប្រែស្រទាប់អូសូន ។

គ. សហការជាមួយស្ថាប័នមានសមត្ថកិច្ចអន្តរជាតិ សំដៅអនុវត្តប្រកបដោយប្រសិទ្ធិភាពនូវអនុសញ្ញានេះ ឬ ពិធីសារនានានៃអនុសញ្ញានេះ ដែលខ្លួនជាសមាជិក ។

៣. ក្នុងគ្រប់ករណី ខនានានៃអនុសញ្ញានេះមិនអាចប៉ះពាល់ដល់សិទ្ធិរបស់ភាគីនានា ក្នុងការអនុម័តវិធានការក្នុងស្រុក យោងតាមច្បាប់អន្តរជាតិ បន្ថែមលើវិធានការទាំងឡាយដែលមានចែងនៅក្នុងកថាខ័ណ្ឌទី ១ និងទី ២ ខាងលើ ហើយក៏មិនអាចប៉ះពាល់ដល់វិធានការក្នុងស្រុកបន្ថែម ដែលភាគីណាមួយបានចាត់រួចហើយ ប្រសិនបើវិធានការ ទាំងនោះស៊ីសង្វាក់គ្នា ជាមួយនឹងកាតព្វកិច្ចរបស់ខ្លួន នៅក្រោមអនុសញ្ញានេះ ។

៤. ការអនុវត្តន៍នូវមាត្រានេះត្រូវតែផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកទេសដ៏សមស្រប ។

## មាត្រា ៣
## ការស្រាវជ្រាវនិងការសង្កេតតាមដានជាប្រចាំ

១. ភាគីទាំងអស់ត្រូវរាប់រងផ្តួចផ្តើមគំនិត និងសហការដោយផ្ទាល់ ឬតាមរយៈស្ថាប័នមានសមត្ថកិច្ចអន្តរជាតិ ក្នុងការ ដឹកនាំស្រាវជ្រាវ និងវាយតំលៃវិទ្យាសាស្ត្រលើ :

ក. ដំណើរការរូបសាស្ត្រ ឬគីមី ដែលអាចមានឥទ្ធិពលដល់ស្រទាប់អូសូន ។

ខ. សុខភាពមនុស្ស និងផលប៉ះពាល់ជីវសាស្ត្រផ្សេងទៀត ដែលបណ្តាលមកពីការកែប្រែណាមួយនៃស្រទាប់អូសូន ជាពិសេសផលប៉ះពាល់ ដែលបណ្តាលមកពីការប្រែប្រួលនៃរំភាយរស្មីស្វាយអុលត្រារបស់ព្រះអាទិត្យ ដែលមានផលប៉ះពាល់ជីវសាស្ត្រ (UV-B) ។

គ. ផលប៉ះពាល់ដល់អាកាសធាតុ ដែលបណ្តាលមកពីការកែប្រែណាមួយនៃស្រទាប់អូសូន ។

ឃ. សារធាតុ ការប្រតិបត្តិ ដំណើរការ និងសកម្មភាពនានា ដែលអាចមានឥទ្ធិពលលើស្រទាប់អូសូន ព្រមទាំងផលប៉ះពាល់សរុបរបស់វា ។

ង. សារធាតុ និងបច្ចេកវិទ្យាជំនួស ។

ច. បញ្ហាសង្គម-សេដ្ឋកិច្ចពាក់ព័ន្ធ ដូចដែលមានចែងលំអិតនៅក្នុងឧបសម្ព័ន្ធទី ១ និងទី ២ ។

២. ភាគីទាំងអស់ត្រូវជំរុញ ឬបង្កើតឱ្យបានសមស្រប ដោយផ្ទាល់ ឬតាមរយៈស្ថាប័នអន្តរជាតិមានសមត្ថកិច្ច និងដោយមានការគិតគូរពេញលេញពីច្បាប់របស់ជាតិ ពីសកម្មភាពកំពុងមានទាំងថ្នាក់ជាតិ និងអន្តរជាតិ នូវកម្មវិធីរួម ឬកម្មវិធីបន្ថែម សំរាប់ការសង្កេតតាមដានជាប្រចាំលើស្ថានភាពស្រទាប់អូសូន និងប៉ារ៉ាម៉ែតពាក់ព័ន្ធផ្សេងទៀត ដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី ១ ។

៣. ភាគីទាំងអស់ត្រូវសហប្រតិបត្តិការដោយផ្ទាល់ ឬតាមរយៈស្ថាប័នអន្តរជាតិមានសមត្ថកិច្ច ដើម្បីធានាឱ្យមានការប្រមូល ការផ្តល់សុពលភាព និងការបញ្ជូននូវទិន្នន័យស្រាវជ្រាវ ឬទិន្នន័យបានមកពីការសង្កេត តាមរយៈមជ្ឈមណ្ឌលទិន្នន័យពិភពលោកពាក់ព័ន្ធ ដោយទៀងទាត់ និងទាន់ពេលវេលា ។

## មាត្រា ៤
## កិច្ចសហប្រតិបត្តិការនៅក្នុងវិស័យច្បាប់វិទ្យាសាស្ត្រនិងបច្ចេកទេស

១. ភាគីទាំងអស់ត្រូវសំរបសំរួល និងជំរុញឱ្យមានការផ្លាស់ប្តូរព័ត៌មានផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស សង្គមសេដ្ឋកិច្ច ពាណិជ្ជកម្ម និងច្បាប់ ដែលពាក់ព័ន្ធនឹងអនុសញ្ញានេះ ដូចមានចែងលំអិតនៅក្នុងឧបសម្ព័ន្ធទី ២ ។ ព័ត៌មានទាំងនេះត្រូវផ្តល់ឱ្យទៅស្ថាប័ននានា ដែលភាគីទាំងអស់បានឯកភាព ។ នៅពេលទទួលព័ត៌មានដែលភាគីផ្តល់ឱ្យចាត់ទុកថាជាព័ត៌មានសំងាត់ ស្ថាប័នទទួលត្រូវធានាថា ព័ត៌មាននេះនឹងមិនត្រូវបញ្ចេញ ហើយត្រូវសរុបបញ្ចូលគ្នា ដើម្បីការពារភាពសំងាត់របស់វា មុននឹងដាក់ឱ្យភាគីផ្សេងៗយកប្រើប្រាស់ ។

២. ភាគីទាំងអស់ត្រូវសហប្រតិបត្តិការ ស្របតាមច្បាប់ បទប្បញ្ញត្តិ និងការប្រតិបត្តិរបស់ជាតិខ្លួន ដោយគិតគូរពីតំរូវការរបស់ប្រទេសកំពុងអភិវឌ្ឍន៍ផង ក្នុងការជំរុញដោយផ្ទាល់ ឬតាមរយៈស្ថាប័នមានសមត្ថកិច្ចអន្តរជាតិ នូវការអភិវឌ្ឍន៍ ការផ្ទេរបច្ចេកវិទ្យា និងការផ្ទេរចំណេះដឹង ។ ជាពិសេស កិច្ចសហប្រតិបត្តិការទាំងនេះត្រូវធ្វើឡើងតាមរយៈ :

ក. ការសំរបសំរួលការទទួលយកបច្ចេកវិទ្យា និងឧបករណ៍ជំនួសដោយភាគីដទៃទៀត ។

ខ. ការផ្តល់ឱ្យនូវព័ត៌មានស្តីពីបច្ចេកវិទ្យា និងឧបករណ៍ជំនួស ព្រមទាំងការផ្គត់ផ្គង់នូវសៀវភៅណែនាំសំរាប់បច្ចេកវិទ្យា ឬឧបករណ៍ទាំងនោះ ។

គ. ការផ្គត់ផ្គង់នូវឧបករណ៍ និងគ្រឿងបរិក្ខារចាំបាច់ សំរាប់ការស្រាវជ្រាវ និងការសង្កេតតាមដានជាប្រចាំ ។

ឃ. ការបណ្តុះបណ្តាលសមស្របសល់បុគ្គលិកបច្ចេកទេស និងវិទ្យាសាស្ត្រ ។

## មាត្រា ៥
## ការបញ្ជូនព័ត៌មាន

តាមរយៈលេខាធិការដ្ឋាន ភាគីទាំងអស់ត្រូវបញ្ជូនឱ្យទៅកិច្ចប្រជុំរបស់ភាគី ដែលបានរៀបចំដោយយោងតាម មាត្រាទី ៦ នូវព័ត៌មានស្តីពីវិធានការនានា ដែលខ្លួនបានចាត់ ដើម្បីអនុវត្តអនុសញ្ញានេះ និងពិធីសារផ្សេងទៀត ដែលខ្លួនបានចុះហត្ថលេខា ក្នុងទំរង់មួយ និងចន្លោះពេលដែលកំណត់ដោយកិច្ចប្រជុំរបស់ភាគី ។

## មាត្រា ៦
## អង្គសន្និបាតរបស់ភាគី

១. អង្គសន្និបាតរបស់ភាគីត្រូវបានបង្កើតឡើង យោងតាមមាត្រានេះ ។ កិច្ចប្រជុំលើកទី ១ នៃអង្គសន្និបាតរបស់ភាគី ត្រូវកោះហៅ មិនយឺតជាងមួយឆ្នាំក្រោយពីអនុសញ្ញានេះចូលជាធរមាន ដោយលេខាធិការដ្ឋាន ដែលជ្រើសតាំងជាបណ្តោះអាសន្ន យោងតាមមាត្រាទី ៧ ។ ក្រោយពីពេលនេះមក កិច្ចប្រជុំសាម័ញ្ញរបស់ភាគីត្រូវប្រព្រឹត្តទៅដោយទៀងទាត់ ក្នុងចន្លោះពេល ដែលនឹងកំណត់ដោយអង្គសន្និបាត នៅក្នុងកិច្ចប្រជុំលើកទី ១ របស់ខ្លួន ។

២. កិច្ចប្រជុំវិសាមញ្ញនៃអង្គសន្និបាតរបស់ភាគី អាចប្រព្រឹត្តទៅនៅពេលណាមួយ ដែលអង្គសន្និបាតយល់ឃើញថាចាំបាច់ ឬនៅពេលដែលមានលិខិតសំណូមពរជាលាយល័ក្ខអក្សររបស់ភាគីណាមួយ ក្នុងករណីដែលមានភាគីដទៃទៀតយ៉ាងហោចណាស់ចំនួនមួយភាគបីគាំទ្រ ក្នុងរយៈពេលប្រាំមួយខែ ក្រោយពេលដែលលេខាធិការដ្ឋានផ្សព្វផ្សាយសំណូមពរនេះទៅឱ្យ ។

អង្គសន្និបាតត្រូវសំរេច និងអនុម័តតាមរយៈកុងសង់ស៊ុស លើបែបបទនីតិវិធី និងបែបបទហិរញ្ញវត្ថុរបស់ខ្លួន និងសំរាប់ស្ថាប័នសាខាដទៃទៀត ក៏ដូចជាលើបែបបទហិរញ្ញវត្ថុសំរាប់ដំណើរការលេខាធិការដ្ឋាន ។

អង្គសន្និបាតត្រូវពិនិត្យជាប្រចាំលើការអនុវត្តដំនៃអនុសញ្ញានេះ ហើយក្រៅពីនេះត្រូវ:

ក. កំណត់នូវទំរង់ និងរយៈពេលសំរាប់បញ្ជូនព័ត៌មាន ដែលត្រូវធ្វើយោងតាមមាត្រាទី ៥ ព្រមទាំងព័ត៌មាន និងរបាយការណ៍នានា ដែលស្ថាប័នសាខាដាក់ជូន ។

ខ. ពិនិត្យលើព័ត៌មានវិទ្យាសាស្ត្រស្តីពីស្រទាប់អូសូន ពីការកែប្រែស្រទាប់អូសូនដែលអាចកើតមាន និងពីឥទ្ធិពលនៃការកែប្រែនេះ ។

គ. ជំរុញឱ្យមានភាពស៊ីសង្វាក់គ្នា យោងតាមមាត្រាទី ២ នូវគោលនយោបាយសមស្រប យុទ្ធសាស្ត្រ និងវិធានការនានា សំរាប់កាត់បន្ថយការបញ្ចេញចោលនូវសារធាតុ ដែលបណ្តាលឱ្យ ឬដែលអាចបណ្តាលឱ្យមានការកែប្រែស្រទាប់អូសូន ព្រមទាំងផ្តល់នូវអនុសាសន៍លើវិធានការផ្សេងទៀត ទាក់ទងទៅនឹងអនុសញ្ញានេះ ។

ឃ. ទទួលយក ដោយយោងតាមមាត្រាទី ៣ និងទី ៤ នូវកម្មវិធីសំរាប់ការស្រាវជ្រាវ សង្កេតតាមដានជាប្រចាំ កិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រ និងបច្ចេកទេស ការផ្លាស់ប្តូរព័ត៌មាន និងការផ្ទេរបច្ចេកវិទ្យា និងចំណេះដឹង ។

ង. យកមកពិនិត្យ និងទទួលយក នៅពេលដែលមានការទាមទារ យោងតាមមាត្រាទី ៩ និងទី ១០ នូវការធ្វើវិសោធនកម្មនៃអនុសញ្ញានេះ ព្រមទាំងឧបសម្ព័ន្ធរបស់វា ។

ច. ពិនិត្យពិចារណាលើវិសោធនកម្មនៃពិធីសារណាមួយ ក៏ដូចជាឧបសម្ព័ន្ធរបស់វា ហើយក្នុងករណីនេះ ផ្តល់យោបល់ដល់ភាគីទាំងអស់ ដើម្បីឱ្យទទួលយកនូវវិសោធនកម្មនៃពិធីសារពាក់ព័ន្ធ ។

ឆ. យកមកពិនិត្យ និងទទួលយក នៅពេលដែលមានការទាមទារ យោងតាមមាត្រាទី ១០ នូវឧបសម្ព័ន្ធបន្ថែមរបស់អនុសញ្ញានេះ ។

ជ. យកមកពិនិត្យ និងទទួលយក នៅពេលដែលមានការទាមទារ នូវពិធីសារនានា យោងតាមមាត្រាទី ៨ ។

ឈ. បង្កើតនូវស្ថាប័នសាខានានា ប្រសិនបើមានការចាំបាច់ សំរាប់អនុវត្តន៍អនុសញ្ញានេះ ។

ញ. ស្វែងរក ប្រសិនបើមានការចាំបាច់ នូវសេវារបស់ស្ថាប័នមានសមត្ថកិច្ចអន្តរជាតិ និងគណៈកម្មាធិការវិទ្យាសាស្ត្រ ដូចជា អង្គការឧតុនិយមពិភពលោក និងអង្គការសុខភាពពិភពលោក ក៏ដូចជាគណៈកម្មាធិការសំរបសំរួលផ្នែកស្រទាប់អូសូន នៅក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រ ការសង្កេតពិនិត្យជាប្រចាំ និងសកម្មភាពផ្សេងទៀត ដែលពាក់ព័ន្ធនឹងគោលបំណងរបស់អនុសញ្ញានេះ ព្រមទាំងប្រើប្រាស់ព័ត៌មានដែលទទួលបានពីស្ថាប័ន និងគណៈកម្មាធិការទាំងនេះឱ្យបានសមស្រប ។

ដ. ពិនិត្យ និងធ្វើសកម្មភាពបន្ថែមទៀត ដែលអាចចាំបាច់ សំរាប់ឈានទៅដល់គោលបំណងនៃអនុសញ្ញានេះ ។

៣. អង្គការសហប្រជាជាតិ ស្ថាប័នជំនាញរបស់អង្គការនេះ និងទីភ្នាក់ងារថាមពលបរមាណូអន្តរជាតិ ក៏ដូចជាប្រទេសដែលមិនមែនជាសមាជិករបស់អនុសញ្ញានេះ អាចចូលរួមនៅក្នុងកិច្ចប្រជុំនៃអង្គសន្និបាតរបស់ភាគី ជាអ្នកសង្កេតការណ៍ ។ ស្ថាប័ន ឬទីភ្នាក់ងារណាមួយ ទោះជាថ្នាក់ជាតិ ឬអន្តរជាតិ របស់រដ្ឋាភិបាល ឬមិនមែនរដ្ឋាភិបាលដែលមានជំនាញនៅក្នុងវិស័យពាក់ព័ន្ធនឹងកិច្ចការពារស្រទាប់អូសូន ហើយដែលបានជូនដំណឹងដល់លេខាធិការដ្ឋានស្តីពីបំណងរបស់ខ្លួន ក្នុងការចូលរួមក្នុងកិច្ចប្រជុំនៃអង្គសន្និបាតរបស់ភាគី ក្នុងនាមជាអ្នកសង្កេតការណ៍ អាចចូលរួមបាន ប្រសិនណាបើពុំមានការជំទាស់ពីសមាជិកវត្តមានចំនួនយ៉ាងហោចណាស់មួយភាគបី ។ ការអនុញ្ញាត និងការចូលរួមរបស់អ្នកសង្កេតការណ៍ ត្រូវតែអនុលោមទៅតាមបែបបទនីតិវិធី ដែលអនុម័តដោយអង្គសន្និបាតរបស់ភាគី ។

## មាត្រា ៧
## លេខាធិការដ្ឋាន

១. មុខងាររបស់លេខាធិការដ្ឋានរួមមាន :

ក. ចាត់ចែង និងផ្តល់សេវាដល់កិច្ចប្រជុំនានា ដូចមានចែងនៅក្នុងមាត្រាទី ៦, ៨, ៩ និង ១០ ។

ខ. រៀបចំ និងចែកចាយរបាយការណ៍ ដោយផ្អែកទៅលើព័ត៌មានដែលទទួលបាន យោងតាមមាត្រាទី ៤ និង ៥ ក៏ដូចជាព័ត៌មានដែលបានមកពីកិច្ចប្រជុំរបស់ស្ថាប័នសាខានានា ដែលបង្កើតឡើងយោងតាមមាត្រាទី ៦

គ. បំពេញតួនាទីរបស់ខ្លួនដែលកំណត់ដោយពិធីសារណាមួយ ។

ឃ. រៀបចំរបាយការណ៍ស្តីពីសកម្មភាពរបស់ខ្លួន ដែលបានធ្វើសំដៅបំពេញមុខងាររបស់ខ្លួន នៅក្រោមអនុសញ្ញានេះ ហើយបង្ហាញរបាយការណ៍ទាំងនេះ ជូនដល់អង្គសន្និបាតរបស់ភាគី ។

ង. ធានាឱ្យមានការសំរបសំរួលចាំបាច់ជាមួយស្ថាប័នអន្តរជាតិពាក់ព័ន្ធ ជាពិសេសធ្វើការរៀបចំផ្នែករដ្ឋបាល ឬកុងត្រានានា ដែលចាំបាច់សំរាប់ដំណើរការមុខងាររបស់ខ្លួនឱ្យមានប្រសិទ្ធិភាព ។

២. កម្មវិធីបរិស្ថានសហប្រជាជាតិនឹងបំពេញមុខងាររបស់លេខាធិការដ្ឋានជាបណ្តោះអាសន្ន រហូតដល់ពេលចុងកិច្ចប្រជុំអចិន្ត្រៃយ៍លើកទីមួយនៃអង្គសន្និបាតរបស់ភាគី ដែលប្រព្រឹត្តទៅយោងតាមមាត្រាទី ៦ ។ នៅក្នុងកិច្ចប្រជុំអចិន្ត្រៃយ៍លើកទីមួយរបស់ខ្លួន អង្គសន្និបាតរបស់ភាគីត្រូវជ្រើសតាំងលេខាធិការដ្ឋាន ពីចំណោមអង្គការអន្តរជាតិមានសមត្ថកិច្ចដែលមានស្រាប់ ហើយដែលបង្ហាញនូវឆន្ទៈរបស់ខ្លួនក្នុងការបំពេញមុខងាររបស់លេខាធិការដ្ឋាន ក្រោមអនុសញ្ញានេះ ។

## មាត្រា ៨
## ការអនុម័តពិធីសារ

១. អង្គសន្និបាតរបស់ភាគីអាចអនុម័តលើពិធីសារនានា នៅក្នុងកិច្ចប្រជុំណាមួយ យោងតាមមាត្រាទី ២ ។

២. លេខាធិការដ្ឋានត្រូវផ្ញើអត្ថបទនៃពិធីសារណាមួយដែលស្នើឡើង ជូនទៅសមាជិកទាំងអស់ យ៉ាងហោចណាស់ឱ្យបាន ប្រាំមួយខែ មុនកិច្ចប្រជុំ ។

## មាត្រា ៩
## វិសោធនកម្មនៃអនុសញ្ញាឬពិធីសារ

១. ភាគីនីមួយៗអាចស្នើធ្វើវិសោធនកម្មដល់អនុសញ្ញានេះ ឬពិធីសារណាមួយ ។ វិសោធនកម្មទាំងនេះត្រូវតែឈរលើ មូលដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកទេសត្រឹមត្រូវ ។

២. វិសោធនកម្មនៃអនុសញ្ញានេះត្រូវតែអនុម័តនៅក្នុងកិច្ចប្រជុំនៃសន្និបាតរបស់ភាគី ។ វិសោធនកម្មលើពិធីសារណា មួយត្រូវតែអនុម័តនៅក្នុងកិច្ចប្រជុំរបស់ភាគីនៃពិធីសារនោះ ។ លេខាធិការដ្ឋានត្រូវតែផ្ញើអត្ថបទវិសោធនកម្ម ដែល ស្នើឡើងលើអនុសញ្ញា ឬពិធីសារណាមួយ លើកលែងតែក្នុងករណីដែលមានចែងដោយឡែកនៅក្នុងពិធីសារនោះ យ៉ាងហោចណាស់ប្រាំមួយខែ មុនកិច្ចប្រជុំពិនិត្យវិសោធនកម្មនោះ ទៅឱ្យភាគីទាំងអស់ ។ លេខាធិការដ្ឋានក៏ត្រូវ ផ្ញើសំណើវិសោធនកម្មទៅឱ្យភាគីហត្ថលេខីនៃអនុសញ្ញា ដើម្បីជាពត៌មាន ។

៣. ភាគីទាំងអស់ត្រូវតែខិតខំឱ្យអស់សមត្ថភាព ដើម្បីឈានដល់កិច្ចព្រមព្រៀងលើសំណើវិសោធនកម្មនៃអនុសញ្ញានេះ តាមរយៈកុងសង់ស៊ុស ។ ប្រសិនបើកិច្ចខិតខំឱ្យមានកុងសង់ស៊ុសពុំបានសំរេច ហើយពុំអាចឈានដល់កិច្ចព្រម ព្រៀងបាន នោះវិសោធនកម្មត្រូវអនុម័តដោយសំលេងភាគច្រើនបីភាគបួនរបស់ភាគីទាំងអស់ ដែលមានវត្តមាន ហើយដែលបោះឆ្នោតនៅក្នុងកិច្ចប្រជុំ ហើយត្រូវដាក់ជូនដល់ភាគីទាំងអស់ សំរាប់ផ្តល់សច្ចាប័ន អនុម័ត ឬការ ទទួលយក ។

៤. នីតិវិធីដែលមានចែងនៅក្នុងកថាខ័ណ្ឌទី ៣ ត្រូវតែអនុវត្តសំរាប់វិសោធនកម្មនៃពិធីសារទាំងអស់ លើកលែងតែក្នុង ករណីដែលពីរភាគបីនៃភាគីរបស់ពិធីសារ ដែលមានវត្តមាន និងបោះឆ្នោតនៅក្នុងកិច្ចប្រជុំ អនុម័តយល់ស្រប ។

៥. ការផ្តល់សច្ចាប័ន ការអនុម័ត ឬការទទួលស្គាល់លើវិសោធនកម្ម ត្រូវតែធ្វើជូនដល់កន្លែងតំកល់ជាលាយល័ក្ខ អក្សរ ។ វិសោធនកម្មដែលត្រូវបានអនុម័តយោងតាមមាត្រាទី ៣ ឬទី ៤ ត្រូវចូលជាធរមានសំរាប់សមាជិកដែល ទទួលស្គាល់ នៅថ្ងៃទី ៩០ ក្រោយពេលដែលកន្លែងតំកល់បានទទួលលិខិតជូនដំណឹងស្តីពីការផ្តល់សច្ចាប័ន ការអនុម័ត ឬការទទួលស្គាល់ របស់សមាជិកនៃអនុសញ្ញានេះយ៉ាងហោចណាស់ចំនួនបីភាគបួន ឬរបស់សមាជិកនៃ ពិធីសារនេះយ៉ាងហោចណាស់ចំនួនពីរភាគបី លើកលែងតែក្នុងករណីដែលមានចែងដោយឡែកណាមួយនៅក្នុង ពិធីសារនេះ ។ វិសោធនកម្មនេះត្រូវចូលជាធរមានសំរាប់សមាជិកទាំងអស់ នៅថ្ងៃទី ៩០ ក្រោយពេលដែលភាគី ទាំងនោះតំកល់ទុកនូវឯកសារស្តីពីការផ្តល់សច្ចាប័ន ការអនុម័ត និងការទទួលយកលើវិសោធនកម្មនេះ ។

៦. នៅក្នុងមាត្រានេះ "ភាគីរបស់ពិធីសារ ដែលមានវត្តមាន និងបោះឆ្នោត" មានន័យថា ភាគីដែលមានវត្តមាន និង បោះឆ្នោតយល់ស្រប ឬជំទាស់ ។

## មាត្រា ១០
## ការអនុម័តនិងវិសោធនកម្មលើឧបសម្ព័ន្ធ

១. ឧបសម្ព័ន្ធនានារបស់អនុសញ្ញានេះ ឬរបស់ពិធីសារណាមួយ គឺជាផ្នែកមិនអាចកាត់ផ្តាច់បានរបស់អនុសញ្ញា ឬពិធី សារនោះ ហើយក្នុងករណីដែលអាចមាន សេចក្តីយោងណាមួយទៅលើអនុសញ្ញា ឬពិធីសាររបស់វា គឺជាសេចក្តី យោងទៅលើឧបសម្ព័ន្ធរបស់វាដែរ ។ ឧបសម្ព័ន្ធទាំងនេះនិយាយតែពីកិច្ចការវិទ្យាសាស្ត្រ បច្ចេកទេស និងរដ្ឋបាល ប៉ុណ្ណោះ ។

២. លើកលែងតែមានចែងជាពិសេសនៅក្នុងនៅក្នុងពិធីសារណាមួយស្តីពីឧបសម្ព័ន្ធរបស់វា នីតិវិធីដូចខាងក្រោមត្រូវអនុវត្តសំរាប់សំណើ ការអនុម័ត និងការចូលជាធរមាននៃឧបសម្ព័ន្ធបន្ថែមរបស់អនុសញ្ញានេះ ឬរបស់ឧបសម្ព័ន្ធទាំងឡាយរបស់ពិធីសារណាមួយ :

ក. ឧបសម្ព័ន្ធសំរាប់អនុសញ្ញានេះត្រូវតែស្នើឡើង និងអនុម័ត យោងទៅតាមនីតិវិធីដែលមានចែងនៅក្នុងមាត្រាទី ៩ កថាខ័ណ្ឌទី ២ និងទី ៣ ហើយឧបសម្ព័ន្ធសំរាប់ពិធីសារណាមួយត្រូវតែស្នើឡើង និងអនុម័ត យោងតាមនីតិវិធីដែលមានចែងនៅក្នុងមាត្រាទី ៩ កថាខ័ណ្ឌទី ២ និងទី ៤ ។

ខ. សមាជិកណាមួយដែលមិនអាចអនុម័តឧបសម្ព័ន្ធបន្ថែមរបស់អនុសញ្ញានេះ ឬឧបសម្ព័ន្ធរបស់ពិធីសារណាមួយដែលខ្លួនជាសមាជិក ត្រូវតែជូនដំណឹងជាលាយល័ក្ខអក្សរដល់កន្លែងតំកល់ទុក ក្នុងរយៈពេលប្រាំមួយខែចាប់ពីពេលដែលកន្លែងតំកល់ទុកផ្តល់ពត៌មានស្តីពីការទទួលយកឧបសម្ព័ន្ធនោះ ។ កន្លែងតំកល់ទុកត្រូវតែជូនដំណឹងជាលាយល័ក្ខអក្សរជាបន្ទាន់ ដល់សមាជិកទាំងអស់ ។ នៅពេលណាក៏បាន សមាជិកណាមួយអាចទទួលយកឧបសម្ព័ន្ធ ជំនួសឱ្យការការប្រកាសបដិសេធពីពេលមុន ហើយបន្ទាប់មក ឧបសម្ព័ន្ធនោះត្រូវចូលជាធរមានសំរាប់សមាជិកនោះ ។

គ. ក្រោយរយៈពេលប្រាំមួយខែ គិតចាប់ពីពេលដែលកន្លែងតំកល់ទុកចែកផ្សាយនូវសេចក្តីជូនដំណឹង ឧបសម្ព័ន្ធនឹងត្រូវចូលជាធរមានសំរាប់សមាជិកទាំងអស់នៃអនុសញ្ញានេះ ឬនៃពិធីសារពាក់ព័ន្ធ ហើយដែលភាគីទាំងនោះមិនបានធ្វើសេចក្តីជូនដំណឹង យោងតាមខដែលមានចែងនៅក្នុងអនុកថាខ័ណ្ឌ "ខ" ខាងលើ ។

៣. សំណើ ការទទួលយក និងការចូលជាធរមាននៃវិសោធនកម្មលើឧបសម្ព័ន្ធរបស់អនុសញ្ញានេះ ឬរបស់ពិធីសារណាមួយ ត្រូវតែអនុវត្តដោយអនុលោមទៅតាមនីតិវិធីដូចគ្នាទៅនឹងសំណើ ការទទួលយក និងការចូលជាធរមាននៃឧបសម្ព័ន្ធរបស់អនុសញ្ញានេះ ឬឧបសម្ព័ន្ធរបស់ពិធីសារណាមួយ ។ វិសោធនកម្ម និងឧបសម្ព័ន្ធទាំងនេះត្រូវតែសង្កត់ធ្ងន់លើកិច្ចការវិទ្យាសាស្ត្រ និងបច្ចេកទេស ។

៤. ប្រសិនបើឧបសម្ព័ន្ធបន្ថែម ឬវិសោធនកម្មរបស់ឧបសម្ព័ន្ធ បណ្តាលឱ្យមានវិសោធនកម្មលើអនុសញ្ញានេះ ឬលើពិធីសារណាមួយ នោះឧបសម្ព័ន្ធបន្ថែម ឬវិសោធនកម្មរបស់ឧបសម្ព័ន្ធខាងលើ មិនអាចចូលជាធរមានបានទេប្រសិនបើវិសោធនកម្មលើអនុសញ្ញានេះ ឬលើពិធីសារពាក់ព័ន្ធមិនទាន់ចូលជាធរមាន ។

## មាត្រា ១១
## ការដោះស្រាយវិវាទ

១. នៅក្នុងករណីដែលមានវិវាទរវាងសមាជិកអនុសញ្ញា ស្តីពីការបកស្រាយ ឬការអនុវត្តន៍អនុសញ្ញានេះ សមាជិកទាំងនោះត្រូវស្វែងរកដំណោះស្រាយ តាមរយៈការចរចារ ។

២. ប្រសិនបើសមាជិកទាំងនោះមិនអាចឈានទៅដល់កិច្ចព្រមព្រៀងបានតាមរយៈការចរចារ នោះគេអាចស្វែងរករួមគ្នានូវការសំរុះសំរួល ដោយភាគីទីបី ។

៣. នៅពេលផ្តល់សច្ចាប័ន ទទួលយក អនុម័ត ឬចូលជាសមាជិកនៃអនុសញ្ញានេះ ឬនៅពេលណាមួយក្រោយពីនេះប្រទេស ឬអង្គការសេដ្ឋកិច្ចរួមក្នុងតំបន់ អាចប្រកាសជាលាយល័ក្ខអក្សរ ដល់កន្លែងតំកល់ទុក ថាចំពោះវិវាទដែលមិនអាចដោះស្រាយតាមរយៈវិធីដូចមានចែងក្នុងកថាខ័ណ្ឌទី ១ និងទី ២ ខាងលើ ខ្លួននឹងទទួលយកនូវមធ្យោបាយដោះស្រាយវិវាទមួយ ឬទាំងពីរខាងក្រោម យោងតាមការចាំបាច់ :

ក. ការសំរុះសំរួល យោងតាមនីតិវិធីដែលនឹងត្រូវអនុម័តដោយអង្គសន្និបាតរបស់ភាគី នៅក្នុងកិច្ចប្រជុំសាមញ្ញលើកទី ១ របស់ខ្លួន ។

ខ. ការដាក់ក្តីវិវាទជូនទៅតុលាការអន្តរជាតិ ។

៤. ប្រសិនបើ យោងតាមកថាខ័ណ្ឌទី ៣ ខាងលើ ភាគីវិវាទពុំទទួលយកនូវនីតិវិធីដូចគ្នាណាមួយ នោះវិវាទត្រូវដាក់ជូនទៅ conciliation យោងតាមកថាខ័ណ្ឌទី ៥ ខាងក្រោម ប្រសិនបើភាគីទាំងនោះពុំបានឯកភាពដោយរបៀបណាមួយផ្សេងទៀត ។

៥. គណកម្មការ conciliation ត្រូវរៀបចំឡើង យោងតាមសំណើរបស់ភាគីវិវាទណាមួយ ។ ភាគីពាក់ព័ន្ធនីមួយៗតែងតាំងចំនួនសមាជិកនៃគណៈកម្មការនេះស្មើគ្នា ហើយប្រធានមួយរូបត្រូវជ្រើសរើសឡើងដោយសមាជិកទាំងអស់ដែលតែងតាំងដោយភាគីនីមួយៗ ។ គណកម្មាធិការនេះត្រូវផ្តល់នូវអនុសាសន៍ចុងក្រោយ ដែលភាគីទាំងអស់ត្រូវគោរពតាម ។

៦. ខទាំងឡាយនៃមាត្រានេះមានប្រសិទ្ធិភាពសំរាប់ពិធីសារទាំងអស់ លើកលែងតែមានចែងដោយឡែកនៅក្នុងពិធីសារនោះ ។

## មាត្រា ១២
## ហត្ថលេខា

អនុសញ្ញានេះត្រូវចំហសំរាប់ចុះហត្ថលេខា នៅក្រសួងការបរទេសសហព័ន្ធរបស់សាធារណរដ្ឋអូទ្រីស នៅទីក្រុងវីយែន ចាប់ពីថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៨៥ ដល់ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៨៥ និងនៅទីស្នាក់ការរបស់អង្គការសហប្រជាជាតិ នៅទីក្រុងញូយ៉ក ចាប់ពីថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៨៥ ដល់ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ១៩៨៦ ។

## មាត្រា ១៣
## ការផ្តល់សច្ចាប័នការទទួលយកនិងការអនុម័ត

១. អនុសញ្ញានេះ និងពិធីសារណាមួយ គឺជាកម្មវត្ថុសំរាប់ការផ្តល់សច្ចាប័ន ការទទួលយក និងការអនុម័ត ដោយរដ្ឋនានា ឬដោយអង្គការសេដ្ឋកិច្ចតំបន់ ។

២. អង្គការណាមួយ ដែលមានចែងនៅក្នុងកថាខ័ណ្ឌទីមួយខាងលើ ហើយដែលក្លាយជាសមាជិកនៃអនុសញ្ញានេះ ឬនៃពិធីសារណាមួយ ដោយពុំមានប្រទេសជាសមាជិករបស់ខ្លួនជាភាគីសមាជិករបស់អនុសញ្ញាឬពិធីសារនោះ ត្រូវមានកាតព្វកិច្ចទាំងអស់ នៅក្រោមអនុសញ្ញា ឬពិធីសារនោះ ។ នៅក្នុងករណីដែលមានសមាជិកមួយ ឬច្រើនរបស់អង្គការ ជាភាគីសមាជិករបស់អនុសញ្ញា ឬពិធីសារពាក់ព័ន្ធ អង្គការនោះ និងសមាជិករបស់ខ្លួនត្រូវធ្វើការសំរេចស្តីពីការទទួលខុសត្រូវរបស់ខ្លួន លើការអនុវត្តកាតព្វកិច្ចខ្លួន ក្រោមអនុសញ្ញា ឬពិធីសារនោះ ។ នៅក្នុងករណីនេះ អង្គការ និងប្រទេសជាសមាជិករបស់អង្គការនេះ ពុំត្រូវបានផ្តល់សិទ្ធិនានា នៅក្រោមអនុសញ្ញា ឬពិធីសារពាក់ព័ន្ធនៅក្នុងពេលតែមួយឡើយ ។

៣. នៅក្នុងឧបករណ៍ផ្តល់សច្ចាប័ន ទទួលយក ឬអនុម័តរបស់ខ្លួន អង្គការទាំងឡាយដែលមាននិយាយក្នុងកថាខ័ណ្ឌទី ១ ខាងលើ ត្រូវប្រកាសស្តីពីទំហំនៃសមត្ថកិច្ចរបស់ខ្លួន ពាក់ព័ន្ធនឹងកិច្ចការក្រោមអនុសញ្ញា ឬពិធីសារពាក់ព័ន្ធ ។ អង្គការទាំងនេះក៏ត្រូវផ្តល់ពត៌មានដល់កន្លែងតំកល់ទុក ស្តីពីការកែប្រែសំខាន់ណាមួយ លើទំហំនៃសមត្ថកិច្ចរបស់ខ្លួន ។

## មាត្រា ១៤
## ការចូលជាសមាជិក

១. អនុសញ្ញានេះ និងពិធីសារណាមួយ ត្រូវបើកចំហសំរាប់ការចូលជាសមាជិកដោយប្រទេសនានា និងអង្គការសេដ្ឋកិច្ចតំបន់ ចាប់តាំងពីថ្ងៃដែលអនុសញ្ញា ឬពិធីសារនោះត្រូវបិទបញ្ឈប់ការចុះហត្ថលេខា ។ ឧបករណ៍នៃការចូលជាសមាជិកត្រូវទុកនៅកន្លែងតំកល់ទុក ។

២. នៅក្នុងឧបករណ៍នៃការចូលជាសមាជិករបស់ខ្លួន អង្គការទាំងឡាយដែលមាននិយាយក្នុងកថាខ័ណ្ឌទី ១ ខាងលើ ត្រូវប្រកាសស្តីពីទំហំនៃសមត្ថកិច្ចរបស់ខ្លួន ពាក់ព័ន្ធនឹងកិច្ចការក្រោមអនុសញ្ញា ឬពិធីសារពាក់ព័ន្ធ ។ អង្គការទាំងនេះ ក៏ត្រូវផ្តល់ពត៌មានដល់កន្លែងតំកល់ទុក ស្តីពីការកែប្រែសំខាន់ណាមួយ លើទំហំនៃសមត្ថកិច្ចរបស់ខ្លួន ។

៣. ខទាំងឡាយនៃកថាខ័ណ្ឌទី ២ របស់មាត្រាទី ១៣ ត្រូវអនុវត្តសំរាប់អង្គការសេដ្ឋកិច្ចតំបន់ ដែលចូលជាសមាជិកជាមួយនឹងអនុសញ្ញា ឬពិធីសារណាមួយ ។

## មាត្រា ១៥
## សិទ្ធិបោះឆ្នោត

១. សមាជិកនៃអនុសញ្ញានេះ ឬពិធីសារណាមួយ ត្រូវមានសំលេងមួយ ។

២. លើកលែងតែដូចមានចែងក្នុងកថាខ័ណ្ឌទី ១ ខាងលើ នៅក្នុងកិច្ចការពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួន អង្គការសេដ្ឋកិច្ចតំបន់ ត្រូវបញ្ចេញសិទ្ធិបោះឆ្នោត ដោយមានចំនួនសំលេងស្មើនឹងចំនួនប្រទេសជាសមាជិករបស់ខ្លួន ហើយដែលជាសមាជិករបស់អនុសញ្ញា ឬពិធីសារពាក់ព័ន្ធ ។ អង្គការទាំងនេះត្រូវចូលរួមបោះឆ្នោត ប្រសិនបើប្រទេសជាសមាជិករបស់ខ្លួនបញ្ចេញសិទ្ធិបោះឆ្នោតរបស់ខ្លួន និងផ្ទុយមកវិញ ។

## មាត្រា ១៦
## ទំនាក់ទំនងរវាងអនុសញ្ញានិងពិធីសារនានារបស់វា

១. ប្រទេសមួយ ឬអង្គការសេដ្ឋកិច្ចតំបន់មួយពុំអាចជាសមាជិករបស់ពិធីសារបានទេ ប្រសិនបើគេពុំមែនជាសមាជិករបស់អនុសញ្ញា ឬក៏អាចជាសមាជិករបស់ពិធីសារ និងអនុសញ្ញាក្នុងពេលតែមួយ ។

២. សេចក្តីសំរេចដែលពាក់ព័ន្ធនឹងពិធីសារត្រូវតែធ្វើឡើង ដោយសមាជិករបស់ពិធីសារនោះតែប៉ុណ្ណោះ ។

## មាត្រា ១៧
## ការចូលជាធរមាន

១. អនុសញ្ញានេះត្រូវចូលជាធរមាន នៅថ្ងៃទីកៅសិប បន្ទាប់ពីកាលបរិច្ឆេទនៃការតំកល់ទុកនូវឧបករណ៍ទីម្ភៃនៃការផ្តល់សច្ចាប័ន ទទួលយក អនុម័ត ឬចូលជាសមាជិក ។

២. ពិធីសារណាមួយ លើកលែងតែមានចែងដោយឡែកនៅក្នុងពិធីសារនោះ ត្រូវចូលជាធរមាន នៅថ្ងៃទីកៅសិប បន្ទាប់ពីកាលបរិច្ឆេទនៃការតំកល់ទុកនូវឧបករណ៍ទីដប់មួយនៃការផ្តល់សច្ចាប័ន ទទួលយក អនុម័ត ឬចូលជាសមាជិក ។

៣. សំរាប់សមាជិកណា ដែលផ្តល់សច្ចាប័ន ទទួលយក អនុម័ត ឬចូលជាសមាជិកលើអនុសញ្ញានេះ ក្រោយពីការតំកល់ទុកនូវឧបករណ៍ទីម្ភៃនៃការផ្តល់សច្ចាប័ន ទទួលយក អនុម័ត ឬចូលជាសមាជិក អនុសញ្ញានេះត្រូវចូលជា

ធរមាន នៅថ្ងៃទីកៅសិប បន្ទាប់ពីកាលបរិច្ឆេទនៃការតំកល់ទុកនូវឧបករណ៍ផ្តល់ សច្ចាប័ន ទទួលយក អនុម័ត ឬចូលជាសមាជិក របស់សមាជិកនោះ ។

៤. ពិធីសារណាមួយ លើកលែងតែមានចែងដោយឡែកនៅក្នុងពិធីសារនោះ ត្រូវចូលជាធរមាន សំរាប់សមាជិកដែលផ្តល់សច្ចាប័ន ទទួលយក អនុម័ត ឬចូលជាសមាជិកលើពិធីសារនោះ ក្រោយពេលដែលពិធីសារនោះចូលជាធរមាន អនុលោមតាមកថាខ័ណ្ឌទី ២ ខាងលើ នៅថ្ងៃទីកៅសិប បន្ទាប់ពីកាលបរិច្ឆេទដែលសមាជិកនោះដាក់តំកល់ទុកនូវឧបករណ៍ផ្តល់ សច្ចាប័ន ទទួលយក អនុម័ត ឬចូលជាសមាជិករបស់ខ្លួន ឬនៅថ្ងៃដែលអនុសញ្ញាចូលជាធរមានសំរាប់សមាជិកនោះ ។ ចំពោះកាលបរិច្ឆេទទាំងពីរនេះ ត្រូវយកតាមកាលបរិច្ឆេទណាដែលក្រោយគេ ។

៥ សំរាប់កថាខ័ណ្ឌទី ១ និងទី ២ ខាងលើ ឧបករណ៍ផ្តល់សច្ចាប័ន ទទួលយក អនុម័ត ឬចូលជាសមាជិករបស់អង្គការសេដ្ឋកិច្ចតំបន់ណាមួយ ពុំត្រូវចាត់ទុកថាជាឧបករណ៍បន្ថែមទៀត សំរាប់សមាជិករបស់អង្គការនោះឡើយ ។

## មាត្រា ១៨
## ខចាក់លក្ខខណ្ឌ

ពុំមានខចាក់លក្ខខណ្ឌណាមួយអាចត្រូវធ្វើសំរាប់អនុសញ្ញានេះទេ ។

## មាត្រា ១៩
## ការលាចេញ

១. សមាជិកណាមួយអាចលាចេញពីអនុសញ្ញា តាមរយៈការជូនដំណឹងជាលាយល័ក្ខអក្សរដល់កន្លែងតំកល់ទុក នៅពេលណាមួយក៏បាន ក្រោយរយៈពេលបួនឆ្នាំ គិតចាប់ពីពេលដែលអនុសញ្ញានេះចូលជាធរមានសំរាប់ភាគីនោះ ។

២. លើកលែងតែក្នុងករណីដែលមានចែងដោយឡែកនៅក្នុងពិធីសារណាមួយ ភាគីណាមួយអាចលាចេញពីពិធីសារណាមួយ តាមរយៈការជូនដំណឹងជាលាយល័ក្ខអក្សរដល់កន្លែងតំកល់ទុក នៅពេលណាមួយក៏បាន ក្រោយរយៈពេលបួនឆ្នាំ គិតចាប់ពីពេលដែលអនុសញ្ញានេះចូលជាធរមាន សំរាប់ភាគីនោះ ។

៣. ការលាចេញទាំងនេះត្រូវចូលជាធរមាន ក្រោយរយៈពេលមួយឆ្នាំ គិតចាប់ពីពេលដែលកន្លែងតំកល់ទុកបានទទួលពាក្យសុំលាលែង ឬក៏នៅពេលក្រោយពីនេះទៀត ដែលអាចមានចែងដោយឡែកនៅក្នុងលិខិតជូនដំណឹងស្តីពីការលាចេញ ។

៤. សមាជិកណាមួយដែលលាចេញពីអនុសញ្ញានេះ ត្រូវបានចាត់ទុកថា លាលែងចេញពីពិធីសារទាំងឡាយដែលខ្លួនជាសមាជិក ។

## មាត្រា ២០
## កន្លែងតំកល់ទុក

១. អគ្គលេខាធិការរបស់អង្គការសហប្រជាជាតិ ត្រូវទទួលមុខងារជាអ្នកតំកល់ទុកនៃអនុសញ្ញានេះ និងពិធីសារនានា ។

២. កន្លែងតំកល់ទុកត្រូវផ្តល់ពត៌មានខាងក្រោម ជូនដល់សមាជិកនានា :

ក. ការចុះហត្ថលេខាលើអនុសញ្ញានេះ និងលើពិធីសារណាមួយ និងការតំកល់ទុកនូវឧបករណ៍ផ្តល់សច្ចាប័ន ទទួលយក អនុម័ត ឬចូលជាសមាជិក យោងតាមមាត្រា ១៣ និង ១៤ ។

ខ. កាលបរិច្ឆេទដែលអនុសញ្ញា ឬពិធីសារណាមួយចូលជាធរមាន យោងតាមមាត្រា ១៧ ។

គ. លិខិតជូនដំណឹងស្តីពីការលាចេញ ដែលធ្វើឡើងយោងតាមមាត្រាទី ១៩ ។

ឃ. វិសោធនកម្ម ដែលអនុម័តសំរាប់អនុសញ្ញា ឬពិធីសារណាមួយ ការទទួលយកវិសោធនកម្មនោះដោយ

សមាជិកនានា និងកាលបរិច្ឆេទនៃការចូលជាធរមាន យោងតាមជំពូក ៩ ។

ង. របាយការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងការយល់ព្រម នឹងការអនុម័តលើឧបសម្ព័ន្ធនានា និងលើវិសោធនកម្មនៃឧបសម្ព័ន្ធ អនុលោមទៅតាមមាត្រាទី ១០ ។

ច. សេចក្តីជូនដំណឹងរបស់អង្គការសេដ្ឋកិច្ចតំបន់ ស្តីពីវិសាលភាពនៃសមត្ថកិច្ចរបស់ខ្លួន ដែលទាក់ទងទៅនឹងកិច្ចការនានា ដែលកំណត់ដោយអនុសញ្ញានេះ និងពិធីសារនានា ព្រមទាំងការកែប្រែណាមួយ ។

ឆ. សេចក្តីប្រកាស ដែលធ្វើឡើងយោងតាមជំពូក ១១ កថាខ័ណ្ឌទី ៣ ។

## មាត្រា ២១
## អត្ថបទច្បាប់ដើម

ច្បាប់ដើមនៃអនុសញ្ញានេះ មានជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ មានតំលៃស្មើគ្នា ហើយ ត្រូវតំកល់ទុកនៅអគ្គលេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិ ។

អនុសញ្ញានេះត្រូវបានចុះហត្ថលេខាដោយតំណាងដែលមានសិទ្ធិពេញលេញ ។

ធ្វើនៅទីក្រុងវីយែន ថ្ងៃទី ២២ ខែមីនា ឆ្នាំ ១៩៨៥ ។

## ឧបសម្ព័ន្ធ ១

## ការស្រាវជ្រាវនិងការសង្កេតតាមដានជាប្រចាំ

១. សមាជិកទាំងអស់របស់អនុសញ្ញានេះ ទទួលស្គាល់ថា បញ្ហាវិទ្យាសាស្ត្រសំខាន់ៗគឺ :

ក. ការកែប្រែស្រទាប់អូសូន ដែលនាំឱ្យមានការប្រែប្រួលនូវបរិមាណវិភាយកាំរស្មីស្វាយអ៊ុលត្រារបស់ព្រះអាទិត្យមានឥទ្ធិពលជីវសាស្ត្រ (UV-B) ដែលចាំងមកដល់ផ្ទៃផែនដី ព្រមទាំងផលវិបាកដែលអាចកើតមានដល់សុខភាពមនុស្ស ដល់សារពាង្គកាយ ស្ថានប្រព័ន្ធ និងរូបធាតុនានាដែលមានប្រយោជន៍សំរាប់មនុស្សជាតិ ។

ខ. ការកែប្រែនូវរបាយអូសូនតាមបន្ទាត់ឈរ ដែលអាចផ្លាស់ប្តូររចនាសម្ព័ន្ធរបស់សីតុណ្ហភាពបរិយាកាស និងផលវិបាកដែលអាចកើតមានដល់ធាតុអាកាស និងអាកាសធាតុ ។

២. យោងតាមមាត្រាទី ៣ សមាជិកទាំងអស់របស់អនុសញ្ញានេះត្រូវធ្វើសហប្រតិបត្តិការ ក្នុងការដឹកនាំការស្រាវជ្រាវនិងការសង្កេតតាមដានជាប្រចាំ និងក្នុងការរៀបចំអនុសាសន៍នានា សំរាប់កិច្ចការស្រាវជ្រាវ និងសង្កេតតាមដាននាពេលអនាគត នៅក្នុងវិស័យទាំងឡាយ ដូចជា :

ក. ការស្រាវជ្រាវលើផ្នែករូបសាស្ត្រ និងគីមីរបស់បរិយាកាស

(១) គំរូជាទ្រឹស្តីយ៉ាងពេញលេញ : ការរៀបចំគំរូបន្តទៀត ដែលពិនិត្យលើអន្តរកម្មរវាងដំណើរការវិភាយរស្មី ឌីណាមិច និងគីមី. សិក្សាពីឥទ្ធិពល នៅពេលតែមួយ របស់ប្រភេទដែលកើតឡើងដោយធម្មជាតិ និងប្រភេទដែលមនុស្សបង្កើត ទៅលើអូសូនបរិយាកាស. បំណកស្រាយសំណុំទិន្នន័យផ្កាយរណប ឬមិនមែនផ្កាយរណប ដែលវាស់វែងបាន. វាយតំលៃលើនិន្នាការរបស់ប៉ារ៉ាម៉ែតបរិយាកាស និងរូបភូគព្ភសាស្ត្រ. និងការរៀបចំវិធីនានាសំរាប់កំណត់ទំនាក់ទំនងរវាងការប្រែប្រួលនៅក្នុងប៉ារ៉ាម៉ែតទាំងនេះ ជាមួយនឹងមូលហេតុដោយឡែកនានា ។

(២) ការសិក្សាក្នុងមន្ទីរពិសោធន៍លើ : rate coefficients, absorption cross-sections និងយន្តការនៃដំណើរប្រព្រឹត្តិគីមី និងផូតូគីមីរបស់មណ្ឌលអាកាសរចល់ និងមណ្ឌលអាកាសស្ងប់. ទិន្នន័យបានមកពីការវិភាគស្ប៉ិច សំរាប់គាំទ្រការវាស់វែងនៅនឹងកន្លែងនៅគ្រប់តំបន់ស្ប៉ិចពាក់ព័ន្ធ ។

(៣) ការវាស់វែងនៅនឹងកន្លែង : កំហាប់ និងភ្លូរបស់ប្រភពឧស្ម័នសំខាន់ៗដែលមានប្រភពពីធម្មជាតិនិងពីមនុស្ស. ការសិក្សាពីឌីណាមិចបរិយាកាស. ការវាស់វែងក្នុងពេលតែមួយលើ photochemically-related species down to the planetary boundary layer ដោយប្រើឧបករណ៍នៅនឹងកន្លែង ឬពីចំងាយ. ការប្រៀបធៀបគ្នាទៅវិញទៅមកលើ sensors ផ្សេងៗគ្នា ដោយរួមទាំង coordinated correlative measurements for satellite instrumentation, three-dimensional fields of key atmospheric trace constituents ភ្លូស្ប៉ិចពន្លឺព្រះអាទិត្យ និងប៉ារ៉ាម៉ែតឧតុនិយម ។

(៤) ការបង្កើតឧបករណ៍ ដូចជា satellite and non-satellite sensors for atmospheric trace constituents ភ្លូព្រះអាទិត្យ និងប៉ារ៉ាម៉ែតឧតុនិយម ។

ខ. ការសិក្សាស្រាវជ្រាវពីឥទ្ធិពលលើសុខភាព ជីវសាស្ត្រ និងការបំបែកធាតុដោយរស្មី (photodegradation)

(១) ទំនាក់ទំនងរវាងការសំអិលត្រូវរបស់មនុស្សទៅនឹងកាំរស្មីព្រះអាទិត្យដែលមើលឃើញ និងកាំរស្មីស្វាយអ៊ុលត្រា និង (ក) ការវិវឌ្ឍន៍មហារីកស្បែកប្រភេទ non-melanoma និង melanoma និង (ខ) ផលប៉ះពាល់លើ immunological system ។

(២) ផលប៉ះពាល់នៃកាំរស្មី UV-B រួមទាំងជំហានរលក ទៅលើ : (ក) ដំណាំកសិកម្ម ព្រៃឈើ និងស្ថានប្រព័ន្ធដីគោក និង (ខ) បណ្តាញអាហារក្នុងទឹក និងជលផល ព្រមទាំងការរំខានដល់ការផលិតអុកស៊ីសែនដោយបូងំក្នុងរុក្ខជាតិ ។

(៣) យន្តការដែលកាំរស្មី UV-B មានអំពើលើរូបធាតុជីវៈ ប្រភេទ និងស្ថានប្រព័ន្ធ រួមមាន : ទំនាក់ទំនងរវាងកំរិតស្រូប អត្រាកំរិតស្រូប និងប្រតិកម្មតប, photorepair បន្សាំ និងការការពារ ។

(៤) ការសិក្សាពី biological action spectra និង ប្រតិកម្មឆ្លើយតបរបស់ស្បិច ដោយប្រើកាំរស្មីប៉ូលីក្រូម៉ាទិច ដើម្បីដាក់បញ្ចូលនូវទំនាក់ទំនងដែលអាចមានរបស់តំបន់មានជំហានរលកផ្សេងៗគ្នា ។

(៥) ឥទ្ធិពលនៃកាំរស្មី UV-B ទៅលើ : ភាព្យស និងសកម្មភាពរបស់ប្រភេទជីវសាស្ត្រ ដែលមានសារៈសំខាន់សំរាប់តុល្យភាពមណ្ឌលជីវៈ, ដំណើរការដំបូងនានា ដូចជារស្មីសំយោគ និងជីវសំយោគ ។

(៦) ឥទ្ធិពលនៃកាំរស្មី UV-B ទៅលើការបំបែកធាតុដោយរស្មីនៃសារធាតុបំពុល សារធាតុគីមីកសិកម្ម និងរូបធាតុផ្សេងទៀត ។

គ. ការស្រាវជ្រាវស្តីពីឥទ្ធិពលទៅលើអាកាសធាតុ

(១) ការសិក្សាបែបទ្រឹស្តី និងដោយសង្កេតលើឥទ្ធិពលវិភាយរស្មីរបស់អូសូន និងប្រភេទឧស្ម័នមួយចំនួនទៀត និងលើផលប៉ះពាល់ដល់ប៉ារ៉ាម៉ែតអាកាសធាតុ ដូចជាសីតុណ្ហភាពផ្ទៃដីនិងផ្ទៃសមុទ្រ របបកំណកអាកាស ការផ្លាស់ប្តូររវាងមណ្ឌលអាកាសរចល់ និងមណ្ឌលអាកាសស្ងប់ ។

(២) ការស្រាវជ្រាវស្តីពីឥទ្ធិពលនៃផលប៉ះពាល់អាកាសធាតុទៅលើផ្នែកផ្សេងៗនៃសកម្មភាពមនុស្ស ។

ឃ. ការសង្កេតតាមដានជាប្រចាំ

(១) ស្ថានភាពនៃស្រទាប់អូសូន (ពោលគឺការប្រែប្រួលក្នុងកាល និងលំហ នូវសមាសភាពសរុប និង រាយតាមបន្ទាត់ឈរ) តាមរយៈការធ្វើប្រព័ន្ធសង្កេតពិនិត្យអូសូនពិភពលោក ដោយឈរលើការដាក់បញ្ចូលគ្នានូវប្រព័ន្ធផ្កាយរណប និងប្រព័ន្ធមានមូលដ្ឋានលើផ្ទៃដី ដែលដំណើរការ ។

(២) កំហាប់នៅក្នុងមណ្ឌលអាកាសរចល់ និងមណ្ឌលអាកាសស្ងប់ នៃឧស្ម័នជាប្រភពនៃ $HO_x$, $NO_x$, $ClO_x$ និងអំបូរកាបូន ។

(៣) សីតុណ្ហភាពចាប់ពីផ្ទៃដី ទៅដល់បរិយាកាស ដោយប្រើប្រព័ន្ធផ្កាយរណប និងប្រព័ន្ធមានមូលដ្ឋានលើផ្ទៃដី ។

(៤) ភ្លួចកាំរស្មីព្រះអាទិត្យ wavelength-resolved ដែលចាំងមកដល់បរិយាកាស និងវិភាយកំដៅដែលផ្ទាតចេញពីបរិយាកាសវិញ ដោយប្រើការវាស់វែងតាមផ្កាយរណប ។

(៥) ភ្លួចកាំរស្មីព្រះអាទិត្យ wavelength-resolved ដែលចាំងមកដល់ផ្ទៃផែនដី ក្នុងទំរង់ជាកាំរស្មីស្វាយអុលត្រាដែលមានឥទ្ធិពលជីវសាស្ត្រ (UV-B) ។

(៦) លក្ខណៈរបស់អាអេរ៉ូសុល និងរបាយរបស់វា ចាប់ពីផ្ទៃផែនដី រហូតដល់មេសូស្វៀ ដោយប្រើប្រព័ន្ធដាក់នៅលើផ្ទៃដី យន្តហោះ ឬផ្កាយរណប ។

(៧) បំរែបំរួលគីមីសំខាន់ៗ តាមរយៈការទ្រទ្រង់ដល់កម្មវិធីវាស់វែងឧតុនិយមវិទ្យានៅលើផ្ទៃដីដែលមានគុណភាពខ្ពស់ ។

(៨) Trace species សីតុណ្ហភាព ភ្លួចកាំរស្មីព្រះអាទិត្យ និងអាអេរ៉ូសុល ដោយប្រើវិធីដែលត្រូវបានកែលំអសំរាប់វិភាគទិន្នន័យពិភពលោក ។

៣. សមាជិកនៃអនុសញ្ញាទាំងអស់ត្រូវសហការ ដោយយកចិត្តទុកដាក់លើតំរូវការដោយឡែករបស់ប្រទេសកំពុងអភិវឌ្ឍន៍ នៅក្នុងការបណ្តុះបណ្តាលវិទ្យាសាស្ត្រ និងបច្ចេកទេសសមស្រប ដែលចាំបាច់សំរាប់ចូលរួមក្នុងការស្រាវជ្រាវ និងសង្កេតតាមដានជាប្រចាំ ដែលមានចែងនៅក្នុងឧបសម្ព័ន្ធនេះ ។ ត្រូវផ្តោតអារម្មណ៍ជាពិសេសលើការធ្វើឱ្យត្រូវខ្នាតគ្នានៃឧបករណ៍សំរាប់សង្កេតតាមដាន និងវិធីនានា សំដៅបង្កើតសំណុំទិន្នន័យវិទ្យាសាស្ត្រដែលអាចប្រៀបធៀបគ្នាបាន ឬដែលមានស្តង់ដាដូចគ្នា ។

៤. សារធាតុគីមីខាងក្រោម ដែលមានប្រភពធម្មជាតិ ឬប្រភពពីមនុស្ស ហើយដែលពុំត្រូវបានរៀបដាក់តាមលំដាប់អាទិភាព ត្រូវបានគេយល់ស្របថា មានសក្តានុពលភាពក្នុងការកែប្រែលក្ខណៈគីមី និងលក្ខណៈរូបរបស់ស្រទាប់អូសូន :

ក. សារធាតុកាបូន :

(១) កាបូនម៉ូណូអុកស៊ីត (CO)

កាបូនម៉ូណូអុកស៊ីតមានប្រភពសំខាន់ពីធម្មជាតិ និងពីមនុស្ស ហើយគេគិតថាចូលរួមដោយផ្ទាល់នៅក្នុងដំណើរផ្លូវគីមីក្នុងមណ្ឌលអាកាសរចល់ និងចូលរួមដោយប្រយោលនៅក្នុងដំណើរផ្លូវគីមីក្នុងមណ្ឌលអាកាសស្ងប់ ។

(២) កាបូនឌីអុកស៊ីត ($CO_2$)

កាបូនឌីអុកស៊ីតមានប្រភពសំខាន់ពីធម្មជាតិ និងពីមនុស្ស ហើយមានឥទ្ធិពលលើអូសូនរបស់មណ្ឌលអាកាសស្ងប់ តាមរយៈអំពើទៅលើរចនាសម្ព័ន្ធកំដៅរបស់បរិយាកាស ។

(៣) មេតាន ($CH_4$)

មេតានមានប្រភពសំខាន់ពីធម្មជាតិផង និងពីមនុស្សផង ហើយមានឥទ្ធិពលលើអូសូននៅក្នុងមណ្ឌលអាកាសរចល់ និងក្នុងមណ្ឌលអាកាសស្ងប់ ។

(៤) សារធាតុអ៊ីដ្រូកាបូក្រៅពីមេតាន

សារធាតុអ៊ីដ្រូកាបូក្រៅពីមេតាន ដែលរួមមានសារធាតុគីមីជាច្រើន មានប្រភពពីធម្មជាតិ និងពីមនុស្ស ហើយចូលរួមដោយផ្ទាល់ក្នុងដំណើរផ្លូវគីមីនៅមណ្ឌលអាកាសរចល់ និងដោយប្រយោលក្នុងដំណើរផ្លូវគីមីនៅមណ្ឌលអាកាសស្ងប់ ។

ខ. សារធាតុអាសូត

(១) ឌីអាសូតម៉ូណូអុកស៊ីត ($N_2O$)

$N_2O$ មានប្រភពចំបងពីធម្មជាតិ ប៉ុន្តែប្រភពពីមនុស្សកាន់តែកើនឡើងជាលំដាប់ ។ ឌីអាសូតម៉ូណូអុកស៊ីតជាប្រភពបឋមនៃអាសូតអុកស៊ីត ($NO_x$) ក្នុងមណ្ឌលអាកាសស្ងប់ ដែលមាននាទីយ៉ាងសំខាន់នៅក្នុងការត្រួតពិនិត្យភាពសំបូរហូរហៀរនៃអូសូនក្នុងមណ្ឌលអាកាសស្ងប់ ។

(២) អាសូតអុកស៊ីត ($NO_x$)

ប្រភព $NO_x$ នៅកំពស់ផ្ទៃដីមាននាទីសំខាន់ផ្ទាល់ក្នុងដំណើរគីមីនៅមណ្ឌលអាកាសរចល់ និងមាននាទីប្រយោលក្នុងដំណើរគីមីនៅមណ្ឌលអាកាសស្ងប់ ហើយការបញ្ចេញ $NO_x$ នៅស្បែរស្រទាប់ត្រូប៉ូប៉ោស អាចបណ្តាលឱ្យមានការប្រែប្រួលដោយផ្ទាល់នៃអូសូនមណ្ឌលអាកាសរចល់ និងមណ្ឌលអាកាសស្ងប់ ។

គ. សារធាតុក្លរ

(១) អាល់កានរងអាឡូសែនកម្ពុពេញ ដូចជា $CCl_4$, $CFCl_3$ (CFC-11), $CF_2Cl_2$ (CFC-12), $C_2F_3Cl_3$ (CFC-113), $C_2F_4Cl_2$ (CFC-114)

អាល់កានអាឡូសែនពេញមានប្រភពពីធម្មជាតិ ហើយដើរតួជាប្រភពនៃ $ClO_x$ ដែលមាននាទីយ៉ាងសំខាន់នៅក្នុងដំណើរផ្លូវគីមីនៃអូសូន ជាពិសេសនៅរយៈកំពស់ 30-50 km.

(២) អាល់កានរងអាឡូសែនដោយភាគ ដូចជា $CH_3Cl$, $CHF_2Cl$ (CFC-22), $CH_3CCl_3$, $CHFCl_2$ (CFC-21)

$CH_3Cl$ មានប្រភពពីធម្មជាតិ ហើយអាល់កានរងអាឡូសែនដោយភាគក្រៅពីនេះ ដែលមានរៀបរាប់ខាងលើ មានប្រភពពីមនុស្ស ។ ឧស្ម័នទាំងនេះមាននាទីជាប្រភពនៃ $ClO_x$ នៅក្នុងមណ្ឌលអាកាសស្ងប់ ។

ឃ. សារធាតុប្រូម

អាល់កានរងអាឡូសែនកម្ពុពេញ ដូចជា $CF_3Br$ ។ ឧស្ម័នទាំងនេះមានប្រភពពីមនុស្ស ហើយមាននាទីជា

ប្រភពនៃ $BrO_x$ ដែលមានអំពើស្រដៀងគ្នាទៅនឹង $ClO_x$ ដែរ ។

ង. សារធាតុអ៊ីដ្រូសែន

(១) អ៊ីដ្រូសែន ($H_2$)

អ៊ីដ្រូសែនមានប្រភពពីធម្មជាតិផង និងពីមនុស្សផង ហើយមាននាទីពុំសូវ សំខាន់នៅក្នុងដំណើរផ្លូវគីមី នៃមណ្ឌលអាកាសស្ងប់ ។

(២) ទឹក ($H_2O$)

ទឹកមានប្រភពពីធម្មជាតិ ហើយមាននាទីយ៉ាងសំខាន់នៅក្នុងដំណើរផ្លូវគីមីក្នុងមណ្ឌលអាកាសរចល់ និងក្នុងមណ្ឌលអាកាសស្ងប់ ។ ប្រភពនៅនឹងកន្លែងនៃចំហាយទឹកនៅក្នុងមណ្ឌលអាកាសស្ងប់ រួមមានទាំងអុកស៊ីតកម្មនៃមេតាន និងអ៊ីដ្រូសែនក្នុងបរិមាណតិចជាង ។

## ឧបសម្ព័ន្ធ ២

## ការផ្លាស់ប្តូរពត៌មាន

១. សមាជិកទាំងអស់របស់អនុសញ្ញានេះ ទទួលស្គាល់ថា ការប្រមូល និងផ្លាស់ប្តូរពត៌មាន គឺជាមធ្យោបាយយ៉ាងសំខាន់ សំរាប់អនុវត្តទិសដៅនៃអនុសញ្ញានេះ ព្រមទាំងសំរាប់ធានាថា សកម្មភាពនានា ដែលអាចចាត់ធ្វើ មានភាពសមស្រប និងសមធម៌ ។ អាស្រ័យហេតុនេះ សមាជិកទាំងអស់ត្រូវផ្លាស់ប្តូរពត៌មានវិទ្យាសាស្ត្រ បច្ចេកទេស សង្គមកិច្ច សេដ្ឋកិច្ច ជំនួញ ពាណិជ្ជកម្ម និងច្បាប់ ។

២. នៅក្នុងការធ្វើសេចក្តីសំរេចថា តើពត៌មានបែបណាត្រូវប្រមូល និងផ្លាស់ប្តូរ សមាជិកទាំងអស់នៃអនុសញ្ញាត្រូវគិតគូរពីភាពមានប្រយោជន៍របស់ពត៌មាន និងពីតំលៃនៃការប្រមូលយកពត៌មានទាំងនោះ ។ លើសពីនេះ សមាជិកទាំងអស់ទទួលស្គាល់ថា កិច្ចសហប្រតិបត្តិការនៅក្រោមឧបសម្ព័ន្ធនេះត្រូវតែស្របទៅនឹងច្បាប់របស់ជាតិ បទប្បញ្ញត្តិ និងការអនុវត្តន៍ ដែលពាក់ព័ន្ធនឹងការរក្សាសិទ្ធិ កិច្ចការសំងាត់ពាណិជ្ជកម្ម និងកិច្ចការពារពត៌មានសំងាត់ និងផ្តាច់មុខ ។

៣. ពត៌មានវិទ្យាសាស្ត្រ ដែលរួមមានពត៌មានស្តីពី :

(ក) ការស្រាវជ្រាវដែលកំពុងធ្វើ និងនឹងត្រូវធ្វើ ទាំងរបស់រដ្ឋ ទាំងរបស់ឯកជន សំដៅជំរុញការសំរបសំរួលកម្មវិធីស្រាវជ្រាវ ដើម្បីប្រើប្រាស់ធនធានជាតិ និងអន្តរជាតិដែលមាន ប្រកបដោយប្រសិទ្ធិភាព ។

(ខ) ទិន្នន័យទាក់ទងនឹងការបញ្ចេញឧស្ម័ន ដែលចាំបាច់សំរាប់ការស្រាវជ្រាវ ។

(គ) លទ្ធផលវិទ្យាសាស្ត្រ ដែលបោះពុម្ពផ្សាយនៅក្នុងឯកសារដែលគេពិនិត្យឡើងវិញហើយ ទាក់ទងនឹងចំណេះដឹងស្តីពីរូបសាស្ត្រ និងគីមីរបស់បរិយាកាសផែនដី ព្រមទាំងពីភាពងាយប្រែប្រួល ជាពិសេសស្តីពីស្ថានភាពនៃស្រទាប់អូសូន និងពីឥទ្ធិពលទៅលើសុខភាពមនុស្ស បរិស្ថាន និងអាកាសធាតុ ដែលជាលទ្ធផលនៃការប្រែប្រួលក្នុងកាល នៃបរិមាណសរុប ឬរបាយអូសូនតាមខ្សែឈរ ។

(ឃ) ការវាយតំលៃលើលទ្ធផលនៃការស្រាវជ្រាវ និងអនុសាសន៍នានា សំរាប់ការស្រាវជ្រាវនាពេលអនាគត ។

៤. ពត៌មានបច្ចេកទេស ដែលរួមមានពត៌មានស្តីពី :

(ក) ភាពដែលអាចមាន និងតំលៃនៃសារធាតុគីមីជំនួស និងបច្ចេកវិទ្យាជំនួស សំរាប់កាត់បន្ថយការបញ្ចេញសារធាតុដែលកែប្រែស្រទាប់អូសូន ព្រមទាំងការស្រាវជ្រាវដែលកំពុងដំណើរការ ឬដែលមានគំរោង ។

(ខ) កំរិតព្រំដែន និងភាពប្រថុយប្រថាន ដែលបណ្តាលមកពីការប្រើប្រាស់សារធាតុគីមីជំនួស និងបច្ចេកវិទ្យាជំនួស ។

៥. ពត៌មានសង្គម-សេដ្ឋកិច្ច និងពាណិជ្ជកម្ម ស្តីពីសារធាតុដែលមានចែងនៅក្នុងឧបសម្ព័ន្ធទី ១ ដែលរួមមានពត៌មានស្តីពី :

(ក) ផលិតកម្ម និងសមត្ថភាពផលិតកម្ម

(ខ) ការប្រើប្រាស់ និងគំរូនៃការប្រើប្រាស់

(គ) ការនាំចេញ និងការនាំចូល

(ឃ) តំលៃ ការប្រថុយប្រថាន និងផលប្រយោជន៍នៃសកម្មភាពមនុស្ស ដែលអាចកែប្រែដោយប្រយោលនូវស្រទាប់អូសូន ព្រមទាំងតំលៃការប្រថុយប្រថាន និងផលប្រយោជន៍នៃផលប៉ះពាល់របស់សកម្មភាពកែតំរូវ ដែលអនុវត្ត ឬលើកយកមកពិនិត្យ សំរាប់ត្រួតពិនិត្យសកម្មភាពទាំងនោះ ។

៦. ព័ត៌មានផ្នែកច្បាប់ ដែលរួមមាន :

(ក) ច្បាប់របស់ជាតិវិធានការរដ្ឋបាល និងការស្រាវជ្រាវផ្នែកច្បាប់ ដែលទាក់ទងទៅនឹងកិច្ចការពារស្រទាប់អូសូន ។

(ខ) កិច្ចព្រមព្រៀងអន្តរជាតិនានា រួមទាំងកិច្ចព្រមព្រៀងទ្វេភាគី ដែលទាក់ទងទៅនឹងកិច្ចការពារស្រទាប់អូសូន ។

(គ) វិធី និងលក្ខខណ្ឌនានាស្តីពីការចេញអាជ្ញាប័ណ្ណ និងសិទ្ធិផ្តាច់មុខ ដែលទាក់ទងទៅនឹងកិច្ចការពារស្រទាប់អូសូន ។

| | |
|---|---|
| accession | ការសុំចូលជាសមាជិក |
| adoption | ការទទួលយក |
| amendment | វិសោធនកម្ម |
| approval | ការអនុម័ត |
| convention | អនុសញ្ញា |
| model | គំរូ, ម៉ូដែល |
| modification | ការកែប្រែ |
| protocol | ពិធីសារ |
| Party | សមាជិក, ភាគី |

# The Vienna Convention for the Protection of the Ozone Layer

UNEP

**Ozone Secretariat**
**United Nations Environment Programme**

Published November 2001

by

Secretariat for
The Vienna Convention for the Protection of the Ozone Layer,&
The Montreal Protocol on Substances that Deplete the Ozone Layer

United Nations Environment Programme
PO Box 30552
Nairobi
Kenya

web site: http://www.unep.org/ozone
http://www.unep.ch/ozone

ISBN: 92-807-2121-6

Printed and bound in Kenya by UNON. Printed on recycled paper.

Cover design by UNON Printshop (November 2001)

Co-ordination: Nelson Sabogal, Senior Scientific Affairs Officer
ចាប់តាំងពីពាក់កណ្តាលទសវត្សទី ៨០មក គេបានរកឃើញភស្តុតាងវិទ្យាសាស្ត្រជាច្រើនដែលអះអាងថា សកម្មភាពរបស់មនុស្សជាមូលហេតុចម្បងនៃការប្រែប្រួលអាកាសធាតុមិនប្រក្រតីនាប៉ុន្មានទសវត្សចុងក្រោយនេះ។ ប្រសិនបើនិន្នាការប្រែប្រួលអាកាសធាតុនេះ នៅតែបន្តទៀតនោះ នាពេលអនាគត ពិភពលោកនឹងជួបប្រទះនូវការកើនកំដៅ ការឡើងកម្ពស់ទឹកសមុទ្រ ការប្រែប្រួលកម្ពស់ទឹកភ្លៀង និងព្រឹត្តិការណ៍អាកាសធាតុមិនប្រក្រតីជាច្រើនទៀត (ភាពរាំងស្ងួត ទឹកជំនន់ ខ្យល់ព្យុះ សង្ឃរា) ដែលអាចមានផលប៉ះពាល់អវិជ្ជមានយ៉ាងធ្ងន់ធ្ងរដល់គ្រប់វិស័យនៃសេដ្ឋកិច្ច ជាពិសេសវិស័យកសិកម្ម រុក្ខកម្ម ធនធានទឹក សុខាភិបាល បរិស្ថាន និងការលិចលង់តំបន់ទំនាបតាមឆ្នេរសមុទ្រជាដើម។ ប្រទេសក្រីក្រជាអ្នកងាយទទួលរងគ្រោះជាងគេពីការប្រែប្រួលអាកាសធាតុ ដោយសារតែបណ្តាប្រទេសទាំងនោះ ភាគច្រើនជាប្រទេសកសិកម្ម ហើយមានសមត្ថភាព មធ្យោបាយ និងធនធានស្តួចស្តើងបំផុតសម្រាប់ចាត់វិធានការ ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

ដោយយល់យ៉ាងច្បាស់ពីផលវិបាកដ៏ធ្ងន់ធ្ងរទាំងនេះ បណ្តាប្រទេសនៅលើពិភពលោក បានឯកភាពគ្នាអនុម័តអនុសញ្ញាក្របខណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (United Nations Framework Convention on Climate Change, UNFCCC) នៅក្នុងសន្និសីទកំពូលពិភពលោករបស់អង្គការសហប្រជាជាតិ ស្តីពីបរិស្ថាន និងការអភិវឌ្ឍ ដែលបានប្រព្រឹត្តទៅនាខែមិថុនា ឆ្នាំ ១៩៩២ នៅទីក្រុងរីយ៉ូដឺសានេរ៉ូ នៃប្រទេសប្រេស៊ីល។

គោលបំណងសំខាន់នៃអនុសញ្ញានេះ គឺធ្វើឱ្យកំហាប់ឧស្ម័នផ្ទះកញ្ចក់ (Greenhouse gases) នៅក្នុងបរិយាកាសមានស្ថេរភាព នៅក្នុងកម្រិតមួយដែលអាចរាំងស្កាត់នូវឥទ្ធិពលប្រកបដោយគ្រោះថ្នាក់ បណ្តាលមកពីសកម្មភាពមនុស្ស ចំពោះប្រព័ន្ធអាកាសធាតុ។

មកទល់បច្ចុប្បន្ន មានប្រទេសចំនួន ១៨៦ នៅលើពិភពលោក បានចូលរួមជាសមាជិកនៃអនុសញ្ញានេះ។ ប្រទេសកម្ពុជាបានចុះហត្ថលេខា សុំចូលជាសមាជិកនៃអនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ នាថ្ងៃទី ១៨ ខែ ធ្នូ

ឆ្នាំ១៩៩៥ ហើយនៅថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៦ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបានអនុម័តច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាក្របខណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុនេះ នាសម័យប្រជុំលើកទី ៧ នីតិកាលទី ១។

នៅឆ្នាំ ១៩៩៨ មូលនិធិបរិស្ថានពិភពលោក (Global Environment Facility, GEF) និងកម្មវិធីអភិវឌ្ឍសហប្រជាជាតិ (United Nations Development Programme, UNDP) បានអនុម័តផ្តល់ជំនួយចំនួន ៣២ម៉ឺនដុល្លារអាមេរិក ដើម្បីឱ្យកម្ពុជារៀបចំរបាយការណ៍ជាតិ លើកទីមួយរបស់ខ្លួនសម្រាប់ដាក់ជូនសម័យប្រជុំប្រចាំឆ្នាំនៃភាគីជាសមាជិករបស់អនុសញ្ញា។ យើងបានប្រើប្រាស់ជំនួយនេះ សម្រាប់ការធ្វើសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ ជាលើកដំបូងនៅកម្ពុជាដែលបានកំណត់ឃើញថា នៅឆ្នាំ ១៩៩៤ ប្រទេសកម្ពុជាបានបញ្ចេញឧស្ម័នផ្ទះកញ្ចក់ចំនួនប្រមាណ ៦០លានតោន ហើយព្រៃឈើយើងស្រូបយកឧស្ម័នកាបូនិចពីបរិយាកាសចំនួនប្រមាណ ៦៥លានតោន។

ពិធីសារក្យូតូ (The Kyoto Protocol) គឺជាកិច្ចព្រមព្រៀងទីមួយ នៅក្រោមអនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ ដែលបានកំណត់គោលដៅជាក់លាក់ ក្នុងការឈានទៅសម្រេចគោលដៅចម្បងនៃអនុសញ្ញា ស្តីពីការប្រែប្រួលអាកាសធាតុ តាមរយៈការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ នៅក្នុងប្រទេសអភិវឌ្ឍ។ ពិធីសារក្យូតូត្រូវបានអនុម័តដោយសមាជិក នៃអនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ នៅក្នុងកិច្ចប្រជុំរបស់ភាគីជាសមាជិកលើកទី៣ ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី ០១ ដល់ ១១ ខែធ្នូ ឆ្នាំ ១៩៩៧ នៅទីក្រុងក្យូតូ ប្រទេសជប៉ុន។ ពិធីសារនេះត្រូវបានចុះហត្ថលេខាចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ ១៩៩៨ ដល់ថ្ងៃទី១៥ ខែមីនា ឆ្នាំ ១៩៩៩ នៅទីស្នាក់ការរបស់អង្គការសហប្រជាជាតិនាទីក្រុងញូវយ៉ក។ គិតត្រឹមថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៥ មានប្រទេសចំនួន៨៤ បានចុះហត្ថលេខាលើពិធីសារនេះ ហើយប្រទេសចំនួន ១៥១ បានផ្តល់សច្ចាប័ន ឬសុំចូលជាសមាជិករួចហើយ។ ប្រទេសដែលពុំទាន់ចុះហត្ថលេខា និងផ្តល់សច្ចាប័នដល់ពិធីសារនេះ អាចសុំចុះហត្ថលេខា និងសុំចូលជាសមាជិកនៅពេលណាមួយក៏បាន។ ពិធីសារនេះចូលជាធរមាន នៅក្នុងរយៈពេល ៩០ថ្ងៃ ក្រោយពីពេលដែលប្រទេសចំនួន ៥៥ ផ្តល់សច្ចាប័ន ឬចូលជាសមាជិក ដោយរួមទាំងប្រទេសក្នុងឧបសម្ព័ន្ធទី ១ ផង (ពោលគឺក្រុមប្រទេសមានឧស្សាហកម្មលូតលាស់ និងប្រទេសមានសេដ្ឋកិច្ចស្ថិតនៅក្នុងអន្តរកាលជាអតីតប្រទេសក្នុងប្លុកសង្គមនិយម) ដែលបានបញ្ចេញឧស្ម័នកាបូនិចចំនួន ៥៥% នៃបរិមាណសរុបនៅឆ្នាំ ១៩៩០។ ពិធីសារនេះបានចូលជាធរមាននៅថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០០៥ ពោលគឺ ៩០ថ្ងៃ ក្រោយពេលដែលសហព័ន្ធរុស្ស៊ីបានផ្តល់សច្ចាប័ន ដល់ពិធីសារនេះ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤។ ពិធីសារនេះ គឺជាជំហានជាក់ស្តែងទី ១ ដែលអាចជួយពិភពលោកឈានទៅសម្រេចបាននូវគោលដៅចុងក្រោយនៃអនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ គឺការរាំងស្កាត់ " ឥទ្ធិពលប្រកបដោយគ្រោះថ្នាក់ បណ្តាលពីសកម្មភាពមនុស្សចំពោះប្រព័ន្ធអាកាសធាតុ "។ យោងតាមពិធីសារនេះ ប្រទេសចំនួន ៣៨នៅក្នុងឧបសម្ព័ន្ធទី ១ នៃអនុសញ្ញាបានយល់ព្រម បំពេញកាតព្វកិច្ចកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ប្រាំមួយមុខ ក្នុងបរិមាណយ៉ាងហោចណាស់ចំនួន ៥% ធៀបនឹងកម្រិតដែល ប្រទេសទាំងនោះបានបញ្ចេញនៅឆ្នាំ ១៩៩០ ក្នុងចន្លោះឆ្នាំ ២០០៨ និង២០១២។ បណ្តាប្រទេស ទាំងនេះអាចធ្វើការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ដែលជាកាតព្វកិច្ចរបស់ខ្លួន តាមរយៈយន្តការបីគឺ ទីមួយ

ការធ្វើ ពាណិជ្ជកម្មអេមីស្យុង (Emission Trading, ET) ទីពីរ ការអនុវត្តរួមគ្នា (Joint Implementation, JI) រវាងប្រទេស អភិវឌ្ឍដូចគ្នា និងទីបី យន្តការអភិវឌ្ឍស្អាត (Clean Development Mechanism, CDM) សំដៅលើកទឹកចិត្ត ឱ្យមានគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នរួមគ្នារវាងប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍ។

កាលានុវត្តភាពសំខាន់របស់ពិធីសារនេះ សម្រាប់ប្រទេសកំពុងអភិវឌ្ឍ គឺការចូលរួមអនុវត្តគម្រោងក្រោម "យន្តការអភិវឌ្ឍស្អាត" ដែលមានបំណងជួយប្រទេសកំពុងអភិវឌ្ឍ ឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព និងជួយប្រទេសនៅក្នុងឧបសម្ព័ន្ធទី ១ ក្នុងការសម្រេចនូវកាតព្វកិច្ចកាត់បន្ថយការបញ្ចេញឧស្ម័នរបស់ខ្លួន។ បណ្តាគម្រោងនេះរួមមាន ១-គម្រោងលើកកម្ពស់ប្រសិទ្ធភាពថាមពល និងការសន្សំសំចៃថាមពលនៅក្នុងវិស័យឧស្សាហកម្ម ការដឹកជញ្ជូន ការផលិតថាមពល និងលំនៅស្ថាន ២-គម្រោងប្រើប្រាស់ថាមពលកើតឡើងវិញ (Renewable energy) ដូចជាពន្លឺព្រះអាទិត្យ ថាមពលខ្យល់ ថាមពលជីវម៉ាស (Biomass) ៣-គម្រោងស្តារព្រៃឈើ (Reforestation) និងដាំដើមឈើនៅតំបន់ថ្មីៗ (Afforestation) ។ល។

ប្រទេសលូតលាស់ជាច្រើន ដែលមានកាតព្វកិច្ចកាត់បន្ថយការបញ្ចេញឧស្ម័នរបស់ខ្លួន បានចាប់អារម្មណ៍ក្នុងការអនុវត្តគម្រោងក្រោម "យន្តការអភិវឌ្ឍស្អាត" នៅបណ្តាប្រទេសកំពុងអភិវឌ្ឍ ដូចជា ព្រះរាជាណាចក្រកម្ពុជាជាដើម ដោយហេតុថា ប្រទេសជឿនលឿនទាំងនោះ មានការលំបាកក្នុងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់នៅក្នុងប្រទេសគេផ្ទាល់ ពីព្រោះគេបានប្រើប្រាស់បច្ចេកវិទ្យាថ្មី និងទំនើបប្រកបដោយប្រសិទ្ធភាពខ្ពស់រួចទៅហើយ។ ប្រទេសកម្ពុជាត្រូវចូលជាសមាជិកនៃពិធីសារក្យូតូសិនមុននឹងមានសិទ្ធិទទួលនូវបណ្តាគម្រោងក្រោម "យន្តការអភិវឌ្ឍស្អាត" នេះ។

នៅក្នុងដំណើរការចរចាថ្នាក់អន្តរជាតិ ទាក់ទងនឹងពិធីសារនេះ សហរដ្ឋអាមេរិកបានប្រកាសថា ខ្លួនពុំមានបំណងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដូចដែលមានកំណត់ក្នុងពិធីសារក្យូតូទេ ដោយសំអាងទៅលើផលប៉ះពាល់ជាអវិជ្ជមាន ទៅលើកំណើនសេដ្ឋកិច្ច ទោះបីប្រទេសនេះបញ្ចេញឧស្ម័នកាបូនិចរហូតដល់ទៅ ២៥%នៃបរិមាណឧស្ម័នកាបូនិចបញ្ចេញសរុប លើពិភពលោកនៅពេលដែលចំនួនប្រជាពលរដ្ឋអាមេរិកមានតែប្រមាណ ៤,៥% នៃចំនួនប្រជាពលរដ្ឋនៅលើពិភពលោកក្តី។ សហរដ្ឋអាមេរិកបានទាមទារឱ្យដាក់បញ្ចូលព្រៃឈើ និងការគ្រប់គ្រងដីធ្លីទាំងអស់ជាអាងផ្ទុកកាបូន ដើម្បីរាប់បញ្ចូលក្នុងកាតព្វកិច្ចកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់របស់ខ្លួន។ ប្រទេសជប៉ុនដើមឡើយបានគាំទ្រជំហររបស់អាមេរិក តែក្រោយមកបានដកខ្លួនចេញ ដោយងាកមកគាំទ្រជំហររបស់សហគមន៍អឺរ៉ុប និងក្រុមប្រទេស G77 ចិនវិញ ដើម្បីជំរុញការអនុវត្តពិធីសារក្យូតូឱ្យបានឆាប់រហ័ស។ បណ្តាសមាជិកនៃអនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ ភាគច្រើនដូចជា សហគមន៍អឺរ៉ុប ជប៉ុន។ល។ បានអះអាងថា គេនឹងប្តេជ្ញាអនុវត្តការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ តាមរយៈពិធីសារក្យូតូ ដោយឈរលើស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការស្រោចស្រង់ភពផែនដីឱ្យជៀសផុតពីគ្រោះមហន្តរាយប្រែប្រួលអាកាសធាតុ។

ព្រះរាជាណាចក្រកម្ពុជាបានគាំទ្រយ៉ាងសកម្មដល់ការជំរុញអនុវត្តពិធីសារក្យូតូ ឱ្យបានឆាប់តាមដែលអាចធ្វើបាន ដូចដែលរាជរដ្ឋាភិបាលធ្លាប់បានបញ្ជាក់ នៅក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីបរិស្ថានប្រទេសអាស៊ាន នៅទីក្រុងភ្នំពេញកាលពីថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០១ ដែលបានបញ្ជាក់យ៉ាងច្បាស់ថា ក្នុងឋានៈជាសមាជិកនៃអនុសញ្ញាស្តីពី

ការប្រែប្រួលអាកាសធាតុ ព្រះរាជាណាចក្រកម្ពុជាគាំទ្រប្រទេសកំពុងអភិវឌ្ឍ ប្រទេសជប៉ុន និងសហគមន៍អឺរ៉ុប ក្នុងការជំរុញឱ្យចូលជាធរមាន នៃពិធីសារក្យូតូនេះ ។

ប្រទេសកម្ពុជាក៏បានគាំទ្រផងដែរក្នុងការដាក់បញ្ចូលព្រៃឈើថា ជាអាងផ្ទុកកាបូន ក្នុងគោលដៅកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ នៅក្រោមពិធីសារក្យូតូ ដែលជាការលើកទឹកចិត្តជំរុញឱ្យមានការថែរក្សាព្រៃឈើនៅលើពិភពលោក ដោយហេតុថា ព្រៃឈើពុំត្រឹមតែមាននាទីក្នុងការសម្អាតបរិយាកាសប៉ុណ្ណោះទេ ប៉ុន្តែវាផ្តល់ពហុប្រយោជន៍ច្រើនយ៉ាងផ្សេងទៀត ទាំងផ្នែកសេដ្ឋកិច្ច បរិស្ថាន ក៏ដូចជាការជួយសម្រាលគ្រោះធម្មជាតិនានា ដូចជាទឹកជំនន់ និងព្យុះ ជាដើម ។

សម្រាប់ព្រះរាជាណាចក្រកម្ពុជា ការចូលជាសមាជិករបស់ពិធីសារនេះ អាចនឹងនាំមកនូវសារប្រយោជន៍ច្រើនយ៉ាងដូចជា ៖

១-ក្នុងនាមជាសមាជិក នៃអនុសញ្ញាក្របខណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ ព្រះរាជាណាចក្រកម្ពុជា មានកាតព្វកិច្ចរួមចំណែកជាមួយសហគមន៍អន្តរជាតិ ក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ

២-ក្នុងនាមជាប្រទេសកំពុងអភិវឌ្ឍ ព្រះរាជាណាចក្រកម្ពុជា ពុំមានកាតព្វកិច្ចកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ទេ

៣-ក្នុងនាមជាប្រទេសកំពុងអភិវឌ្ឍ គេពុំតម្រូវឱ្យព្រះរាជាណាចក្រកម្ពុជាបង់ជាវិភាគទាន ឬចំណាយណាមួយឡើយ

៤-ផ្ទុយទៅវិញយើងនឹងទទួលផលចំណេញផ្នែកនយោបាយ៖

- បង្ហាញពីឆន្ទៈរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងការរួមចំណែកដោះស្រាយបញ្ហាបរិស្ថានជាមួយសហគមន៍អន្តរជាតិ
- លើកកម្ពស់កិត្យានុភាពជាតិ តាមរយៈការចូលរួមប្រជុំ ដែលរៀបចំឡើងសម្រាប់ពិភាក្សាដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ

៥-ទទួលផលចំណេញផ្នែកបរិស្ថាន៖

- រួមចំណែកដោះស្រាយបញ្ហាអាកាសធាតុមិនប្រក្រតីនៅកម្ពុជា ព្រោះអាកាសធាតុកម្ពុជាមិនអាចកាត់ផ្តាច់ពីអាកាសធាតុពិភពលោកបានឡើយ
- អាចទទួលបាននូវជំនួយពីប្រទេសអ្នកមាន ក៏ដូចជាអង្គការអន្តរជាតិនានាសម្រាប់យកមកទប់ស្កាត់ការបំពុលបរិយាកាសនៅទីក្រុង ការពារព្រៃឈើ ការគ្រប់គ្រងការប្រើប្រាស់ដីធ្លី រៀបចំផែនការបន្សាំ (Adaptation plan) ទៅនឹងការប្រែប្រួលអាកាសធាតុ ។ល។

៦-ទទួលបានផលចំណេញផ្នែកសេដ្ឋកិច្ច៖

- អាចចូលរួមក្នុងការអនុវត្តគម្រោង ក្រោមយន្តការអភិវឌ្ឍស្អាត ទាក់ទងនឹងការសន្សំសំចៃថាមពល ប្រសិទ្ធភាពថាមពល បច្ចេកវិជ្ជាផលិតកម្មស្អាត ដែលមិនបំផ្លាញបរិស្ថានក្នុងវិស័យឧស្សាហកម្ម ការអភិវឌ្ឍថាមពលកើតឡើងវិញ (Renewable energy) គម្រោងការពារ និងដាំព្រៃឈើ ការកែលម្អវិស័យគមនាគមន៍ ។ល។

-ទទួលការគាំទ្រផ្នែកស្រាវជ្រាវ និងសង្កេតតាមដានអាកាសធាតុដែលមានសារសំខាន់បំផុតសម្រាប់ប្រទេសកម្ពុជាដែលមានសេដ្ឋកិច្ចពឹងផ្អែកលើវិស័យកសិកម្ម

-ទទួលការគាំទ្រផ្នែកបណ្តុះបណ្តាលធនធានមនុស្ស ។

ជារួម ការចូលជាសមាជិកនៃពិធីសារនេះ ពុំបាននាំមកនូវផលវិបាកជាអវិជ្ជមានណាមួយដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមរបស់កម្ពុជាឡើយ ។ ផ្ទុយទៅវិញវា គឺជាឱកាសដ៏ល្អមួយដែលអនុញ្ញាតឱ្យព្រះរាជាណាចក្រកម្ពុជាទទួលបាននូវផលចំណេញលើគ្រប់វិស័យ ដូចបានរៀបរាប់ខាងលើ ដែលជាទុនយ៉ាងសំខាន់សម្រាប់រាជរដ្ឋាភិបាល អនុវត្តកម្មវិធីកាត់បន្ថយភាពក្រីក្រ ការពារបរិស្ថាន និងធនធានធម្មជាតិ ឆ្ពោះទៅសម្រេចបាននូវការអភិវឌ្ឍប្រទេសប្រកបដោយចីរភាពស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលអាណត្តិទី ៣នេះ ។

សេចក្តីដូចបានទូលថ្វាយ និងជម្រាបជូនខាងលើ សូមរដ្ឋសភាមេត្តាពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងពិធីសារក្យូតូនៃអនុសញ្ញាក្របខណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុនេះ ដោយអនុគ្រោះ ។

រាជធានីភ្នំពេញ ថ្ងៃទី ឆ្នាំ២០០៥

ហ៊ុន សែន

*បកប្រែក្រៅផ្លូវការ*

អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ
The United Nations Framework Convention on Climate Change

# ពិធីសារក្យូតូ

# THE KYOTO PROTOCOL

*បកប្រែក្រៅផ្លូវការ*

## សេចក្តីផ្តើម

នៅពេលរដ្ឋាភិបាលនៃប្រទេសនានាអនុម័តលើអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុក្នុងឆ្នាំ ១៩៩២ ពួកគេបានទទួលស្គាល់ថា អនុសញ្ញានេះអាចប្រើប្រាស់ជាមូលដ្ឋានសំរាប់ធ្វើសកម្មភាពឱ្យបានខ្លាំងក្លាទៅអនាគត ។ តាមរយៈការរៀបចំដំណើរការពិនិត្យឡើងវិញ ការពិភាក្សា និងការផ្លាស់ប្តូរពត៌មានជាប្រចាំ អនុសញ្ញានេះផ្តល់ជាមូលដ្ឋានសំរាប់អនុម័តលើការសន្យាបន្ថែម ដើម្បីឆ្លើយតបនឹងរាល់ការប្រែប្រួលចំណេះដឹងផ្នែកវិទ្យាសាស្ត្រ និងឆន្ទៈនយោបាយទៅអនាគត ។

ការពិនិត្យឡើងវិញជាលើកដំបូង អំពីប្រសិទ្ធិភាពអនុវត្តការសន្យារបស់បណ្តាប្រទេសអភិវឌ្ឍន៍ ត្រូវបានធ្វើឡើង តាមការស្នើសុំនៅក្នុងសម័យប្រជុំ ១ នៃសន្និសីទបណ្តាភាគី (COP-1) ដែលបានប្រព្រឹត្តទៅនៅទីក្រុងប៊ែរឡាំង នាឆ្នាំ ១៩៩៥ ។ បណ្តាភាគីបានសំរេចថាការសន្យារបស់បណ្តាប្រទេសអភិវឌ្ឍន៍ ដើម្បីព្យាយាមកាត់បន្ថយអេមីស្យុង (ឬការបញ្ចេញឧស្ម័ន) រហូតដល់ឆ្នាំ ២០០០ ឱ្យនៅត្រឹមកំរិតអេមីស្យុងឆ្នាំ ១៩៩០ ពុំទាន់គ្រប់គ្រាន់ ដើម្បីឈានទៅសំរេចគោលដៅរយៈពេលវែងនៃអនុសញ្ញានេះទេ គោលគឺការរាំងស្កាត់ "ឥទ្ធិពលប្រកបដោយគ្រោះថ្នាក់ បណ្តាលពីសកម្មភាពមនុស្សចំពោះប្រព័ន្ធអាកាសធាតុ" ។

បណ្តារដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់ដទៃទៀត បានឆ្លើយតបដោយអនុម័តយល់ព្រមលើ "អណត្តិទីក្រុងប៊ែរឡាំង" (Berlin Mandate) និងបង្កើតឱ្យមាន ការចរចាបន្ថែមទៀត ដើម្បីពង្រឹងកិច្ចអនុវត្តន៍ការសន្យាដោយបណ្តាប្រទេសអភិវឌ្ឍន៍ ។ គេបានបង្កើត *ក្រុមការងារបណ្តោះអាសន្ននៃអណត្តិទីក្រុងប៊ែរឡាំង* (Ad Hoc Group on Berlin Mandate) មួយ ដើម្បីធ្វើសេចក្តីព្រាងកិច្ចព្រមព្រៀងមួយ ។ ក្រោយពីបានប្រជុំចំនួនប្រាំបីលើក ក្រុមការងារនេះបានបញ្ជូនអត្ថបទព្រាងនៃកិច្ចព្រមព្រៀងនេះ ទៅសន្និសីទបណ្តាភាគីលើកទី ៣ (COP-3) ដើម្បីចរចាសំរេច ។

នៅក្នុងព្រឹត្តិការណ៍ដ៏អធិកអធមនាទីក្រុងក្យូតូ ប្រទេសជប៉ុន នាខែធ្នូ ឆ្នាំ ១៩៩៧ មានការចូលរួមពីសំណាក់បណ្តាប្រតិភូ អ្នកសង្កេតការណ៍ និងអ្នកសារព័តមាន ប្រមាណ ១០.០០០ នាក់ ។ សន្និសីទនេះបានឯកភាពមតិជាទូទៅលើសេក្តីសំរេច (1/CP.3) ដើម្បីអនុម័តពិធីសារមួយ ដែលនៅក្នុងនោះបណ្តាប្រទេសឧស្សាហកម្មជឿនលឿននឹងកាត់បន្ថយអេមីស្យុងឧស្ម័នផ្ទះកញ្ចក់សរុបយ៉ាងហោច ក្នុងកំរិត ៥% ធៀបនឹងអត្រាឆ្នាំ ១៩៩០ នៅក្នុងចន្លោះឆ្នាំ ២០០៨-២០១២ ខាងមុខ ។ ការសន្យាជាលក្ខណៈច្បាប់ (Legally binding commitment promises) នេះផ្តល់នូវក្តីសង្ឃឹមថា នឹងធ្វើឱ្យមានការត្រលប់បញ្ច្រាសជាប្រវត្តិសាស្ត្រនៃអេមីស្យុង ដែលបានបញ្ចេញចោលដោយបណ្តាប្រទេសទាំងនោះ តាំងពី ១៥០ ឆ្នាំមុន មកម្ល៉េះ ។

ការចុះហត្ថលេខាលើពិធីសារក្រុងក្យូតូបានចាប់ផ្តើមនៅថ្ងៃទី ១៦ ខែមីនា ឆ្នាំ ១៩៩៨ ។ ពិធីសារនេះនឹងចូលជាធរមាននៅរយៈពេល ៩០ ថ្ងៃ ក្រោយមានការឱ្យសច្ចាប័នដោយបណ្តាភាគីនៃអនុសញ្ញានេះយ៉ាងតិចចំនួន ៥៥ ដែលក្នុងនោះត្រូវមានបណ្តាប្រទេសអភិវឌ្ឍន៍ ដែលបានបញ្ចេញអេមីស្យុងឧស្ម័នកាបូនិចយ៉ាងហោចណាស់ ៥៥% នៃអេមីស្យុងសរុបនៅឆ្នាំ ១៩៩០ ក្នុងចំណោមបណ្តាប្រទេសឧស្សាហកម្មជឿនលឿនទាំងនេះ ។ នៅក្នុងចន្លោះពេលនោះ បណ្តាភាគីក្នុងអនុសញ្ញាការស្តីពីប្រែប្រួលអាកាសធាតុ ត្រូវបន្តអនុវត្តការសន្យារបស់ខ្លួន ក្នុងក្របខ័ណ្ឌនៃអនុសញ្ញានេះ និងត្រៀមខ្លួន ដើម្បីអនុវត្តខដែលមានចែងក្នុងពិធីសារនេះ ក្រោយពេលចូលជាធរមាន ។

*បកប្រែក្រៅផ្លូវការ*

## មាតិកា

*បណ្តាមាត្រាក្នុងពិធីសារក្រុងក្យូតូនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ពុំមានចំណងជើងជាប់ជាមួយទេ ។ ឈ្មោះចំណងជើងដែលមានចុះនៅខាងក្រោមគ្រាន់តែជាជំនួយចង្អុលបង្ហាញដល់បណ្តាអ្នកអានតែប៉ុណ្ណោះ តែមិនមែនជាចំណែកមួយនៃអត្ថបទដើមនោះទេ ដែលនឹងមានចាប់ពីទំព័រទី ៣ តទៅ ។*


បុព្វកថា

១. និយមន័យ

២. គោលនយោបាយ និងវិធានការ

៣. ការសន្យាកំហិត និងកាត់បន្ថយបរិមាណអេមីស្សុង (Quantified emission limitation and reduction commitments)

៤. កិច្ចអនុវត្តនៃការសន្យារួមគ្នា (Joint fulfillment of commitments)

៥. បញ្ហាវិធីសាស្ត្រ

៦. ការផ្ទេរ និងទទួលយកចំនួនឯកត្តាកាត់បន្ថយអេមីស្សុង (ការអនុវត្តន៍រួមគ្នា)

៧. ការធ្វើទំនាក់ទំនងពត៌មាន

៨. ការពិនិត្យពត៌មានឡើងវិញ

៩. ការពិនិត្យពិធីសារឡើងវិញ

១០. ការបន្តអនុវត្តការសន្យាដែលមានស្រាប់

១១. យន្តការហិរញ្ញវត្ថុ

១២. យន្តការអភិវឌ្ឍន៍ស្អាត (Clean Development Mechanism)

១៣. សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារ

១៤. លេខាធិការដ្ឋាន

១៥. អង្គភាពជំនួយការ (Subsidiary bodies)

១៦. ដំណើរការពិគ្រោះយោបល់ពហុភាគី

១៧. ពាណិជ្ជកម្មអេមីស្សុង (Emission trading)

១៨. ករណីខកខានមិនគោរពតាមពិធីសារ (Non-compliance)

១៩. ដំណោះស្រាយជំលោះ

២០. វិសោធនកម្ម

២១. ការអនុម័ត និងវិសោធនកម្មឧបសម្ព័ន្ធ

២២. សិទ្ធិបោះឆ្នោត

២៣. កន្លែងតំកល់ឯកសារ

២៤. ហត្ថលេខា ការផ្តល់សច្ចាប័ន ការទទួលយក ការអនុម័ត ឬការសុំចូលជាសមាជិក

២៥. ការចូលជាធរមាន

២៦. ករណីលើកលែង (Reservations)

២៧. ការសុំលាលែង

២៨. អត្ថបទសំណៅដើម

ឧបសម្ព័ន្ធ ក : ឧស្ម័នផ្ទះកញ្ចក់ និងយថាប្រភេទវិស័យ/ប្រភព

ឧបសម្ព័ន្ធ ខ : ការសន្យាកំហិត និងកាត់បន្ថយបរិមាណអេមីស្សុង (Quantified emission limitation or reduction commitments) ដោយបណ្តាភាគី


Comment: Signature and Ratification, Acceptance, Approval or Accession

*តារាងដែលមានភ្ជាប់ និងសេចក្តីសំរេចរបស់សន្និសីទបណ្តាភាគី មិនមែនជាផ្នែកមួយនៃពិធីសារក្រុងក្យូតូទេ ប៉ុន្តែត្រូវបានដាក់បញ្ចូលនៅទីនេះ ដោយសារវាផ្តល់ពត៌មានពាក់ព័ន្ធនឹងការអនុម័ត និងអនុវត្តន៍ពិធីសារនេះ ។*


សេចក្តីសំរេច 1/CP.3 : ការអនុម័តពិធីសារក្រុងក្យូតូនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ

សេចក្តីសំរេច 2/CP.3 : បញ្ហាវិធីសាស្ត្រទាក់ទងនឹងពិធីសារក្រុងក្យូតូ

សេចក្តីសំរេច 3/CP.3 : ការអនុវត្តន៍មាត្រា ៤ វាក្យខ័ណ្ឌ ៨ និង ៩ នៃអនុសញ្ញា

តារាង : អេមីស្សុងឧស្ម័នកាបូនិចសរុបក្នុងឆ្នាំ ១៩៩០ នៃបណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ សំរាប់គោលបំណងមាត្រា ២៥ នៃពិធីសារក្រុងក្យូតូ ។

*បកប្រែក្រៅផ្លូវការ*

## ពិធីសារក្រុងក្យូតូ នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ

**បណ្តាប្រទេសជាភាគីក្នុងពិធីសារនេះ**

ក្នុងនាមជាភាគីក្នុងអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ចាប់ពីពេលនេះតទៅហៅកាត់ថា "អនុសញ្ញា" ។

ដើម្បីបំពេញនូវគោលបំណងចំបងនៃអនុសញ្ញានេះ ដូចមានចែងក្នុងមាត្រា ២ ។

បានឃើញខដែលមានចែងនៅក្នុងអនុសញ្ញានេះ ។

ដោយអនុវត្តតាមមាត្រា ៣ នៃអនុសញ្ញានេះ ។

អនុលោមតាមអាណត្តិទីក្រុងប៊ែរឡាំង ដែលបានអនុម័តតាមសេចក្តីសំរេច 1/CP.1 នៃសន្និសីទបណ្តាភាគីក្នុងអនុសញ្ញានេះ នៅក្នុងសម័យប្រជុំលើកទី ១ ។

**បានឯកភាពដូចតទៅ :**

### មាត្រា ១

និយមន័យដែលមានចែងក្នុងមាត្រា ១ នៃអនុសញ្ញានេះនឹងត្រូវអនុវត្តសំរាប់គោលដៅនៃពិធីសារនេះ ។

១. "សន្និសីទបណ្តាភាគី" គឺសន្និសីទនៃបណ្តាប្រទេសជាភាគីក្នុងអនុសញ្ញានេះ ។

២. "អនុសញ្ញា" គឺអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដែលបានអនុម័តនៅទីក្រុងញូវយ៉ក នៅថ្ងៃទី ៩ ខែឧសភា ឆ្នាំ ១៩៩២ ។

៣. "ក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកកិច្ចការប្រែប្រួលអាកាសធាតុ" (Intergovernmental Panel on Climate Change: IPCC) គឺក្រុមការងារអន្តររដ្ឋាភិបាល ទទួលបន្ទុកការងារទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងដែលបានបង្កើតឡើងរួមគ្នានៅឆ្នាំ ១៩៨៨ ដោយអង្គការឧតុនិយមពិភពលោក និងកម្មវិធីបរិស្ថានសហប្រជាជាតិ ។

៤. "ពិធីសារក្រុងម៉ុងរ៉េអាល់" គឺពិធីសារទីក្រុងម៉ុងត្រេអាល់ស្តីពីសារធាតុដែលបំផ្លាញស្រទាប់អូសូន និងដែលបានអនុម័តនៅទីក្រុងម៉ុងរ៉េអាល់ កាលពីថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ១៩៨៧ និងក្រោយមកបានកែសំរួល និងធ្វើវិសោធនកម្ម ។

៥. "ភាគីមានវត្តមាន និងបានបោះឆ្នោត" គឺបណ្តាភាគីដែលមានវត្តមាន និងដែលបានបោះឆ្នោតគាំទ្រ ឬជំទាស់ ។

៦. "បណ្តាភាគី" គឺបណ្តាភាគីក្នុងពិធីសារនេះ លើកលែងតែមានការបញ្ជាក់បន្ថែម ។

៧. "ភាគីក្នុងឧបសម្ព័ន្ធ ១" គឺភាគីដែលបានបញ្ចូលទៅក្នុងឧបសម្ព័ន្ធ ១ នៃអនុសញ្ញា ដែលអាចត្រូវធ្វើវិសោធនកម្ម ឬភាគីដែលបានធ្វើសេចក្តីជូនដំណឹង ដូចមានចែងក្នុងមាត្រា ៤ វាក្យខ័ណ្ឌ ២ (ឆ) នៃអនុសញ្ញានេះ ។

### មាត្រា ២

១. ក្នុងដំណើរអនុវត្តការសន្យាកំហិត និងកាត់បន្ថយបរិមាណអេមីស្យុង ដូចមានចែងក្នុងមាត្រា ៣ ដែលជាចំណែកមួយជំរុញការអភិវឌ្ឍន៍ដោយចីរភាព ភាគីនីមួយៗក្នុងឧបសម្ព័ន្ធ ១ ត្រូវ :

ក) អនុវត្ត និង/ឬចែងលំអិតបន្ថែមអំពីគោលនយោបាយ និងវិធានការស្របតាមកាលៈទេសៈក្នុងប្រទេស ដូចជា :

(i) បង្កើនប្រសិទ្ធិភាពនៃការប្រើប្រាស់ថាមពលនៅតាមស្ថាប័នពាក់ព័ន្ធក្នុងសេដ្ឋកិច្ចជាតិ ។

(ii) ការពារ និងធ្វើឱ្យប្រសើរឡើងនូវអាងស្រូប (sinks) និងអាងផ្ទុក (reservoirs) ឧស្ម័នផ្ទះកញ្ចក់ ដែលពុំមានចែងក្នុងពិធីសារក្រុងម៉ុងរ៉េអាល់ ដោយគិតទាំងការសន្យារបស់ប្រទេសទាំងនោះ ដូចមានចែងនៅក្នុងបណ្តាកិច្ចព្រមព្រៀងអន្តរជាតិ ពាក់ព័ន្ធនឹងបរិស្ថាន ព្រមទាំងជំរុញការគ្រប់គ្រងព្រៃឈើដោយនិរន្តភាព ការដាំព្រៃឈើ (afforestation) និងស្តារព្រៃឈើឡើងវិញ (reforestation) ។

(iii) ជំរុញរបៀបធ្វើកសិកម្មឱ្យមាននិរន្តភាព ដោយពិចារណាអំពីការប្រែប្រួលអាកាសធាតុ ។

(iv) ស្រាវជ្រាវ ជំរុញការអភិវឌ្ឍន៍ និងបង្កើនការប្រើប្រាស់ប្រភេទថាមពលថ្មី និងដែលអាចកើតឡើងវិញបាន (new and renewable forms of energy) បច្ចេកវិទ្យាស្រូបយកឧស្ម័នកាបូនិច ព្រមទាំងបច្ចេកវិទ្យាទំនើប និងថ្មីដែលមិនប៉ះពាល់ដល់បរិស្ថាន ។

*បកប្រែក្រៅផ្លូវការ*

(v) កាត់បន្ថយជាលំដាប់ ឬលុបបំបាត់ជាបណ្ដើរៗនូវអសុក្រិតភាពនៃទីផ្សារ (market imperfection) ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ ការលើកលែងពន្ធអាករ និងការជួយឧបត្ថម្ភ សំរាប់វិស័យណា ដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់តាមទិន្នាការផ្ទុយពីគោលបំណងនៃអនុសញ្ញានេះ និងការប្រើប្រាស់វិធានការទីផ្សារ ។

Comment: Fiscal Incentives

Comment: Subsidy

Comment: Market instrument

(vi) លើកទឹកចិត្តឱ្យមានការកែទំរង់សមស្របនៅតាមវិស័យពាក់ព័ន្ធ សំដៅជំរុញការអនុវត្តន៍គោលនយោបាយ និង វិធានការកំហិត ឬកាត់បន្ថយអេមីស្យុងឧស្ម័នផ្ទះកញ្ចក់ ដែលពុំមានចែងក្នុងពិធីសារក្រុងម៉ុងរ៉េអាល់ ។

(vii) វិធានការកំហិត និង/ឬកាត់បន្ថយអេមីស្យុងឧស្ម័នផ្ទះកញ្ចក់ ដែលពុំមានចែងនៅក្នុងពិធីសារទីក្រុងម៉ុងរ៉េអាល់ ក្នុងវិស័យដឹកជញ្ជូន ។

(viii) កំហិត និង/ឬកាត់បន្ថយអេមីស្យុងឧស្ម័នមេតាន តាមរយៈការទាញយកមកប្រើវិញ (recovery) និងប្រើប្រាស់វាក្នុងផ្នែកគ្រប់គ្រងសំណល់ ក៏ដូចជានៅក្នុងផលិតកម្ម ការដឹកជញ្ជូន និងការចែកចាយថាមពល ។

ខ) ធ្វើសហប្រតិបត្តិការជាមួយភាគីនានាផ្សេងទៀត ដើម្បីបង្កើនប្រសិទ្ធិភាពគោលនយោបាយ និងវិធានការក្នុងប្រទេសរៀងខ្លួន និងរួមគ្នា ដែលបានអនុម័ត ដូចមានចែងក្នុងមាត្រានេះ និងអនុលោមតាមមាត្រា ៤ វាក្យខ័ណ្ឌ ២ (ង) (ឈ) នៃអនុសញ្ញានេះ ។ ត្រង់ចំនុចនេះ ភាគីទាំងនេះត្រូវចាត់វិធានការដើម្បីចែករំលែកបទពិសោធន៍ និងផ្លាស់ប្ដូរព័ត៌មានអំពីគោលនយោបាយ និងវិធានការទាំងនោះ រួមទាំងបង្កើតវិធីកែលំអរបៀបប្រៀបធៀប តំលាភាព និងប្រសិទ្ធិភាព ។ នៅក្នុងសម័យប្រជុំលើកទីមួយរបស់ខ្លួន ឬក្នុងករណីបន្ទាន់ តាមតែអាចធ្វើបាន នៅពេលក្រោយមក សន្និសីទបណ្ដាភាគីសំរាប់ការប្រជុំនៃបណ្ដាភាគីក្នុងពិធីសារនេះ ត្រូវពិចារណាកវិធីសំរួលកិច្ចសហប្រតិបត្តិការបែបនេះ ដោយផ្អែកលើព័ត៌មានពាក់ព័ន្ធទាំងអស់ ។

២. ភាគីក្នុងឧបសម្ព័ន្ធ ១ ត្រូវព្យាយាមអនុវត្តកំហិត និងការកាត់បន្ថយអេមីស្យុងឧស្ម័នផ្ទះកញ្ចក់ ដែលពុំមានចែងនៅក្នុងពិធីសារក្រុងម៉ុងរ៉េអាល់ ពីសកម្មភាពអាកាសចរ និងនាវាដឹកប្រេងតាមសមុទ្រ ដោយត្រូវធ្វើការតាមរយៈអង្គការអាកាសចរស៊ីវិលអន្តរជាតិ និងអង្គការសមុទ្រអន្តរជាតិ (International Maritime Organisation) ។

៣. ភាគីក្នុងឧបសម្ព័ន្ធ ១ ត្រូវប្រឹងប្រែងអនុវត្តគោលនយោបាយ និងវិធានការដែលចែងក្នុងមាត្រានេះ ទៅតាមវិធីដែលកាត់បន្ថយផលអវិជ្ជមានបណ្ដាលពីការប្រែប្រួលអាកាសធាតុ ផលប៉ះពាល់ចំពោះពាណិជ្ជកម្មអន្តរជាតិ និងចំពោះទិដ្ឋភាពសង្គម បរិស្ថាន និងសេដ្ឋកិច្ច ទៅលើបណ្ដាភាគីដទៃទៀត ពិសេសភាគីជាបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ និងដែលមានចែងនៅក្នុងមាត្រា ៤ វាក្យខ័ណ្ឌ ៨ និង ៩ នៃអនុសញ្ញា ព្រមទាំងត្រូវផ្អែកលើមាត្រា ៣ នៃអនុសញ្ញានេះ ។ ក្នុងករណីសមស្រប សន្និសីទបណ្ដាភាគីសំរាប់ការប្រជុំនៃបណ្ដាភាគីក្នុងពិធីសារនេះ អាចចាត់វិធានការបន្ថែមទៀត ដើម្បីជំរុញការអនុវត្តន៍ ដែលមានចែងក្នុងវាក្យខ័ណ្ឌនេះ ។

៤. ប្រសិនបើមានការកំនត់ថា ការសំរបសំរួលគោលនយោបាយ និងវិធានការណាមួយក្នុងវាក្យខ័ណ្ឌ ១ (ក) ខាងលើអាចផ្ដល់ផលប្រយោជន៍ ដោយពិចារណាផងដែរពីលក្ខខ័ណ្ឌ និងផលដែលអាចកើតមានខុសគ្នាចំពោះប្រទេសនីមួយៗ សន្និសីទបណ្ដាភាគីសំរាប់ការប្រជុំនៃបណ្ដាភាគីក្នុងពិធីសារនេះ ត្រូវពិចារណាកវិធី និងមធ្យោបាយ ដើម្បីចែងឱ្យបានលំអិតអំពីការសំរបសំរួលគោលនយោបាយ និងវិធានការទាំងនោះ ។

## មាត្រា ៣

១. បណ្ដាភាគីក្នុងឧបសម្ព័ន្ធ ១ ត្រូវធានារៀងៗខ្លួន និងរួមគ្នាថា បរិមាណសរុបនៃឧស្ម័នកាបូនិចកើតពីសកម្មភាពមនុស្ស សមមូលនឹងអេមីស្យុងនៃបណ្ដាឧស្ម័នផ្ទះកញ្ចក់ចែងក្នុងឧបសម្ព័ន្ធ A មិនលើសពីបរិមាណកំនត់ (assigned amounts) របស់ភាគីទាំងនោះ ដែលគណនាអនុលោមតាមការសន្យាកំហិត និងកាត់បន្ថយបរិមាណអេមីស្យុងចែងក្នុងឧបសម្ព័ន្ធ B និងអនុលោមតាមខ ដែលមានក្នុងមាត្រានេះ ដោយត្រូវផ្អែកលើគោលដៅកាត់បន្ថយបរិមាណអេមីស្យុងសរុបនៃឧស្ម័នទាំងនោះ ឱ្យបានយ៉ាងហោចណាស់ ៥% នៅក្រោមកំរិតអេមីស្យុងឆ្នាំ ១៩៩០ នៅក្នុងចន្លោះពេលសន្យា ឆ្នាំ ២០០៨-២០១២ ។

២. រហូតដល់ឆ្នាំ ២០០៥ ភាគីក្នុងឧបសម្ព័ន្ធ ១ ត្រូវបង្ហាញឱ្យឃើញនូវភាពរីកចំរើនក្នុងកិច្ចអនុវត្តន៍ការសន្យារបស់ខ្លួនតាមពិធីសារនេះ ។

៣. ការប្រែប្រួលសុទ្ធនៃអេមីស្យុងឧស្ម័នផ្ទះកញ្ចក់ពីប្រភពផ្សេងៗ និងការស្រូបយកតាមរយៈអាងស្រូបកាបូន បណ្ដាលពីសកម្មភាពមនុស្សដោយផ្ទាល់ ដូចជាការផ្លាស់ប្ដូររបៀបប្រើប្រាស់ដី និងព្រៃឈើ ដែលកើតពីការដាំព្រៃឈើ ការស្ដារព្រៃឈើ និងការបាត់បង់ព្រៃឈើ តាំងពីឆ្នាំ ១៩៩០ រហូតមក អាចចាត់ទុកជាការប្រែប្រួលសន្និធិកាបូន ដែលអាចផ្ទៀងផ្ទាត់បាន នៅក្នុងរយៈពេលនៃការសន្យា ហើយនឹងត្រូវប្រើប្រាស់សំរាប់ផ្ទៀងផ្ទាត់ប្រសិទ្ធិភាពអនុវត្តការសន្យា ដែលចែងក្នុងមាត្រានេះសំរាប់ភាគីនីមួយៗ ក្នុងឧបសម្ព័ន្ធ ១ ។ ត្រូវធ្វើសេចក្ដីរាយការណ៍ និងពិនិត្យឡើងវិញ តាមទំរង់ដែលមានតំលាភាព និងដែលអាចផ្ទៀងផ្ទាត់បាន នូវអេមីស្យុងឧស្ម័នផ្ទះកញ្ចក់ពីប្រភពផ្សេងៗ និងការស្រូបយកតាមរយៈអាងស្រូវកាបូនបណ្ដាលពីសកម្មភាពពាក់ព័ន្ធទាំងនោះ អនុលោមតាមមាត្រា ៧ និង ៨ ។

៤. ដើម្បីជាមូលដ្ឋានសំរាប់ការពិចារណារបស់អង្គភាពជំនួយការផ្តល់យោបល់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា មុនពេលបើកសម័យប្រជុំទី ១ នៃសន្និសីទបណ្តាភាគី សំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ភាគីនីមួយៗក្នុងឧបសម្ព័ន្ធ ១ ត្រូវផ្តល់ទិន្នន័យសំរាប់រៀបចំកំនត់ កំរិតសន្និធិកាបូនឆ្នាំ ១៩៩០ និងសំរាប់ផ្តល់លទ្ធភាពប៉ាន់ប្រមាណអំពីការប្រែប្រួលសន្និធិកាបូន សំរាប់បណ្តាឆ្នាំបន្តបន្ទាប់ទៀត ។ នៅក្នុងសម័យប្រជុំលើកទី ១ ឬក្នុងករណីបន្ទាន់នាមតែអាចធ្វើបាននៅពេលក្រោយមកទៀត សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវសំរេចកំនត់បណ្តាសកម្មភាពបន្ថែមទៀតបង្កដោយមនុស្ស ពាក់ព័ន្ធនឹងការប្រែប្រួលអេមីស្យុងឧស្ម័នផ្ទះកញ្ចក់ពីប្រភពផ្សេងៗ និងការចាប់យកតាមរយៈអាងស្រូបកាបូន នៅក្នុងវិស័យកសិកម្ម និងក្នុងការផ្លាស់ប្តូររបៀបប្រើប្រាស់ដី និងព្រៃឈើ ដោយផ្អែកលើ វិធី បទបញ្ញា និងគោលការណ៍ណែនាំ ដើម្បីដាក់បញ្ចូលបន្ថែម ឬកាត់ចេញពីបញ្ជីបរិមាណកំណត់សំរាប់បណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ ដោយគិតទាំងភាពមិនប្រាកដប្រជា តំលាភាពក្នុងសេចក្តីរាយការណ៍ ភាពអាចផ្ទៀងផ្ទាត់បាន វិធីសាស្ត្រស្រាវជ្រាវ របស់ក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកកិច្ចការប្រែប្រួលបរិយាកាស បណ្តាសេចក្តីណែនាំពីអង្គភាពជំនួយការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ស្របតាមមាត្រា ៥ និងសេចក្តីសំរេចនៃសន្និសីទបណ្តាភាគី ។ សេចក្តីសំរេចបែបនេះនឹង ត្រូវអនុវត្តនៅដំណាក់កាលទី ២ ឬដំណាក់កាលបន្ទាប់ទៀតនៃការសន្យា ។ ភាគីនីមួយៗអាចមានជំរើសដើម្បីអនុវត្តសេចក្តីសំរេចបែបនេះ ដើម្បីគ្រប់គ្រងសកម្មភាពបន្ថែមបង្កដោយមនុស្ស នៅក្នុងដំនាក់កាលទី ១ នៃការសន្យាអនុវត្ត ប្រសិនបើសកម្មភាពទាំងនោះបានចាប់ផ្តើម មានតាំងតែពីឆ្នាំ ១៩៩០ មក ។

Comment: Modalities

៥. បណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ ដែលជាប្រទេសក្នុងសេដ្ឋកិច្ចអន្តរកាល និងដែលមានឆ្នាំ ឬចន្លោះពេលមូលដ្ឋាន (base year or period) ត្រូវបានកំនត់ អនុលោមតាមសេចក្តីសំរេច 9/CP.2 នៃសន្និសីទបណ្តាភាគីនៅក្នុងសម័យប្រជុំលើកទី ២ របស់ខ្លួន ត្រូវប្រើឆ្នាំឬចន្លោះពេលមូលដ្ឋាននោះ ដើម្បីអនុវត្តការសន្យារបស់ខ្លួនទៅតាមមាត្រានេះ ។ បណ្តាភាគីណាមួយផ្សេងទៀតក្នុងឧបសម្ព័ន្ធ ១ ដែលស្ថិតក្នុងសេដ្ឋកិច្ចអន្តរកាល តែពុំបានដាក់ជូនរបាយការណ៍ជាតិ តាមមាត្រា ១២ នៃអនុសញ្ញា ក៏អាចធ្វើសេចក្តីជូនដំណឹងទៅសន្និសីទបណ្តាភាគី សំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះថា ប្រទេសទាំងនោះមានបំណងប្រកាន់យកឆ្នាំ ឬចន្លោះពេលមូលដ្ឋានផ្សេងពីឆ្នាំ ១៩៩០ សំរាប់អនុវត្តការសន្យារបស់គេតាមមាត្រានេះ ។ សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវធ្វើសេចក្តីសំរេចអនុម័តលើសេចក្តីជូនដំណឹងបែបនេះ ។

៦. ដោយយោងតាមមាត្រា ៤ វាក្យខ័ណ្ឌ ៦ នៃអនុសញ្ញានេះ សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវអនុញ្ញាតឱ្យមានការអនុគ្រោះមួយចំនួនដល់បណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ ដែលជាប្រទេសស្ថិតក្នុងសេដ្ឋកិច្ចអន្តរកាល ក្នុងកិច្ចអនុវត្តការសន្យារបស់ខ្លួនតាមមាត្រានានាក្នុងពិធីសារនេះ លើកលែងតែមាត្រានេះចេញ ។

៧. នៅក្នុងដំនាក់កាលទី ១ នៃកិច្ចអនុវត្តន៍ការសន្យាកំហិត និងកាត់បន្ថយអេមីស្យុងឆ្នាំ ២០០៨-២០១២ បរិមាណកំនត់សំរាប់ភាគីនីមួយៗ ក្នុងឧបសម្ព័ន្ធ ១ ត្រូវតែស្មើនឹងភាគរយនៃអេមីស្យុងឧស្ម័នកាបូនិចសរុប បណ្តាលពីសកម្មភាពមនុស្ស ដែលមានចែងក្នុងឧបសម្ព័ន្ធ ក សមមូលនឹងអេមីស្យុងឧស្ម័នផ្ទះកញ្ចក់ចែងក្នុងឧបសម្ព័ន្ធ ក ក្នុងឆ្នាំ ១៩៩០ ឬ ឆ្នាំឬចន្លោះពេលមូលដ្ឋាន កំនត់តាមវាក្យខ័ណ្ឌ៥ខាងលើ ដោយគុណនឹង ៥ ។ បណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ ដែលមានសកម្មភាពបង្កឱ្យប្រែប្រួលការប្រើប្រាស់ដី និងព្រៃឈើ បង្កើតជាប្រភពសុទ្ធនៃអេមីស្យុងឧស្ម័នផ្ទះកញ្ចក់ក្នុងឆ្នាំ ១៩៩០ ត្រូវបញ្ចូលទៅក្នុងឆ្នាំ ឬចន្លោះពេលមូលដ្ឋានអេមីស្យុងឆ្នាំ ១៩៩០ របស់ខ្លួន នូវឧស្ម័នកាបូនិចសរុបបណ្តាលពីសកម្មភាពមនុស្ស សមមូលនឹងបណ្តាអេមីស្យុងសរុបតាមបណ្តាប្រភពនានា ដកនឹងបរិមាណស្រូបយកតាមរយៈអាងស្រូបកាបូនក្នុងឆ្នាំ ១៩៩០ បណ្តាលពីសកម្មភាពប្រែប្រួលក្នុងការប្រើប្រាស់ដី សំរាប់ធ្វើជាមូលដ្ឋាននៃការគណនាបរិមាណកំនត់ (assigned amount) ។

៨. ភាគីនីមួយៗក្នុងឧបសម្ព័ន្ធ ១ អាចប្រកាន់យកឆ្នាំ ១៩៩៥ ជាឆ្នាំមូលដ្ឋាន សំរាប់ការគណនាឧស្ម័នអ៊ីដ្រូភ្លុយអរ៉ូកាបូន ឧស្ម័នពែរភ្លុយអរ៉ូកាបូន និងឧស្ម័នស៊ុលភួអិចសាភ្លុយអរីត យោងតាមវាក្យខ័ណ្ឌ ៧ ខាងលើ ។

៩. ការសន្យាសំរាប់ដំណាក់កាលបន្ទាប់សំរាប់បណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ ត្រូវកំនត់តាមវិសោធនកម្មលើឧបសម្ព័ន្ធ ខ ក្នុងពិធីសារនេះ ដែលនឹងត្រូវអនុម័តអនុលោមតាមបណ្តាខចែងក្នុងមាត្រា ២១ វាក្យខ័ណ្ឌ ៧ ។ សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវពិចារណាលើការសន្យាបែបនេះ នៅក្នុងកំឡុងពេលយ៉ាងយោចណាស់ ៧ ឆ្នាំ មុនពេលចុងបញ្ចប់នៃដំណាក់កាលសន្យាទី ១ ដែលមានយោងនៅក្នុងវាក្យខ័ណ្ឌ ១ ខាងលើ ។

១០. ចំនួនឯកត្តានៃអេមីស្យុងត្រូវកាត់បន្ថយ (emission reduction units) ឬចំណែកមួយនៃបរិមាណកំនត់ ដែលភាគីមួយទទួលយកពីភាគីមួយផ្សេងទៀត អនុលោមតាមខដែលមានចែងក្នុងមាត្រា ៦ ឬមាត្រា ១៧ ត្រូវបូកបន្ថែមជាមួយបរិមាណកំនត់សំរាប់ភាគីដែលជាអ្នកទទួលយកនោះ ។

១១. ចំនួនឯកត្តានៃអេមីស្យុងត្រូវកាត់បន្ថយ ឬចំណែកណាមួយនៃបរិមាណកំនត់ ដែលភាគីមួយផ្ទេរទៅឱ្យភាគីមួយផ្សេងទៀត អនុលោមតាមខដែលមានចែងក្នុងមាត្រា ៦ ឬមាត្រា ១៧ ត្រូវតែកាត់ចេញពីបរិមាណកំនត់សំរាប់ភាគីជាអ្នកផ្ទេរនោះ ។

១២. ការកាត់បន្ថយណាមួយនៃអេមីស្យុងដែលបានបញ្ជាក់ថាត្រឹមត្រូវ ដែលភាគីណាមួយទទួលបានពីភាគីមួយផ្សេងទៀត អនុលោមតាមបណ្តាខចែងក្នុងមាត្រា ១២ ត្រូវបូកបន្ថែមជាមួយបរិមាណកំនត់សំរាប់កាត់បន្ថយរបស់ភាគីទទួលយកនោះ ។

១៣. បើនៅក្នុងដំណាក់កាលនៃការសន្យា អេមីស្យុងនៃភាគីណាមួយក្នុងឧបសម្ព័ន្ធ ១ មានបរិមាណតិចជាងបរិមាណកំនត់តាមមាត្រានេះ ភាគីនោះអាចធ្វើសេចក្តីស្នើដើម្បីដាក់បរិមាណខុសគ្នានេះទៅក្នុងបរិមាណកំនត់របស់ភាគីនោះ សំរាប់ដំនាក់កាលបន្ទាប់នៃការសន្យា ។

១៤. ភាគីនីមួយៗក្នុងឧបសម្ព័ន្ធ ១ត្រូវប្រឹងប្រែងអនុវត្តការសន្យាចែងក្នុងវាក្យខ័ណ ១ ខាងលើ តាមរបៀបដែលកាត់បន្ថយផលប៉ះពាល់ចំពោះសង្គម បរិស្ថាន និងសេដ្ឋកិច្ចរបស់ភាគីជាប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសផលប៉ះពាល់ដែលមានចែងក្នុងមាត្រា ៤ វាក្យខ័ណ្ឌ ៨ និង ៩ នៃអនុសញ្ញា ។ ស្របគ្នានឹងសេចក្តីសំរេចមួយចំនួននៃសន្និសីទបណ្តាភាគី ពាក់ព័ន្ធនឹងការអនុវត្តវាក្យខ័ណ្ឌទាំងនោះ នៅក្នុងសម័យប្រជុំលើកទី ១ របស់ខ្លួន សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវពិចារណាបណ្តាសកម្មភាព ចាំបាច់សំរាប់ កាត់បន្ថយផលប៉ះពាល់បណ្តាលពីការប្រែប្រួលអាកាសធាតុ និង/ឬផលប៉ះពាល់បណ្តាលពីវិធានការនានា ទៅលើបណ្តាភាគីដែលមានចែងក្នុងបណ្តាវាក្យខ័ណ្ឌទាំងនោះ ។ ក្នុងចំនោមបញ្ហាដែលត្រូវពិចារណាត្រូវមាន ការបង្កើតមូលនិធិ ការធានារ៉ាប់រង និងការផ្ទេរបច្ចេកវិទ្យា ។

## មាត្រា ៤

១. បណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ ដែលមានចុះកិច្ចព្រមព្រៀងបំពេញការសន្យារបស់ខ្លួនរួមគ្នាតាមមាត្រា ៣ ត្រូវតែចាត់ទុកថាបានបំពេញការសន្យាតែក្នុងករណីណា ដែលបរិមាណឧស្ម័នកាបូនិចសរុបបណ្តាលពីសកម្មភាពមនុស្សសមមូលនឹងអេមីស្យុងនៃបណ្តាឧស្ម័នផ្ទះកញ្ចក់ ចែងក្នុងឧបសម្ព័ន្ធ A មានមិនលើសពីបរិមាណកំនត់ដែលគណនាអនុលោមតាមការសន្យាកំហិត និងការកាត់បន្ថយអេមីស្យុងរបស់ប្រទេសក្នុងកិច្ចព្រមព្រៀងនោះ ដែលមានចែងក្នុងឧបសម្ព័ន្ធ B និងដោយអនុលោមតាមខ ដែលមានក្នុងមាត្រា ៣ ។ កំរិតអេមីស្យុង សំរាប់បណ្តាភាគីក្នុងកិច្ចព្រមព្រៀងទាំងនោះ ត្រូវតែមានចែងនៅក្នុងកិច្ចព្រមព្រៀងនោះ ។

២. បណ្តាភាគីក្នុងកិច្ចព្រមព្រៀងបែបនេះ ត្រូវធ្វើសេចក្តីជូនដំណឹងទៅលេខាធិការដ្ឋាន អំពីលក្ខខណ្ឌនៃកិច្ចព្រមព្រៀង នៅថ្ងៃដែលដាក់តំកល់លិខិតូបករណ៍ផ្តល់សច្ចាប័ន ឯកសារទទួលស្គាល់ អនុម័ត ឬសុំចូលជាសមាជិកពិធីសារនេះ ។ លេខាធិការដ្ឋានត្រូវធ្វើសេចក្តីជូនដំនឹង ឆ្លើយតបទៅបណ្តាភាគី និងហត្ថលេខីក្នុងអនុសញ្ញានេះ អំពីលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនោះ ។

៣. កិច្ចព្រមព្រៀងបែបនេះណាមួយត្រូវស្ថិតនៅជាធរមានសំរាប់ដំណាក់កាលមួយនៃការសន្យាដូចមានចែងក្នុងមាត្រា ៣ វាក្យខ័ណ្ឌ ៧ ។

៤. ប្រសិនបើបណ្តាភាគីធ្វើសកម្មភាពបែបនេះរួមគ្នា ក្នុងក្របខ័ណ្ឌនៃ និងជាមួយអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ រាល់ការកែប្រែណាមួយនៅក្នុងរចនាសម្ព័ន្ធរបស់អង្គការនេះ ក្រោយពីអនុម័តពិធីសារនេះ នឹងមិនប៉ះពាល់ដល់ការសន្យាដែលមានស្រាប់ក្នុងក្របខ័ណ្ឌនៃពិធីសារនេះទេ ។ រាល់ការកែប្រែណាមួយនៅក្នុងរចនាសម្ព័ន្ធរបស់អង្គការនេះ នឹងមានអនុភាពសំរាប់តែបណ្តាការសន្យាតាមមាត្រា ៣ ដែលបានអនុម័តក្រោយពេលមានការកែប្រែនោះ ។

៥. ក្នុងករណីដែលបណ្តាភាគីក្នុងកិច្ចព្រមព្រៀងមិនអាចសំរេចបាននូវការកាត់បន្ថយអេមីស្យុងសរុបរបស់ខ្លួនតាមការកំនត់ ភាគីនីមួយៗក្នុងកិច្ចព្រមព្រៀងនោះ ត្រូវទទួលខុសត្រូវរៀងៗខ្លួនចំពោះចំណែកអេមីស្យុងរបស់ខ្លួនដែលបានចែងនៅក្នុងកិច្ចព្រមព្រៀងនោះ ។

៦. ប្រសិនបើបណ្តាភាគីធ្វើសកម្មភាពបែបនេះរួមគ្នាក្នុងក្របខ័ណ្ឌ និងជាមួយអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ដែលអង្គការនោះក៏ជាភាគីក្នុងពិធីសារនេះដែរ រដ្ឋនីមួយៗជាសមាជិកនៃអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់នោះ ត្រូវធ្វើសកម្មភាពរៀងខ្លួន និងជាមួយអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ដោយអនុលោមតាមមាត្រា ២៤ និងក្នុងករណីមិនអាចសំរេចបាននូវការកាត់បន្ថយកំរិតអេមីស្យុងសរុប ត្រូវទទួលខុសត្រូវចំពោះចំណែកអេមីស្យុងរបស់ខ្លួន ដូចដែលមានចែងក្នុងមាត្រានេះ ។

## មាត្រា ៥

១. ភាគីនីមួយៗក្នុងឧបសម្ព័ន្ធ ១ ត្រូវមានរួចជាស្រេចនូវប្រព័ន្ធសំរាប់ប្រទេសខ្លួន ដើម្បីប៉ាន់ប្រមាណអេមីស្យុងបណ្តាលពីសកម្មភាពមនុស្សពីប្រភពផ្សេងៗ និងការចាប់យកតាមរយៈអាងស្រូបកាបូននៃឧស្ម័នផ្ទះកញ្ចក់គ្រប់ប្រភេទ ដែលពុំមានចែងក្នុងពិធីសារក្រុងម៉ុងរ៉េអាល់ ឱ្យបានយ៉ាងយឺតបំផុតក្នុងរយៈពេលមួយឆ្នាំ មុនពេលចាប់ផ្តើមដំនាក់កាលទីមួយនៃការសន្យា ។ គោលការណ៍ណែនាំសំរាប់ប្រព័ន្ធជាតិបែបនេះ ដែលមានរួមបញ្ចូលវិធីសាស្ត្រចែងក្នុងវាក្យខ័ណ្ឌ ២ ខាងក្រោម ត្រូវតែមានការសំរេចទទួលស្គាល់ដោយសន្និសីទបណ្តាភាគី សំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ នៅក្នុងសម័យប្រជុំទី ១ របស់ខ្លួន ។

២. វិធីសាស្ត្រប៉ាន់ប្រមាណអេមីស្យុងបណ្តាលពីសកម្មភាពមនុស្សពីប្រភពនានា និងការចាប់យកតាមរយៈការស្រូបឧស្ម័នផ្ទះកញ្ចក់គ្រប់ប្រភេទ ដែលពុំមានក្នុងពិធីសារក្រុងម៉ុងរ៉េអាល់ ត្រូវតែជាវិធីសាស្ត្រ ដែលមានការទទួលស្គាល់ដោយក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកកិច្ចការប្រែប្រួលអាកាសធាតុ និងមានការឯកភាពដោយសន្និសីទបណ្តាភាគីក្នុងសម័យប្រជុំទី ៣ របស់ខ្លួន ។ ក្នុងករណីដែលមិនមានប្រើប្រាស់វិធីសាស្ត្រខាងលើ គេត្រូវធ្វើការកែតំរូវសមស្រប អនុលោមតាមវិធីសាស្ត្រដែលមានការឯកភាពដោយ

*បកប្រែក្រៅផ្លូវការ*

សន្និសីទភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះនៅក្នុងសម័យប្រជុំលើកទី ១ របស់ខ្លួន ។ ផ្អែកលើមូលដ្ឋាននៃការងាររបស់ក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកកិច្ចការប្រែប្រួលអាកាសធាតុ និងយោបល់វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាពីអង្គភាពជំនួយការសន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវពិនិត្យ និងក្នុងករណីសមស្រប ត្រូវកែសំរួលជាទៀងទាត់នូវវិធីសាស្ត្រ និងកំណែតំរូវ ដោយផ្អែកលើរាល់សេចក្តីសំរេចពាក់ព័ន្ធរបស់សន្និសីទបណ្តាភាគី ។ រាល់ការកែសំរួលវិធីសាស្ត្រ និងកំណែតំរូវ ត្រូវធ្វើតែក្នុងករណី ដើម្បីផ្ទៀងផ្ទាត់រវាងប្រសិទ្ធិភាពអនុវត្តការសន្យាតាមមាត្រា ៣ សំរាប់ចន្លោះពេលនៃការសន្យា ក្រោយពីមានការកែសំរួល ។

៣. សក្តានុពលនៃកំនើនកំដៅពិភពលោក (global warming potentials) ដែលប្រើប្រាស់សំរាប់គណនាឧស្ម័នកាបូនិច សមមូលនឹងអេមីស្យុងដោយសកម្មភាពមនុស្សពីបណ្តាប្រភពផ្សេងៗ និងការចាប់យកតាមរយៈការស្រូបបណ្តាឧស្ម័នផ្ទះកញ្ចក់ចែងក្នុងឧបសម្ព័ន្ធ A ត្រូវតែជាបណ្តាសក្តានុពល ដែលមានការទទួលស្គាល់ដោយក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកកិច្ចការប្រែប្រួលអាកាសធាតុ និងឯកភាពដោយសន្និសីទបណ្តាភាគ ក្នុងសម័យប្រជុំទី ៣ របស់ខ្លួន ។ ផ្អែកលើមូលដ្ឋាននៃការងាររបស់ក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកកិច្ចការប្រែប្រួលអាកាសធាតុ ព្រមទាំងយោបល់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ពីអង្គភាពជំនួយការ សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះត្រូវពិនិត្យ និងក្នុងករណីសមស្រប ត្រូវកែសំរួលសក្តានុពលកំនើនកំដៅពិភពលោកនៃឧស្ម័នផ្ទះកញ្ចក់បែបនោះ ដោយផ្អែកលើគ្រប់សេចក្តីសំរេចពាក់ព័ន្ធរបស់សន្និសីទបណ្តាភាគី ។ រាល់ការកែសំរួលសក្តានុពលកំនើនកំដៅពិភពលោក ត្រូវធ្វើតែនៅក្នុងករណី ដើម្បីផ្ទៀងផ្ទាត់រវាងប្រសិទ្ធិភាពអនុវត្តការសន្យាតាមមាត្រា ៣ សំរាប់ចន្លោះពេលនៃការសន្យាក្រោយពីមានការកែសំរួល ។

## មាត្រា ៦

១. ដើម្បីបំពេញការសន្យាតាមមាត្រា ៣ រាល់ភាគីក្នុងឧបសម្ព័ន្ធ ១ អាចផ្ទេរ ឬទទួលយកពីភាគីមួយផ្សេងទៀត នូវចំនួនឯកត្តាណាមួយនៃអេមីស្យុងដែលត្រូវកាត់បន្ថយ តាមរយៈគំរោងការដែលមានគោលដៅកាត់បន្ថយអេមីស្យុងពីសកម្មភាពមនុស្សពីប្រភពនានា ឬបង្កើនការចាប់យកតាមរយៈអាងស្រូបឧស្ម័នផ្ទះកញ្ចក់នៅក្នុងវិស័យសេដ្ឋកិច្ច តែនៅក្នុងករណីដែល :

(ក) គំរោងការបែបនោះទទួលការឯកភាពពីបណ្តាភាគីពាក់ព័ន្ធ

(ខ) គំរោងការបែបនេះផ្តល់នូវការកាត់បន្ថយអេមីស្យុងពីប្រភពនានា ឬបង្កើនការចាប់យកតាមរយៈអាងស្រូបកាបូន បន្ថែមពីលើបណ្តាគំរោងធម្មតាដែលអាចនឹងអនុវត្ត

(គ) ពុំទទួលយកចំនួនឯកត្តាណាមួយនៃអេមីស្យុងដែលត្រូវកាត់បន្ថយ ប្រសិនបើវាពុំគោរពតាមកាតព្វកិច្ចចែងក្នុងមាត្រា ៥ និង ៧

(ឃ) ការទទួលយកចំនួនឯកត្តាណាមួយនៃអេមីស្យុងដែលត្រូវកាត់បន្ថយ ត្រូវតែជាការបន្ថែមលើសកម្មភាពក្នុងប្រទេស ដើម្បីបំពេញការសន្យាចែងក្នុងមាត្រា ៣ ។

២. នៅក្នុងសម័យប្រជុំលើកទី ១ របស់ខ្លួន ឬក្នុងពេលបន្ទាន់តាមតែអាចធ្វើបាននៅពេលក្រោយមកទៀត សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ អាចធ្វើការចែងឱ្យបានលំអិតបន្ថែមសំរាប់អនុវត្តមាត្រានេះ រួមទាំងដើម្បីផ្ទៀងផ្ទាត់ និងដើម្បីធ្វើសេក្តីរាយការណ៍ ។

៣. ភាគីណាមួយក្នុងឧបសម្ព័ន្ធ ១ ក្រោមការទទួលខុសត្រូវរបស់ខ្លួន អាចផ្តល់សិទ្ធិដល់អង្គភាពស្របច្បាប់មួយចំនួនដើម្បីចូលរួមក្នុងសកម្មភាពឈានទៅបង្កើត ផ្ទេរ ឬទទួលយកចំនួនឯកត្តាណាមួយនៃអេមីស្យុងដែលត្រូវកាត់បន្ថយ តាមមាត្រានេះ ។

៤. ប្រសិនបើមានសំនួរមួយចំនួនពាក់ព័ន្ធនឹងការអនុវត្តន៍របស់ភាគីណាមួយក្នុងឧបសម្ព័ន្ធ ១ ស្តីពីតំរូវការដែលមានយោងក្នុងមាត្រានេះ ត្រូវបានធ្វើអត្តសញ្ញាណអនុលោមទៅតាមខពាក់ព័ន្ធក្នុងមាត្រា ៨ ការផ្ទេរ ឬទទួលយកចំនួនឯកត្តាណាមួយនៃអេមីស្យុងដែលត្រូវកាត់បន្ថយ អាចត្រូវបន្តបានក្រោយពេលដែលសំនួរនោះត្រូវបានធ្វើអត្តសញ្ញាណ និងក្នុងករណីដែលចំនួនឯកត្តាណាមួយខាងលើមិនមានប្រើប្រាស់ដោយភាគីណាមួយ ដើម្បីបំពេញការសន្យារបស់ខ្លួនតាមមាត្រាពរហូតដល់បានដោះស្រាយបញ្ហាទាំងនោះរួចរាល់ ។

## មាត្រា ៧

១. ភាគីក្នុងឧបសម្ព័ន្ធ ១ ត្រូវដាក់បញ្ចូលនៅក្នុងរបាយការណ៍សារពើភ័ណ្ឌប្រចាំឆ្នាំរបស់ខ្លួន អំពីអេមីស្យុងដោយសកម្មភាពមនុស្សពីប្រភពនានា និងការចាប់យកដោយអាងស្រូបកាបូននៃឧស្ម័នផ្ទះកញ្ចក់ ដែលពុំមានចែងក្នុងពិធីសារក្រុងម៉ុងរ៉េអាល់ និងដែលត្រូវដាក់ជូន អនុលោមតាមគ្រប់សេចក្តីសំរេចនៃសន្និសីទបណ្តាភាគី នូវបណ្តាព័ត៌មានបន្ថែមចាំបាច់ដើម្បីបញ្ជាក់ពី កិច្ចអនុវត្តន៍ការសន្យាចែងក្នុងមាត្រា ៣ សំរាប់ការធ្វើសេចក្តីសំរេចអនុលោមតាមវាក្យខ័ណ្ឌ ៤ ខាងក្រោម ។

*បកប្រែក្រៅផ្លូវការ*

២. ភាគីនីមួយៗក្នុងឧបសម្ព័ន្ធ ១ ត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ជាតិប្រចាំឆ្នាំរបស់ខ្លួន ដែលត្រូវដាក់ជូនអនុលោមតាមមាត្រា ១២ នៃអនុសញ្ញានេះ នូវព័ត៌មានបន្ថែមចាំបាច់ ដើម្បីបញ្ជាក់ពីលទ្ធផលនៃកិច្ចអនុវត្តន៍ការសន្យាតាមពិធីសារនេះ សំរាប់ការធ្វើសេចក្តីសំរេចអនុលោមតាមវាក្យខ័ណ្ឌ ៤ ខាងក្រោម ។

៣. ភាគីនីមួយៗក្នុងឧបសម្ព័ន្ធ ១ ត្រូវដាក់ជូនប្រចាំឆ្នាំនូវពត៌មានតាមការចែងក្នុងវាក្យខ័ណ្ឌ ១ ខាងលើ ដោយចាប់ផ្តើមពីរបាយការណ៍សារពើភ័ណ្ឌលើកទី ១ ដែលជាប្រការចាំបាច់នៅក្នុងក្របខ័ណ្ឌនៃអនុសញ្ញា សំរាប់ដំនាក់កាលទី ១ នៃការសន្យា ក្រោយពីពិធីសារនេះចូលជាធរមានសំរាប់ភាគីនោះ ។ ភាគីនោះត្រូវដាក់ជូននូវពត៌មានចាំបាច់តាមវាក្យខ័ណ្ឌ ២ ខាងលើ ជាចំណែកមួយនៃរបាយការណ៍ជាតិដំបូង ដែលជាប្រការចាំបាច់នៅក្នុងក្របខ័ណ្ឌនៃអនុសញ្ញានេះ ក្រោយពេលពិធីសារនេះចូលជាធរមានសំរាប់ភាគីនោះ និងក្រោយពីមានការអនុម័តឯកភាពលើគោលការណ៍ ដែលមានចែងក្នុងវាក្យខ័ណ្ឌ ៤ ខាងក្រោម ។ សន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះត្រូវកំនត់ពីចន្លោះពេលដែលត្រូវដាក់ជូននូវរបាយការណ៍ចាំបាច់តាមមាត្រានេះ ដោយត្រូវគិតផងដែរអំពីកាលបរិច្ឆេទនៃការដាក់ជូនរបាយការណ៍ជាតិ ដែលត្រូវកំនត់ដោយសន្និសីទបណ្តាភាគី ។

៤. ក្នុងសម័យប្រជុំទី ១ របស់ខ្លួន សន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវអនុម័ត និងត្រូវពិនិត្យឡើងវិញជាប្រចាំនៅពេលក្រោយ នូវគោលការណ៍សំរាប់រៀបចំពត៌មានចាំបាច់តាមមាត្រានេះ ដោយគិតទាំងគោលការណ៍សំរាប់រៀបចំរបាយការណ៍ជាតិរបស់បណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ តាមការអនុម័តដោយសន្និសីទបណ្តាភាគី ។ មុនដំនាក់កាលទី ១ នៃការសន្យា សន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ក៏ត្រូវធ្វើសេចក្តីសំរេចអំពីវិធីសំរាប់ធ្វើការគណនាបរិមាណកំនត់ ។

## មាត្រា ៨

១. ពត៌មានដែលដាក់ជូនតាមមាត្រា ៧ ដោយភាគីនីមួយៗក្នុងឧបសម្ព័ន្ធ ១ ត្រូវទទួលការពិនិត្យវាយតំលៃដោយក្រុមជំនាញការអនុលោមតាមសេចក្តីសំរេចនៃសន្និសីទបណ្តាភាគី និងយោងតាមគោលការណ៍អនុម័តដោយសន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ តាមវាក្យខ័ណ្ឌ ៤ ខាងក្រោម ។ ពត៌មានដាក់ជូនតាមមាត្រា ៧ វាក្យខ័ណ្ឌ ១ ដោយភាគីក្នុងឧបសម្ព័ន្ធ ១ នឹងត្រូវពិនិត្យឡើងវិញ ជាចំណែកមួយនៃការប្រមូលផ្តុំ និងផ្ទៀងផ្ទាត់លើការធ្វើសារពើភ័ណ្ឌអេមីស្យុង និងបរិមាណកំនត់ ។ លើសពីនេះ ពត៌មាន ដែលដាក់ជូនតាមមាត្រា ៧ វាក្យខ័ណ្ឌ ២ ដោយភាគីក្នុងឧបសម្ព័ន្ធ ១ នឹងត្រូវពិនិត្យឡើងវិញ ជាចំណែកមួយនៃការពិនិត្យរបាយការណ៍ ។

២. លេខធិការដ្ឋានត្រូវសំរបសំរួលជាមួយក្រុមជំនាញការ ដែលជ្រើសរើសចេញពីបណ្តាជំនាញការចាត់តាំងដោយបណ្តាភាគីក្នុងអនុសញ្ញានេះ និងដោយអង្គការអន្តររដ្ឋាភិបាលយោងតាមការណែនាំពីសំណាក់សន្និសីទបណ្តាភាគី ។

៣. ដំណើរការពិនិត្យឡើងវិញត្រូវតែជាការវាយតំលៃបច្ចេកទេសម៉ត់ចត់ និងល្អិតល្អន់លើគ្រប់ទិដ្ឋភាពនៃការប្រតិបត្តិរបស់បណ្តាភាគីក្នុងពិធីសារនេះ ។ ក្រុមជំនាញការត្រូវរៀបចំរបាយការណ៍ទៅសន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ដោយវាយតំលៃកិច្ចអនុវត្តន៍ការសន្យានៃភាគីនិមួយៗ និងធ្វើអត្តសញ្ញាណបញ្ហាក្នុងការអនុវត្តន៍ និងកត្តាជះឥទ្ធិពលដល់ការអនុវត្តន៍ ។ លេខាធិការដ្ឋានត្រូវចែករបាយការណ៍បែបនេះឱ្យដល់គ្រប់បណ្តាភាគីក្នុងអនុសញ្ញានេះ ។ លេខាធិការដ្ឋានត្រូវធ្វើបញ្ជីសំនួរពាក់ព័ន្ធនឹងការប្រតិបត្តិដែលមានបញ្ជាក់ក្នុងរបាយការណ៍បែបនេះ សំរាប់ការពិចារណាបន្ថែមទៀតពីសំណាក់សន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ។

៤. ក្នុងសម័យប្រជុំទី ១ របស់ខ្លួន សន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ តាមរយៈក្រុមជំនាញការ ត្រូវអនុម័ត និងពិនិត្យឡើងវិញជាទៀតទាត់នៅពេលក្រោយបន្ទាប់មកទៀត នូវគោលការណ៍សំរាប់ពិនិត្យឡើងវិញការប្រតិបត្តិតាមពិធីសារនេះ ដោយផ្អែកលើគ្រប់សេចក្តីសំរេចរបស់សន្និសីទបណ្តាភាគី ។

៥. ដោយមានជំនួយពីអង្គភាពជំនួយការអនុវត្ត (Subsidiary Body on Implementation) និងក្នុងករណីសមស្របពីអង្គភាពជំនួយការផ្តល់យោបល់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (Subsidiary Body on Scientific and Technological Advice) សន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះត្រូវពិចារណា :

(ក) ពត៌មានដែលដាក់ជូនដោយបណ្តាភាគីតាមមាត្រា៧ និងរបាយការណ៍ពីក្រុមជំនាញការធ្វើឡើងតាមមាត្រានេះ ។

(ខ) បណ្តាសំនួរពាក់ព័ន្ធនឹងការអនុវត្តន៍ដែលស្រង់ជាបញ្ជីដោយលេខាធិការដ្ឋានតាមវាក្យខ័ណ្ឌ៣ខាងលើ ក៏ដូចជាបណ្តាសំនួរលើកឡើងដោយភាគី ។

៦. អនុលោមតាមការពិចារណារបស់ខ្លួនអំពីពត៌មានដែលយោងក្នុងវាក្យខ័ណ្ឌ ៥ ខាងលើ សន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះត្រូវធ្វើសេចក្តីសំរេចលើបញ្ហាចាំបាច់ណាមួយសំរាប់អនុវត្តពិធីសារនេះ ។

*បកប្រែក្រៅផ្លូវការ*

## មាត្រា ៩

១. សន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះត្រូវពិនិត្យពិធីសារនេះឡើងវិញជាទៀងទាត់ ដោយផ្អែកលើពត៌មាន និងការវាយតំលៃវិទ្យាសាស្ត្រអំពីការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់របស់វា ក៏ដូចជាពត៌មានពាក់ព័ន្ធនឹងបច្ចេកទេស សង្គម និងសេដ្ឋកិច្ច ។ ការពិនិត្យឡើងវិញបែបនេះត្រូវតែមានការសំរបសំរួលជាមួយការពិនិត្យឡើងដែលពាក់ព័ន្ធក្នុងក្របខ័ណ្ឌនៃអនុសញ្ញា ជាពិសេសការពិនិត្យឡើងវិញដូចមានចែងក្នុងមាត្រា ៤ វាក្យខ័ណ្ឌ ២ (ឃ) និងមាត្រា ៧ វាក្យខ័ណ្ឌ ២ (ក) នៃអនុសញ្ញា ។ ផ្អែកលើការពិនិត្យឡើងវិញទាំងនេះ សន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវចាត់វិធានការសមស្រប ។

២. ការពិនិត្យឡើងវិញលើកទី ១ ត្រូវធ្វើនៅក្នុងសម័យប្រជុំលើកទី ២ នៃសន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ។ ការពិនិត្យឡើងវិញលើកក្រោយទៀត ត្រូវធ្វើជាទៀងទាត់នៅចន្លោះពេល និងតាមកាលវេលាកំនត់ ។

## មាត្រា ១០

ដោយយោងតាមការទទួលខុសត្រូវរួម និងខុសៗគ្នារបស់ខ្លួន តាមគោលបំណង កាលៈទេសៈ និងអាទិភាពអភិវឌ្ឍន៍ជាក់លាក់សំរាប់ជាតិ និងប្រចាំតំបន់របស់ខ្លួន និងដោយពុំមានការដាក់បញ្ចូលបន្ថែមនូវការសន្យាថ្មីណាមួយសំរាប់បណ្តាភាគីពុំមានក្នុងឧបសម្ព័ន្ធ ១ ប៉ុន្តែដោយអះអាងជាថ្មីឡើងវិញនូវការសន្យាដែលមានស្រាប់តាមមាត្រា ៤ វាក្យខ័ណ្ឌ ១ អំពីការសន្យាដើម្បីសំរេចការអភិវឌ្ឍន៍ដោយចិរភាព និងដោយយោងតាមមាត្រា ៤ វាក្យខ័ណ្ឌ ៥ និង ៧ បណ្តាភាគីក្នុងអនុសញ្ញានេះត្រូវ :

ក) ក្នុងករណីដែលពាក់ព័ន្ធ និងតាមការដែលអាចធ្វើបាន រៀបចំកម្មវិធីដែលមានប្រសិទ្ធិភាពសេដ្ឋកិច្ចសំរាប់ជាតិ និងក្នុងករណីសមស្រប រៀបចំកម្មវិធីសំរាប់តំបន់ ដើម្បីកែលំអគុណភាពកត្តាអេមីស្យុងនៅក្នុងមូលដ្ឋាន ទិន្នន័យពីសកម្មភាព និង/ឬបណ្តាគំរូដែលឆ្លុះបញ្ចាំងលក្ខខណ្ឌសេដ្ឋកិច្ចសង្គមនៃភាគីនីមួយៗ ដើម្បីរៀបចំនិងកែតំរូវជាទៀងទាត់ឱ្យទាន់សភាពការណ៍នូវសារពើភ័ណ្ឌជាតិនៃអេមីស្យុងដោយសកម្មភាពមនុស្សតាមប្រភពផ្សេងៗ និងការចាប់យកតាមរយៈអាងស្រូបឧស្ម័នផ្ទះកញ្ចក់ទាំងអស់ ដែលពុំមានចែងក្នុងពិធីសារក្រុងម៉ុងរ៉េអាល់ ដោយប្រើប្រាស់វិធីសាស្ត្រដែលអាចប្រៀបធៀបបាន និងដែលមានការអនុម័តដោយសន្និសីទបណ្តាភាគី ព្រមទាំងស្របគ្នាជាមួយគោលការណ៍សំរាប់រៀបចំរបាយការណ៍ជាតិ ដែលមានការអនុម័តដោយសន្និសីទបណ្តាភាគី ។

ខ) រៀបចំ អនុវត្ត បោះពុម្ពផ្សាយ និងកែតំរូវជាទៀងទាត់ឱ្យទាន់សភាពការណ៍ នូវកម្មវិធីជាតិ និងក្នុងករណីសមស្រប ត្រូវធ្វើដូចគ្នាសំរាប់តំបន់ នូវកម្មវិធីដែលមានដាក់បញ្ចូលវិធានការដើម្បីសំរាលការប្រែប្រួលអាកាសធាតុ និងបណ្តាវិធានការសំរួលសំរាប់ឱ្យមានបន្សាំបានសមស្រប ទៅនឹងការប្រែប្រួលអាកាសធាតុ ។

(i) កម្មវិធីបែបនេះដែលពាក់ព័ន្ធនឹងវិស័យថាមពល ដឹកជញ្ជូន និងឧស្សាហកម្ម ក៏ដូចជាវិស័យកសិកម្ម ព្រៃឈើ និងការគ្រប់គ្រងសំណល់ ។ លើសពីនេះ បច្ចេកវិទ្យា និងវិធីសាស្ត្របន្សាំសំរាប់កែលំអ ការរៀបចំផែនការ នឹងជួយធ្វើឱ្យប្រសើរឡើងនូវភាពស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ ។

(ii) ភាគីក្នុងឧបសម្ព័ន្ធ ១ ត្រូវដាក់ជូនពត៌មានស្តីពីសកម្មភាពក្នុងក្របខ័ណ្ឌនៃពិធីសារនេះ រួមទាំងកម្មវិធីជាតិ អនុលោមតាមមាត្រា ៧ និងក្នុងករណីសមស្រប បណ្តាភាគីដទៃទៀតត្រូវព្យាយាមដាក់បញ្ចូលក្នុងរបាយការណ៍ជាតិរបស់ខ្លួននូវពត៌មានស្តីពីកម្មវិធីដែលមានរួមបញ្ចូលវិធានការ ដែលបណ្តាភាគីជឿថា អាចរួមចំណែកដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់របស់វា រួមទាំងការកាត់បន្ថយកំនើនអេមីស្យុងឧស្ម័នផ្ទះកញ្ចក់ និងបង្កើនការចាប់យកតាមរយៈអាងស្រូបកាបូន ការកសាងសមត្ថភាពបច្ចេកទេស និងវិធានការបន្សាំ ។

គ) សហការក្នុងការជំរុញបង្កើតវិធីប្រកបដោយប្រសិទ្ធិភាពសំរាប់អភិវឌ្ឍ អនុវត្ត និងផ្សព្វផ្សាយ ព្រមទាំងចាត់រាល់វិធានការដែលអាចធ្វើបាន ដើម្បីជំរុញ សំរួល និងក្នុងករណីសមស្រប ផ្តល់ហិរញ្ញវត្ថុ ផ្ទេរបច្ចេកវិទ្យា ឬលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាសមស្របនឹងលក្ខខណ្ឌបរិស្ថាន ជំនាញ បទពិសោធន៍ និងដំណើរការពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ជាពិសេសសំរាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ រួមទាំងការរៀបចំគោលនយោបាយ និងកម្មវិធីសំរាប់ការផ្ទេរដោយមានប្រសិទ្ធិភាពនូវបច្ចេកវិទ្យាសមស្របនឹងលក្ខខណ្ឌបរិស្ថាន ដែលជាកម្មសិទ្ធិសាធារណៈ ឬក្នុងការងារវិស័យសាធារណៈ និងបង្កើតលក្ខខណ្ឌបរិស្ថានសមស្របសំរាប់ការវិនិយោគឯកជន ជំរុញ និងបង្កើនការផ្ទេរ និងលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាសមស្របនឹងស្ថានភាពបរិស្ថាន ។

Comment: Diffusion

ឃ) សហការស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកទេស និងជំរុញការថែទាំ និងបង្កើតប្រព័ន្ធសង្កេតការណ៍យថាភាព និងបង្កើតបណ្ណសារដ្ឋានទិន្នន័យ ដើម្បីកាត់បន្ថយស្ថានភាពមិនប្រាកដប្រជាពាក់ព័ន្ធនឹងប្រព័ន្ធអាកាសធាតុ ផលប៉ះពាល់បណ្តាលពីការប្រែប្រួលអាកាសធាតុ និងផលវិបាកផ្នែកសេដ្ឋកិច្ច និងសង្គម នៃយុទ្ធសាស្ត្រទប់ទល់ ព្រមទាំងជំរុញការអភិវឌ្ឍន៍ និងពង្រឹង

*បកប្រែក្រៅផ្លូវការ*

សមត្ថភាព និងលទ្ធភាព ដើម្បីចូលរួមក្នុងកិច្ចប្រឹងប្រែងអន្តរជាតិ និងអន្តររដ្ឋាភិបាល កម្មវិធី និងបណ្តាញស្រាវជ្រាវ និងសង្កេតការណ៍យថាភាព ដោយយោងតាមមាត្រា ៥ នៃអនុសញ្ញានេះ ។

ង) សហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ និងក្នុងករណីសមស្រប ជំរុញការប្រើប្រាស់បណ្តាអង្គការដែលមានស្រាប់ ដើម្បីបង្កើត និងអនុវត្តកម្មវិធីអប់រំ និងបណ្តុះបណ្តាល រួមទាំងពង្រឹងសមត្ថភាពស្ថាប័នជាតិ ជាពិសេសសមត្ថភាពមន្ត្រី និងស្ថាប័ន និងការផ្លាស់ប្តូរ ឬជួលបុគ្គលិកឱ្យទៅបណ្តុះបណ្តាលជំនាញផ្សេងៗ ជាពិសេសសំរាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងសំរបសំរួលបង្កើនការយល់ដឹងនៅកំរិតជាតិ និងបង្កើតលទ្ធភាពប្រើប្រាស់ព័ត៌មានពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ។ គួរបង្កើតគំរូម៉ូដែលសមស្របសំរាប់អនុវត្តសកម្មភាពទាំងនេះ តាមរយៈអង្គការដែលធ្វើការពាក់ព័ន្ធនឹងអនុសញ្ញានេះ ដោយយោងតាមមាត្រា ៦ នៃអនុសញ្ញា ។

ច) ដាក់បញ្ចូលទៅក្នុងរបាយការណ៍ជាតិរបស់ខ្លួន នូវព័ត៌មានស្តីពីកម្មវិធី និងសកម្មភាពដែលបានអនុវត្តអនុលោមតាមមាត្រានេះ ដោយយោងតាមសេចក្តីសំរេចពាក់ព័ន្ធនានានៃសន្និសីទបណ្តាភាគី ។

ឆ) ក្នុងពេលអនុវត្តការសន្យាតាមមាត្រានេះ ត្រូវយកចិត្តទុកដាក់ពិចារណាមាត្រា ៤ វាក្យខ័ណ្ឌ ៨ នៃអនុសញ្ញានេះ ។

## មាត្រា ១១

១. ក្នុងពេលអនុវត្តមាត្រា ១០ បណ្តាភាគីត្រូវយកចិត្តទុកដាក់ចំពោះខទាំងឡាយនៃមាត្រា ៤ វាក្យខ័ណ្ឌ ៤ ៥ ៧ ៨ និង ៩ នៃអនុសញ្ញា។

២. ក្នុងក្របខ័ណ្ឌនៃការអនុវត្តមាត្រា ៤ វាក្យខ័ណ្ឌ ១ នៃអនុសញ្ញា ដោយអនុលោមតាមខទាំងឡាយនៃមាត្រា ៤ វាក្យខ័ណ្ឌ ៣ និងមាត្រា ១១ នៃអនុសញ្ញានេះ និងតាមរយៈអង្គការ ឬបណ្តាអង្គការទទួលបន្ទុកយន្តការប្រតិបត្តិ និងហិរញ្ញវត្ថុនៃអនុសញ្ញា ភាគីបណ្តាប្រទេសឧស្សាហកម្មជឿនលឿន និងបណ្តាភាគីមានការលួតលាស់ដទៃទៀតក្នុងឧបសម្ព័ន្ធ ២ នៃអនុសញ្ញា ត្រូវ :

(ក) ផ្តល់ធនធានហិរញ្ញវត្ថុថ្មី និងបន្ថែមសំរាប់បំពេញថ្លៃចំណាយដែលបានឯកភាព និងដែលចាយដោយបណ្តាភាគីនៃប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីជួយឧបត្ថម្ភកិច្ចអនុវត្តការសន្យាដែលមានស្រាប់តាមមាត្រា ៤ វាក្យខ័ណ្ឌ ១ (ក) នៃអនុសញ្ញា ដែលមានចែងក្នុងមាត្រា ១០ វាក្យខ័ណ្ឌរង (ក) ។

(ខ) អនុលោមតាមមាត្រានោះ ផ្តល់ផងដែរនូវធនធានហិរញ្ញវត្ថុបែបនេះសំរាប់ការផ្ទេរបច្ចេកវិទ្យាចាំបាច់សំរាប់ភាគីប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីបំពេញទាំងស្រុងនូវការចំណាយបន្ថែម (incremental costs) ដែលមានការឯកភាព សំរាប់ជួយឧបត្ថម្ភកិច្ចអនុវត្តការសន្យាដែលមានស្រាប់តាមមាត្រ ៤ វាក្យខ័ណ្ឌ ១នៃអនុសញ្ញានេះ និងដែលមានចែងក្នុងមាត្រា ១០ ព្រមទាំងមានការឯកភាពរវាងភាគីប្រទេសកំពុងអភិវឌ្ឍន៍ និងអង្គការ ឬបណ្តាអង្គការអន្តរជាតិ ដែលមានយោងក្នុងមាត្រា ១១នៃអនុសញ្ញា ។

កិច្ចអនុវត្តការសន្យាដែលមានស្រាប់ទាំងនោះ ត្រូវគិតផងដែរអំពីសេចក្តីត្រូវការពិនិត្យមើលលក្ខណៈគ្រប់គ្រាន់ និងការព្យាករណ៍ចរាចរ មូលនិធិ និងសារៈសំខាន់នៃបន្ទុកសមស្របរំលែកដោយបណ្តាភាគីប្រទេសមានឧស្សាហកម្មជឿនលឿន។ ការណែនាំចំពោះអង្គការ ឬបណ្តា អង្គការទទួលបន្ទុកប្រតិបត្តិយន្តការហិរញ្ញវត្ថុនៃអនុសញ្ញានេះ ដែលពាក់ព័ន្ធនឹងដោយក្តីសំរេចនានានៃសន្និសីទបណ្តាភាគី រួមទាំងបណ្តាសេចក្តីសំរេចដែលមានការឯកភាពរួចមកហើយមុនពេលអនុម័តពិធីសារនេះ នឹងត្រូវអនុវត្តឱ្យបានសមស្របតាមការប្រែប្រួលនៅក្នុងបណ្តាប្រការនានាក្នុងមាត្រានេះដែរ ។

៣. បណ្តាភាគីនៃប្រទេសឧស្សាហកម្មជឿនលឿន និងបណ្តាភាគីដែលមានការលួតលាស់ដទៃទៀតក្នុងឧបសម្ព័ន្ធ ២ នៃអនុសញ្ញា អាចផ្តល់ធនធានហិរញ្ញវត្ថុ ហើយភាគីនៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ប្រើប្រាស់ធនធានហិរញ្ញវត្ថុទាំងនោះ សំរាប់អនុវត្តមាត្រា ១០ តាមរយៈកិច្ចព្រមព្រៀងទ្វេភាគី កិច្ចព្រមព្រៀងក្នុងតំបន់ និងកិច្ចព្រមព្រៀងពហុភាគីនានាផ្សេងទៀត ។

## មាត្រា ១២

១. យន្តការអភិវឌ្ឍន៍ស្អាតត្រូវបានឱ្យនិយមន័យនៅទីនេះ ។

២. គោលបំណងនៃយន្តការអភិវឌ្ឍន៍ស្អាតគឺដើម្បីជួយបណ្តាភាគីពុំមាននៅក្នុងឧបសម្ព័ន្ធ ១ ឱ្យសំរេចការអភិវឌ្ឍន៍ប្រកបដោយចិរភាព និងដើម្បីរួមចំណែកក្នុងការសំរេចគោលបំណងចុងក្រោយនៃអនុសញ្ញា ព្រមទាំងជួយបណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ ឱ្យសំរេចបានការសន្យាកំហិត និងកាត់បន្ថយបរិមាណអេមីស្យុងស្របតាមមាត្រា ៣ ។

៣. ក្នុងក្របខ័ណ្ឌយន្តការអភិវឌ្ឍន៍ស្អាត :

(ក) បណ្តាភាគីមិនមានក្នុងឧបសម្ព័ន្ធ ១ នឹងទទួលប្រយោជន៍ពីបណ្តាសកម្មភាពគំរោងការ ដែលបង្កឱ្យអេមីស្យុងថយចុះ និង

*បកប្រែក្រៅផ្លូវការ*

(ខ) បណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ អាចប្រើប្រាស់តំហយអេមីស្យុងបានពីបណ្តាសកម្មភាពនៃគំរោងការបែបនោះ ជាចំណែកមួយនៃកិច្ចបំពេញការសន្យាកំហិត និងកាត់បន្ថយបរិមាណអេមីស្យុង យោងតាមមាត្រា ៣ និងដែលកំណត់ដោយសន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ។

៤. គោលការណ៍យន្តការអភិវឌ្ឍន៍ស្អាតត្រូវស្ថិតក្រោមអំណាច និងការណែនាំរបស់សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ និងត្រូវត្រួតពិនិត្យដោយក្រុមប្រឹក្សាប្រតិបត្តិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត ។

៥. ការកាត់បន្ថយអេមីស្យុងបណ្តាលពីសកម្មភាពនៃគំរោងនិមួយៗ ត្រូវទទួលស្គាល់ដោយអង្គភាពប្រតិបត្តិដែលនឹងត្រូវចាត់តាំងដោយសន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ដោយផ្អែកលើ :

(ក) ការចូលរួមដោយស្ម័គ្រចិត្តដែលមានការឯកភាពពីភាគីពាក់ព័ន្ធនីមួយៗ

(ខ) ផលប្រយោជន៍ពិតប្រាកដ ដែលអាចគណនាបាន និងសំរាប់រយៈពេលវែង ពាក់ព័ន្ធនឹងការសំរាលបញ្ហាប្រែប្រួលអាកាសធាតុ

(គ) កាត់បន្ថយអេមីស្យុងបន្ថែមលើកំរិតបច្ចុប្បន្នណាមួយដែលមានស្រាប់ក្នុងករណីអវត្តមាននៃសកម្មភាពគំរោងការខាងលើ ។

៦. យន្តការអភិវឌ្ឍន៍ស្អាតនេះត្រូវជួយចាត់ចែងផ្តល់មូលនិធិសំរាប់សកម្មភាពគំរោងការដែលបានការទទួលស្គាល់ តាមការចាំបាច់ ។

៧. នៅក្នុងសម័យប្រជុំលើកទី១របស់ខ្លួន សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវបរិយាយឱ្យបានល់អិតពីវិធី និងបែបបទប្រកបដោយគោលបំណងដើម្បីធានាតំលាភាព ប្រសិទ្ធិភាព និងការទទួលខុសត្រូវ តាមរយៈសវនកម្ម និងផ្ទៀងផ្ទាត់ដោយអង្គភាពឯករាជ្យ សំរាប់សកម្មភាពគំរោងការ ។ Comment: Accountability

៨. សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវធានាថា ចំណែកនៃចំណូលបានពីសកម្មភាពនៃគំរោងការខាងលើ នឹងត្រូវប្រើប្រាស់សំរាប់បំពេញចំណាយរដ្ឋបាល និងសំរាប់ជួយភាគីប្រទេសកំពុងអភិវឌ្ឍន៍ ពិសេសបណ្តាប្រទេសដែលងាយរងគ្រោះដោយឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ក្នុងការបំពេញចំនាយសំរាប់បន្សាំនឹងស្ថានភាពប្រែប្រួលអាកាសធាតុ ។

៩. ការចូលរួមក្នុងក្របខ័ណ្ឌយន្តការអភិវឌ្ឍន៍ស្អាត រួមទាំងសកម្មភាពចែងក្នុងវាក្យខ័ណ្ឌ ៣ (ក) ខាងលើ និងបណ្តាសកម្មភាពទទួលយកនូវការកាត់បន្ថយអេមីស្យុង អាចអនុញ្ញាតឱ្យមានការចូលរួមពីសំណាក់អង្គភាពឯកជន ឬសាធារណៈ និងត្រូវស្ថិតក្រោមរាល់ការណែនាំ ដែលអាចនឹងដាក់ចេញដោយក្រុមប្រឹក្សាប្រតិបត្តិទទួលបន្ទុកការងារយន្តការអភិវឌ្ឍន៍ស្អាត ។

១០. ការកាត់បន្ថយអេមីស្យុង ដែលមានការទទួលស្គាល់នៅក្នុងចន្លោះឆ្នាំ ២០០០ រហូតដល់ពេលចាប់ផ្តើមដំណាក់កាលទី ១ នៃការសន្យា អាចប្រើប្រាស់សំរាប់ជួយសំរេចការសន្យា នៅក្នុងដំនាក់កាលទី ១ នៃការសន្យា ។

## មាត្រា ១៣

១. សន្និសីទបណ្តាភាគី ដែលជាស្ថាប័នជាន់ខ្ពស់នៃអនុសញ្ញា ត្រូវមាននាទីជាកន្លែងប្រជុំសំរាប់បណ្តាភាគីក្នុងពិធីសារនេះ ។

២. បណ្តាភាគីក្នុងអនុសញ្ញា ដែលមិនមែនជាភាគីក្នុងពិធីសារនេះ អាចចូលរួមជាអ្នកសង្កេតការណ៍ ក្នុងសម័យប្រជុំណាមួយនៃសន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ។ នៅក្នុងសន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ មានតែបណ្តាភាគីក្នុងពិធីសារនេះទេដែលអាចធ្វើសេចក្តីសំរេចក្នុងក្របខ័ណ្ឌនៃពិធីសារនេះ ។

៣. នៅក្នុងសន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ សមាជិកណាម្នាក់ក្នុងការិយាល័យសន្និសីទបណ្តាភាគី ដែលជាតំណាងភាគីមួយក្នុងអនុសញ្ញានេះនៅក្នុងពេលសន្និសីទ ប៉ុន្តែមិនជាភាគីក្នុងពិធីសារនេះ នឹងត្រូវជំនួសដោយសមាជិកម្នាក់បន្ថែមទៀតតាមរយៈការបោះឆ្នោតដោយ និងត្រូវជ្រើសរើសក្នុងចំណោមបណ្តាសមាជិកក្នុងពិធីសារនេះ ។

៤. សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវពិនិត្យឡើងវិញជាទៀងទាត់នូវការអនុវត្តន៍ពិធីសារនេះ និងត្រូវធ្វើសេចក្តីសំរេចចាំបាច់ក្នុងក្របខ័ណ្ឌនៃអណត្តិរបស់ខ្លួន ដើម្បីជំរុញប្រសិទ្ធិភាពនៃការអនុវត្តន៍ពិធីសារនេះ ។ សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវបំពេញមុខងាររបស់ខ្លួនដែលកំនត់ដោយពិធីសារនេះ ហើយត្រូវ :

(ក) ផ្អែកលើមូលដ្ឋាននៃពត៌មានដែលមាន និងស្របតាមខចែងក្នុងពិធីសារនេះ វាយតំលៃការអនុវត្តន៍ពិធីសារនេះរបស់បណ្តាភាគី ផលសរុបបានពីបណ្តាវិធានការអនុវត្ត អនុលោមតាមពិធីសារនេះ ពិសេសផ្នែកបរិស្ថាន សេដ្ឋកិច្ច និងសង្គម ក៏ដូចជាផលប៉ះពាល់ត្រួតផ្គុំ និងវិសាលភាពនៃការសំរេចបាននូវគោលបំណងរបស់អនុសញ្ញានេះ ។

(ខ) ពិនិត្យជាទៀងទាត់នូវ កាតព្វកិច្ចរបស់បណ្តាភាគីក្នុងពិធីសារនេះ ដោយផ្តោតការយកចិត្តទុកដាក់ចំពោះរាល់ការពិនិត្យកែសំរួលដែលមានកំនត់ក្នុងមាត្រា ៤ វាក្យខណ្ឌ ២ (ឃ) និងមាត្រា ៧ វាក្យខ័ណ្ឌ ២ នៃអនុសញ្ញា និងដោយផ្អែកលើគោលបំណងនៃអនុសញ្ញា ហើយពិនិត្យជាទៀងទាត់នូវបទពិសោធន៍ទទួលបានក្នុងការអនុវត្តន៍ និងការវិវត្តន៍រីកចំរើននៃចំណេះដឹងខាងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដោយក្នុងនេះដែរត្រូវពិចារណា និងអនុម័តរបាយការណ៍ប្រក្រតីស្តីពីការអនុវត្តន៍ពិធីសារនេះ ។

(គ) ជំរុញ និងសំរួលការផ្លាស់ប្តូរពត៌មានស្តីពីវិធានការអនុម័តដោយបណ្តាភាគី សំរាប់ដោះស្រាយការប្រែប្រួលអាកាសធាតុ និងផលរបស់វា ដោយគិតទាំងភាពខុសគ្នានៃកាលៈទេសៈ ការទទួលខុសត្រូវ និងសមត្ថភាពរបស់បណ្តាភាគី ព្រមទាំងបណ្តាការសន្យារៀង១ខ្លួនរបស់ភាគីទាំងនោះ ក្នុងក្របខ័ណ្ឌនៃពិធីសារនេះ ។

(ឃ) តាមសំណើរបស់ភាគីពីរ ឬច្រើន ត្រូវជួយសំរបសំរួលវិធានការអនុម័តដោយភាគីទាំងនោះ សំរាប់ដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ និងផលរបស់វា ដោយគិតទាំងភាពខុសគ្នានៃកាលៈទេស ការទទួលខុសត្រូវ និងសមត្ថភាពរបស់បណ្តាភាគី ព្រមទាំងការសន្យារបស់ពួកគេរៀងខ្លួនរបស់ភាគីទាំងនោះ ក្នុងក្របខ័ណ្ឌនៃពិធីសារនេះ ។

(ង) អនុលោមតាមគោលបំណងនៃអនុសញ្ញានេះ និងខនានាក្នុងពិធីសារនេះ និងដោយផ្អែកលើបណ្តាសេចក្តីសំរេចពាក់ព័ន្ធធ្វើដោយសន្និសីទនៃបណ្តាភាគី ត្រូវជំរុញ និងណែនាំការអភិវឌ្ឍន៍ និងធ្វើឱ្យប្រសើរឡើងនូវតាមកាលកំណត់ នូវវិធីសាស្ត្រដែលអាចប្រៀបធៀបបាននូវប្រសិទ្ធិភាពនៃការអនុវត្តន៍ពិធីសារនេះ និងត្រូវមានការឯកភាពពីសំណាក់សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ។

(ច) ធ្វើអនុសាសន៍ទាក់ទងនឹងបញ្ហានានាចាំបាច់សំរាប់អនុវត្តពិធីសារនេះ ។

(ឆ) ប្រឹងប្រែងឱ្យមានការប្រមូលធនធានហិរញ្ញវត្ថុ អនុលោមតាមមាត្រា ១១ វាក្យខ័ណ្ឌ ២ ។

(ជ) បង្កើតអង្គភាពជំនួយការតាមការចាំបាច់សំរាប់អនុវត្តពិធីសារនេះ ។

(ឈ) ក្នុងករណីសមស្រប ស្វែងរក និងប្រើប្រាស់បណ្តាសេវា និងកិច្ចសហការជាមួយ និងពត៌មានផ្តល់ដោយ អង្គការអន្តរជាតិ ស្ថាប័នអន្តររដ្ឋាភិបាល និងស្ថាប័នក្រៅរដ្ឋាភិបាលដែលមានសមត្ថភាព ។

(ញ) បំពេញមុខងារផ្សេងទៀតដែលចាំបាច់សំរាប់អនុវត្តពិធីសារនេះ និងពិចារណាកិច្ចការណាមួយដែលស្តែងពីសេចក្តីសំរេចរបស់សន្និសីទបណ្តាភាគី ។

៥. បទបញ្ជានៃទំរង់បែបបទសំរាប់សន្និសីទបណ្តាភាគី និងទំរង់បែបបទហិរញ្ញវត្ថុសំរាប់ក្របខ័ណ្ឌអនុសញ្ញានេះ នឹងត្រូវអនុវត្តទៅតាមការប្រែប្រួលសមស្រប សំរាប់ពិធីសារនេះ លើកលែងតែមានការសំរេចជាមតិទូទៅដោយសន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ។

៦. លេខាធិការដ្ឋានត្រូវកោះប្រជុំសំរាប់សម័យប្រជុំលើកទី ១ នៃសន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ព្រមពេលជាមួយសម័យប្រជុំលើកទី ១ នៃសន្និសីទបណ្តាភាគី ដែលនឹងត្រូវកំនត់ពេលក្រោយការចូលជាធរមាននៃពិធីសារនេះ ។ សម័យប្រជុំសាមញ្ញនៃសន្និសីទបណ្តាភាគី សំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ នឹងត្រូវប្រព្រឹត្តទៅរៀងរាល់ឆ្នាំ ព្រមពេលជាមួយនឹងសម័យប្រជុំសាមញ្ញនៃសន្និសីទបណ្តាភាគី លើកលែងតែមានការសំរេចដោយសន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ។

៧. បណ្តាសម័យប្រជុំវិសាមញ្ញនៃសន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ នឹងត្រូវរៀបចំនៅពេលផ្សេង តាមការកំនត់ដោយសន្និសីទបណ្តាភាគី សំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ឬតាមសំណើរជាលាយលក្ខណ៍អក្សរដោយភាគីណាមួយ យ៉ាងតិចក្នុងរយៈពេល ៦ ខែ ដើម្បីឱ្យលេខាធិការដ្ឋានធ្វើទំនាក់ទំនងជាមួយបណ្តាភាគី និងក្រោយពេលទទួលបានការគាំទ្រយ៉ាងហោចណាស់មួយភាគបីនៃបណ្តាភាគីទាំងអស់ ។

៨. អង្គការសហប្រជាជាតិ ស្ថាប័នជំនាញរបស់អង្គការនេះ និងស្ថាប័នថាមពលអាតូមិកអន្តរជាតិ ព្រមទាំងរដ្ឋជាសមាជិក ឬអ្នកសង្កេតការណ៍ ដែលមិនមែនជាភាគីក្នុងអនុសញ្ញានេះ អាចមានតំនាងចូលរួមក្នុងនាមជាអ្នកសង្កេតការណ៍នៅក្នុងសន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ។ ជនណាម្នាក់ ឬអង្គភាពណាមួយ ទោះបីក្នុងក្របខ័ណ្ឌជាតិឬអន្តរជាតិ រដ្ឋាភិបាល ឬមិនមែនរដ្ឋាភិបាល ដែលមានសមត្ថភាពក្នុងជំនាញដែលមានចែងក្នុងពិធីសារនេះ និងដែលបានជូនដំណឹងដល់លេខាធិការដ្ឋាន ពីគោលបំណងរបស់ខ្លួន ក្នុងការបញ្ជូនតំនាងចូលរួម ក្នុងនាមជាអ្នកសង្កេតការណ៍ ក្នុងសម័យប្រជុំនៃសន្និសីទបណ្តាភាគី សំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ អាចត្រូវបានទទួលការអនុញ្ញាតឱ្យចូលរួម លើតលែងតែមានការបដិសេធដោយភាគីមានវត្តមានក្នុងសន្និសីទ យ៉ាងហោចណាស់មួយភាគបី ។ ការអនុញ្ញាត និងការចូលរួមរបស់បណ្តាអ្នកសង្កេតការណ៍ ត្រូវគោរពទៅតាមបទបញ្ជា ដែលមានចែងក្នុងវាក្យខ័ណ្ឌ ៥ ខាងលើ ។

## មាត្រា ១៤

១. លេខាធិការដ្ឋានដែលបង្កើតឡើងតាមមាត្រា ៨ នៃអនុសញ្ញានេះ ត្រូវមាននាទីជាលេខាធិការដ្ឋានសំរាប់ពិធីសារនេះ ។

*បកប្រែក្រៅផ្លូវការ*

២. មាត្រា ៨ វាក្យខ័ណ្ឌ ២ នៃអនុសញ្ញានេះ ដែលចែងពីមុខងាររបស់លេខាធិការដ្ឋាន និងមាត្រា ៨ វាក្យខ័ណ្ឌ ៣ នៃអនុសញ្ញាដែលចែងពីការរៀបចំសំរាប់ការបំពេញមុខងាររបស់លេខាធិការដ្ឋាន នឹងត្រូវអនុវត្ត តាមការប្រែប្រួលសមស្រប សំរាប់ពិធីសារនេះ ។ លើសពីនេះ លេខាធិការដ្ឋានត្រូវបំពេញមុខងាររបស់ខ្លួន ដែលកំនត់ក្នុងក្របខ័ណ្ឌនៃពិធីសារនេះ ។

## មាត្រា ១៥

១. អង្គភាពជំនួយការផ្តល់យោបល់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងអង្គភាពជំនួយការអនុវត្ត ដែលបង្កើតឡើងតាមមាត្រា ៩ និង ១០នៃអនុសញ្ញានេះ ត្រូវមាននាទីជាអង្គភាពជំនួយការផ្តល់យោបល់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងអង្គភាពជំនួយការអនុវត្តនៃពិធីសារនេះ ។ ប្រការដែលចែងពាក់ព័ន្ធនឹងមុខងាររបស់អង្គភាពទាំងពីរនេះ ក្នុងក្របខ័ណ្ឌនៃអនុសញ្ញា ត្រូវអនុវត្ត តាមការប្រែប្រួលសមស្រប សំរាប់ពិធីសារនេះ ។ សម័យប្រជុំនៃអង្គភាពជំនួយការផ្តល់យោបល់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងអង្គភាពជំនួយការអនុវត្តនៃពិធីសារនេះ នឹងត្រូវរៀបចំរួមជាមួយការប្រជុំនៃអង្គភាពជំនួយការផ្តល់យោបល់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងអង្គភាពជំនួយការអនុវត្តនៃអនុសញ្ញានេះ ។
២. បណ្តាភាគីក្នុងអនុសញ្ញានេះ ដែលមិនមែនជាភាគីក្នុងពិធីសារនេះ អាចចូលរួមប្រជុំក្នុងនាមជាអ្នកសង្កេតការណ៍នៅក្នុងសម័យប្រជុំណាមួយនៃអង្គភាពជំនួយការ ។ នៅពេលដែលអង្គភាពជំនួយការមាននាទីជាអង្គភាពជំនួយការសំរាប់ពិធីសារនេះ មានតែបណ្តាភាគីក្នុងពិធីសារនេះទេ ដែលមានសិទ្ធិធ្វើសេចក្តីសំរេចក្នុងក្របខ័ណ្ឌនៃពិធីសារនេះ ។
៣. នៅពេលដែលអង្គភាពជំនួយការបង្កើតឡើងតាមមាត្រា ៩ និង ១០នៃអនុសញ្ញា អនុវត្តមុខនាទីរបស់ខ្លួនក្នុងការងារពាក់ព័ន្ធនឹងពិធីសារនេះ សមាជិកណាម្នាក់នៃការិយាល័យរបស់បណ្តាអង្គភាពជំនួយការទាំងនេះ ដែលធ្វើជាតំណាងភាគីមួយក្នុងអនុសញ្ញានៅក្នុងពេលប្រជុំ ប៉ុន្តែមិនមែនជាភាគីក្នុងពិធីសារនេះ ត្រូវជំនួសដោយសមាជិកម្នាក់ផ្សេងទៀតក្រោយពីមានការបោះឆ្នោតដោយ និងត្រូវជ្រើសរើសក្នុងចំណោមបណ្តាភាគីក្នុងពិធីសារនេះ ។

## មាត្រា ១៦

តាមការបន្ទាន់ដែលអាចធ្វើបាន សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវពិចារណាអនុវត្ត នៅក្នុងពិធីសារនេះ និងត្រូវកែប្រែក្នុងករណីសមស្រប នូវដំណើរពិគ្រោះយោបល់ពហុភាគីដែលមានយោងក្នុងមាត្រា ១៣ នៃអនុសញ្ញា ដោយផ្អែកលើរាល់សេចក្តីសំរេចដែលអាចធ្វើឡើងដោយសន្និសីទបណ្តាភាគី ។ ដំណើរពិគ្រោះយោបល់ពហុភាគីណាមួយ ដែលអាចប្រើប្រាស់នៅក្នុងពិធីសារនេះ នឹងត្រូវអនុវត្តដោយគ្មានលំអៀងនៅក្នុងទំរង់ការ និងយន្តការដែលរៀបចំដូចមានចែងក្នុងមាត្រា ១៨ ។

## មាត្រា ១៧

សន្និសីទបណ្តាភាគីត្រូវកំនត់គោលការណ៍ វិធី បទបញ្ជា និងសេចក្តីណែនាំ ជាពិសេសសំរាប់ផ្ទៀងផ្ទាត់ ធ្វើសេចក្តីរាយការណ៍ និងការទទួលខុសត្រូវក្នុងការធ្វើពាណិជ្ជកម្មឧស្ម័ន ។ បណ្តាភាគីក្នុងឧបសម្ព័ន្ធ ខ អាចចូលរួមក្នុងពាណិជ្ជកម្មអេមីស្យុង ក្នុងគោលបំណងបំពេញការសន្យាតាមមាត្រា ៣ ។ រាល់ការធ្វើពាណិជ្ជកម្មបែបនេះ ត្រូវតែជាការបន្ថែមទៅលើសកម្មភាពក្នុងប្រទេសក្នុងគោលបំណងបំពេញការសន្យាកំហិត និងកាត់បន្ថយបរិមាណអេមីស្យុងតាមមាត្រានេះ ។

## មាត្រា ១៨

នៅក្នុងសម័យប្រជុំទី ១ របស់ខ្លួន សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវអនុម័តទំរង់ការ និងយន្តការសមស្រប និងមានប្រសិទ្ធិភាព សំរាប់កំនត់ និងដោះស្រាយករណីខកខានមិនបានគោរពតាមខនៃពិធីសារនេះ រួមទាំងតាមរយៈការបង្កើតតារាងសន្ទស្សន៍ផលវិបាក ដោយគិតផងដែរអំពីមូលហេតុ ប្រភេទ កំរិតធ្ងន់ធ្ងរ និងភាពញឹកញាប់នៃករណីមិនគោរពតាមនេះ។ ទំរង់ការ និងយន្តការណាមួយក្នុងមាត្រានេះ ដែលតំរូវឱ្យមានការទទួលខុសត្រូវជាលក្ខណៈច្បាប់ចំពោះផលវិបាកដែលកើតឡើង នឹងត្រូវអនុម័តតាមរូបភាពនៃការធ្វើវិសោធនកម្មចំពោះពិធីសារនេះ ។

## មាត្រា ១៩

បណ្តាប្រការក្នុងមាត្រា ១៤ នៃអនុសញ្ញានេះ ដែលចែងពីជំលោះស្រាយទំនាស់ នឹងត្រូវអនុវត្ត ដោយមានការកែប្រែសមស្រប ទៅតាមស្ថានភាពនៃពិធីសារនេះ ។

## មាត្រា ២០

១. ភាគីណាមួយអាចលើកសំណើធ្វើវិសោធនកម្មចំពោះពិធីសារនេះ ។
២. ការធ្វើវិសោធនកម្មចំពោះពិធីសារនេះ នឹងត្រូវអនុម័តនៅក្នុងសម័យប្រជុំសាមញ្ញនៃសន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ។ លេខាធិការដ្ឋានត្រូវផ្សព្វផ្សាយអត្ថបទសំណើវិសោធនកម្មចំពោះពិធីសារនេះដល់បណ្តាភាគី យ៉ាងហោចណាស់ក្នុងរយៈពេល ៦ ខែ មុនពេលរៀបចំប្រជុំដើម្បីអនុម័តលើសំណើវិសោធនកម្មនោះ ។ លេខាធិការដ្ឋានត្រូវផ្សព្វផ្សាយអត្ថបទនៃសំណើវិសោធនកម្មទៅបណ្តាភាគី និងហត្ថលេខីនៃអនុសញ្ញានេះ និងផ្ញើទៅកន្លែងតំកល់ឯកសារសំរាប់ជាពតិមាន ។
៣. បណ្តាភាគីត្រូវប្រឹងប្រែងដើម្បីឱ្យមានការឯកភាពលើសំណើវិសោធនកម្មណាមួយចំពោះពិធីសារនេះ តាមការអនុម័តដោយមតិឯកភាពជាទូទៅ ។ ក្នុងករណីដែលមិនអាចឈានដល់ការឯកភាពជាមតិទូទៅ ការអនុម័តលើសំនើធ្វើវិសោធនកម្មអាចធ្វើតាមរយៈការបោះឆ្នោតដោយសំលេងភាគច្រើនពីរភាគបីនៃបណ្តាភាគីដែលមានវត្តមាន និងដែលបានបោះឆ្នោតនៅក្នុងការប្រជុំ ។ លេខាធិការដ្ឋានត្រូវផ្ញើវិសោធនកម្មដែលទទួលបានការអនុម័តឯកភាពរួចហើយទៅកន្លែងតំកល់ឯកសារ ដែលនឹងផ្សព្វផ្សាយទៅគ្រប់បណ្តាភាគីសំរាប់ការទទួលយល់ព្រម ។
៤. ឯកសារស្តីពីការទទួលយល់ព្រមចំពោះវិសោធនកម្មនឹងត្រូវរក្សាទុកនៅកន្លែងតំកល់ឯកសារ ។ វិសោធនកម្មធ្វើឡើងតាមវាក្យខ័ណ្ឌ ៣ ខាងលើ នឹងចូលជាធរមានសំរាប់បណ្តាភាគីដែលទទួលយល់ព្រមលើវិសោធនកម្មនោះ នៅក្នុងរយៈពេល ៩០ ថ្ងៃ ក្រោយកាលបរិច្ឆេទ ដែលកន្លែងតំកល់ឯកសារបានទទួលសំណៅនៃការយល់ព្រមចំនួនយ៉ាងហោចណាស់បីភាគបួននៃចំនួនភាគីក្នុងពិធីសារនេះ ។
៥. អត្ថបទវិសោធនកម្មនឹងចូលជាធរមានសំរាប់ភាគីផ្សេងៗទៀត នៅក្នុងរយៈពេល ៩០ ថ្ងៃ ក្រោយកាលបរិច្ឆេទដែលភាគីនោះបានបញ្ជូនឯកសារស្តីពីទទួលយល់ព្រមលើវិសោធនកម្មនោះ ទៅដល់កន្លែងតំកល់ឯកសារ ។

## មាត្រា ២១

១. បណ្តាឧបសម្ព័ន្ធនៃពិធីសារនេះនឹងក្លាយជាចំណែករួមមួយនៃពិធីសារនេះ ផ្ទុយទៅវិញ ការចុះកំនត់យោងចំពោះពិធីសារនេះ នឹងត្រូវមានការចុះកំនត់យោងចំពោះឧបសម្ព័ន្ធរបស់ពិធីសារនេះផងដែរ ។ រាល់ឧបសម្ព័ន្ធដែលបានអនុម័តក្រោយពេលចូលជាធរមាននៃពិធីសារនេះ នឹងត្រូវកំនត់ក្រោមរូបភាពជាតារាង ក្រដាសបំពេញ និងជាឯកសារដែលមានទំរង់ជាសេចក្តីអធិប្បាយ ដែលមានលក្ខណៈជាឯកសារវិទ្យាសាស្ត្រ បច្ចេកទេស ឯកសារទំរង់ការ ឬឯកសាររដ្ឋបាល ។
២. គ្រប់ភាគីអាចលើកសេចក្តីស្នើឱ្យមានឧបសម្ព័ន្ធចំពោះពិធីសារនេះ និងអាចស្នើធ្វើវិសោធនកម្មចំពោះបណ្តាឧបសម្ព័ន្ធនៃពិធីសារនេះ ។
៣. បណ្តាឧបសម្ព័ន្ធចំពោះពិធីសារនេះ និងវិសោធនកម្មឧបសម្ព័ន្ធនៃពិធីសារនេះត្រូវអនុម័តក្នុងសម័យប្រជុំសាមញ្ញនៃសន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ។ លេខាធិការដ្ឋានត្រូវផ្សព្វផ្សាយអត្ថបទនៃសេចក្តីស្នើឧបសម្ព័ន្ធ ឬវិសោធនកម្មចំពោះឧបសម្ព័ន្ធដល់បណ្តាភាគី យ៉ាងហោចណាស់ ៦ ខែ មុនពេលប្រជុំអនុម័តសំណើនោះ ។ លេខាធិការដ្ឋានក៏ត្រូវផ្សព្វផ្សាយអត្ថបទសំនើឧបសម្ព័ន្ធ ឬវិសោធនកម្មចំពោះឧបសម្ព័ន្ធដល់បណ្តាភាគី និងហត្ថលេខីនៃអនុសញ្ញានេះនិងទៅកន្លែងតំកល់ឯកសារសំរាប់ជាពតិមាន។
៤. បណ្តាភាគីត្រូវប្រឹងប្រែងដើម្បីឱ្យមានការឯកភាពលើសេចក្តីស្នើឧបសម្ព័ន្ធ ឬវិសោធនកម្មចំពោះឧបសម្ព័ន្ធ តាមការអនុម័តដោយមតិឯកភាពជាទូទៅ ។ ក្នុងករណីដែលមិនអាចឈានដល់ការឯកភាពជាមតិទូទៅ ការអនុម័តលើសេចក្តីស្នើឧបសម្ព័ន្ធ ឬវិសោធនកម្មចំពោះឧបសម្ព័ន្ធអាចធ្វើ តាមរយៈការបោះឆ្នោតដោយសំលេងភាគច្រើនពីរភាគបីនៃបណ្តាភាគីដែលមានវត្តមាន និងដែលបានបោះឆ្នោតនៅក្នុងការប្រជុំ ។ លេខាធិការដ្ឋានត្រូវផ្ញើឧបសម្ព័ន្ធ ឬវិសោធនកម្មចំពោះឧបសម្ព័ន្ធ ដែលទទួលបានការអនុម័តឯកភាពរួចហើយ ទៅកន្លែងតំកល់ឯកសារ ដែលនឹងផ្សព្វផ្សាយទៅគ្រប់បណ្តាភាគីសំរាប់ការទទួលយល់ព្រម ។
៥. ឧបសម្ព័ន្ធ ឬវិសោធនកម្មចំពោះឧបសម្ព័ន្ធក្រៅពីឧបសម្ព័ន្ធ A និង B ដែលបានទទួលការអនុម័តយល់ព្រម ស្របតាមវាក្យខ័ណ្ឌ ៣ និង ៤ ខាងលើ នឹងត្រូវចូលជាធរមានសំរាប់គ្រប់ភាគីក្នុងពិធីសារនេះនៅក្នុងកំឡុងពេល ៦ ខែ ក្រោយកាលបរិច្ឆេទនៃការផ្សព្វផ្សាយស្តីពីការអនុម័តឧបសម្ព័ន្ធ ឬវិសោធនកម្មចំពោះឧបសម្ព័ន្ធ ដោយកន្លែងតំកល់ឯកសារទៅគ្រប់បណ្តាភាគី លើកលែងតែចំពោះភាគី

ដែលបានធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកន្លែងតំកល់ឯកសារក្នុងកំឡុងពេលនោះ នូវការមិនទទួលយល់ព្រមរបស់គេចំពោះឧបសម្ព័ន្ធ ឬវិសោធនកម្មចំពោះឧបសម្ព័ន្ធនោះ ។ ឧបសម្ព័ន្ធ ឬវិសោធនកម្មចំពោះឧបសម្ព័ន្ធ នឹងចូលជាធរមានចំពោះបណ្តាភាគីដែល បានដកសេចក្តីជូនដំណឹងពីការមិនទទួលយល់ព្រមរបស់គេ នៅក្នុងកំឡុងពេលថ្ងៃទី ៩០ ក្រោយកាលបរិច្ឆេទ ដែលកន្លែងតំកល់ឯកសារបានទទួលសំណើសុំដកសេចក្តីជូនដំណឹងបែបនេះ ។

៦. ប្រសិនបើការអនុម័តឧបសម្ព័ន្ធ ឬវិសោធនកម្មចំពោះឧបសម្ព័ន្ធពាក់ព័ន្ធដល់ការធ្វើវិសោធនកម្មពិធីសារនេះ ឧបសម្ព័ន្ធនោះ ឬវិសោធនកម្មចំពោះឧបសម្ព័ន្ធនោះ នឹងមិនចូលជាធរមាន រហូតដល់ពេលដែលវិសោធនកម្មចំពោះពិធីសារនេះបានចូលជាធរមាន ។

៧. វិសោធនកម្មចំពោះឧបសម្ព័ន្ធ A និង B នៃពិធីសារនេះ នឹងត្រូវអនុម័ត និងចូលជាធរមានយោងតាមទំរង់ការដែលមានចែងក្នុងមាត្រា ២០ និងតែក្នុងករណីដែលវិសោធនកម្មចំពោះឧបសម្ព័ន្ធ B បានទទួលការអនុម័តយល់ព្រមជាលាយលក្ខណ៍អក្សរពីសំណាក់ភាគីពាក់ព័ន្ធ ។

## មាត្រា ២២

១. ភាគីនីមួយៗមានសំលេងឆ្នោតតែមួយគត់ លើកលែងតែក្នុងករណីចែងក្នុងវាក្យខ័ណ្ឌ ២ ខាងក្រោម ។

២. អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់អាចនឹងមានសិទ្ធិបោះឆ្នោតលើសពីមួយសំលេង ស្មើនឹងចំនួនរដ្ឋជាសមាជិករបស់អង្គការនោះ ដែលជាភាគីក្នុងពិធីសារនេះ ។ អង្គការបែបនេះនឹងមិនប្រើសិទ្ធិបោះឆ្នោតបែបនេះឡើយ ប្រសិនបើរដ្ឋណាមួយជាសមាជិកចូលរួមបោះឆ្នោត ក្នុងនាមជាភាគីក្នុងពិធីសារនេះ ឬផ្ទុយទៅវិញ រដ្ឋនោះនឹងពុំមានសិទ្ធិបោះឆ្នោតក្នុងនាមជាភាគីក្នុងពិធីសារនេះឡើយ ។

## មាត្រា ២៣

អគ្គលេខាធិការអង្គការសហប្រជាជាតិនឹងមាននាទីជាកន្លែងតំកល់ឯកសារពិធីសារនេះ ។

## មាត្រា ២៤

១. ពិធីសារនេះនឹងត្រូវបើកសំរាប់ការចុះហត្ថលេខា និងត្រូវមានការឱ្យសច្ចាប័ន ការទទួលយល់ព្រម ឬការអនុម័តដោយបណ្តារដ្ឋ និងអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ដែលជាភាគីក្នុងអនុសញ្ញានេះ ។ ពិធីសារនេះនឹងត្រូវបើកឱ្យចុះហត្ថលេខានៅឯទីស្នាក់ការអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក ពីថ្ងៃទី ១៦ ខែ មិនា ឆ្នាំ ១៩៩៨ ដល់ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៩៩៩ ។ ពិធីសារនេះនឹងបើកសំរាប់ការសុំចូលជាសមាជិក ចាប់ពីថ្ងៃក្រោយកាលបរិច្ឆេទបញ្ចប់ការចុះហត្ថលេខា ។ ឯកសារសច្ចាប័ន ការទទួលយល់ព្រម អនុម័ត ឬការសុំចូលជាសមាជិក នឹងត្រូវរក្សាទុកនៅកន្លែងតំកល់ឯកសារ ។

២. អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ណាមួយ ដែលក្លាយជាភាគីក្នុងពិធីសារនេះ ដោយរដ្ឋជាសមាជិករបស់ខ្លួនពុំមែនជាភាគីក្នុងពិធីសារនេះ នឹងមានកាតព្វកិច្ចជាលក្ខណៈច្បាប់តាមពិធីសារនេះទាំងស្រុង ។ ក្នុងករណីដែលបណ្តាអង្គការបែបនេះ មានរដ្ឋជាសមាជិក មួយឬច្រើនជាសមាជិកនៃពិធីសារនេះ អង្គការនេះ និងបណ្តារដ្ឋជាសមាជិករបស់ខ្លួនត្រូវធ្វើសេចក្តីសំរេចអំពីការទទួលខុសត្រូវ ក្នុងកិច្ចអនុវត្តកាតព្វកិច្ចក្នុងពិធីសារនេះ ។ ក្នុងករណីបែបនេះ អង្គការ និងរដ្ឋជាសមាជិកនឹងមិនមានសិទ្ធិទ្វេរដំណាលគ្នាក្នុងពិធីសារនេះទេ ។

៣. នៅក្នុងឯកសារសច្ចាប័ន ទទួលយល់ព្រម អនុម័ត ឬសុំចូលជាសមាជិករបស់ខ្លួន បណ្តាអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ត្រូវប្រកាសនូវកំរិតសមត្ថភាពរបស់ខ្លួនក្នុងក្របខ័ណ្ឌនៃសេចក្តីដែលមានចែងក្នុងពិធីសារនេះ ។ អង្គការទាំងនេះក៏ត្រូវធ្វើសេចក្តីជូនដំណឹងទៅកន្លែងតំកល់ឯកសារដែលនឹងផ្សព្វផ្សាយបន្តទៅបណ្តាភាគី ស្តីពីការកែប្រែ នៅក្នុងវិសាលភាពនៃសមត្ថភាពរបស់អង្គការទាំងនោះ ។

## មាត្រា ២៥

១. ពិធីសារនេះនឹងចូលជាធរមាននៅថ្ងៃទី ៩០ ក្រោយកាលបរិច្ឆេទ ដែលមានសមាជិកក្នុងអនុសញ្ញាចំនួនមិនតិចជាង ៥៥ ដែលនៅក្នុងនោះ បណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ ដែលមានអេមីស្យុងឧស្ម័នកាបូនិចយ៉ាងហោចណាស់ ៥៥% នៃអេមីស្យុងឧស្ម័ន កាបូនិចសារុបបញ្ចេញក្នុងឆ្នាំ ១៩៩០ ដោយបណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ បានតំកល់ឯកសារសច្ចាប័ន ទទួលយល់ព្រម អនុម័ត ឬចូលជាសមាជិក ។

*បកប្រែក្រៅផ្លូវការ*

២. សំរាប់តែក្នុងគោលបំណងនៃមាត្រានេះ "អេមីស្យុងឧស្ម័នកាបូនិចសរុបក្នុងឆ្នាំ ១៩៩០ បញ្ចេញដោយបណ្តាភាគីក្នុងឧបសម្ព័ន្ធ ១" មានន័យថា បរិមាណដែលបានប្រកាសឱ្យដឹងនៅកាលបរិច្ឆេទ ឬមុនកាលបរិច្ឆេទនៃការអនុម័តពិធីសារនេះ ពីសំណាក់បណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ នៅក្នុងរបាយការណ៍ជាតិដំបូងបង្អស់ ដែលបានដាក់ជូន តាមមាត្រា ១២ នៃអនុសញ្ញា ។

៣. ចំពោះរដ្ឋនានា ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ដែលផ្តល់សច្ចាប័ន ទទួលយល់ព្រម ឬអនុម័តលើពិធីសារនេះ ឬសុំចូលជាសមាជិកនៃពិធីសារនេះក្រោយពេលដែលលក្ខខណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌ ១ ខាងលើ ស្តីពីការចូលជាធរមានត្រូវបានបំពេញ ពិធីសារនេះនឹងចូលជាធរមាននៅថ្ងៃទី ៩០ ក្រោយកាលបរិច្ឆេទនៃការដាក់តំកល់លិខិតូបករណ៍សច្ចាប័ន ទទួលយល់ព្រម អនុម័ត ឬសុំចូលជាសមាជិក ។

៤. សំរាប់តែគោលបំណងនៃមាត្រានេះ លិខិតូបករណ៍ណាមួយដែលដាក់ដំកល់ដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ នឹងមិនត្រូវរាប់បញ្ចូលជាចំនួនបន្ថែមនឹងចំនួនលិខិតូបករណ៍ដែលបានតំកល់ដោយបណ្តារដ្ឋជាសមាជិកនៃអង្គការនោះទេ ។

## មាត្រា ២៦

ពុំមានករណីលើកលែងណាមួយអនុញ្ញាតឱ្យមាននៅក្នុងពិធីសារនេះទេ ។

## មាត្រា ២៧

១. នៅពេលណាមួយ ក្រោយរយៈពេលបីឆ្នាំគិតចាប់ពីថ្ងៃដែលពិធីសារនេះបានចូលជាធរមានសំរាប់ភាគីណាមួយ ភាគីនោះអាចសុំដកសមាជិកភាពរបស់ខ្លួនពីពិធីសារនេះ ដោយធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកន្លែងតំកល់ឯកសារ ។

២. ការសុំលាលែងបែបនេះនឹងមានប្រសិទ្ធិភាពក្រោយពីកាលកំនត់សុពលភាពរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទដែលកន្លែងតំកល់ឯកសារបានទទួលសេចក្តីជូនដំណឹងអំពីការសុំដកសមាជិកភាពតំកល់ ឬនៅកាលបរិច្ឆេទក្រោយទៀត ដែលអាចមានកំនត់នៅក្នុងសេចក្តីជូនដំណឹងអំពីការសុំលាលែងតំកល់ ។

៣. ភាគីណាមួយដែលសុំដកសមាជិកភាពពីអនុសញ្ញា ក៏ត្រូវបានចាត់ទុកថាបានដកសមាជិកភាពពីពិធីសារនេះដែរ ។

## មាត្រា ២៨

សំណៅដើមនៃពិធីសារនេះ ដែលមានជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ មានតំលៃដូចគ្នា នឹងត្រូវដាក់តំកល់នៅឯអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

ធ្វើនៅ ក្យូតូ ថ្ងៃទីដប់មួយ ខែវិច្ឆិកា ឆ្នាំមួយពាន់ប្រាំបួនរយកៅសិបប្រាំពីរ ។

ដើម្បីជាសាក្សី បណ្តាភាគីបានចុះហត្ថលេខាលើពិធីសារនេះតាមកាលបរិច្ឆេទខាងលើ ។

*បកប្រែក្រៅផ្លូវការ*

**ឧបសម្ព័ន្ធ A**

**ឧស្ម័នផ្ទះកញ្ចក់**

ឧស្ម័នកាបូនិច ($CO_2$)

មេតាន ($CH_4$)

ឌីអាសូតម៉ូណូអុកស៊ីត ($N_2O$)

អ៊ីដ្រូភ្លុយអរ៉ូកាបូន (HFCs)

ពែរភ្លុយអរ៉ូកាបូន (PFCs)

ស៊ុលផួអ៊ិចសាភ្លូរីត ($SF_6$)

**វិស័យ/ប្រភពនៃឧស្ម័នផ្ទះកញ្ចក់**

ថាមពល

- ចំហេះឥន្ធនៈ
  - ឧស្សាហកម្មថាមពល
  - ឧស្សាហកម្មផលិតឧបករណ៍ប្រើប្រាស់ និងសំណង់
  - ការដឹកជញ្ជូន
  - វិស័យផ្សេងទៀត
  - ប្រភពផ្សេងទៀត
- អេមីស្យុងពីឥន្ធនៈ
  - ឥន្ធនៈរឹង
  - ប្រេង និងឧស្ម័នធម្មជាតិ
  - ប្រភពផ្សេងទៀត

ក្នុងដំណើរផលិតកម្មឧស្សាហកម្ម

- ផលិតផលរ៉ែ
- ឧស្សាហកម្មគីមី
- ផលិតកម្មលោហធាតុ
- ផលិតកម្មផ្សេងទៀត
- ផលិតកម្មហាឡូកាបូន និងស៊ុលភួអ៊ិចសាភ្លុយអរីត
- ការប្រើប្រាស់ហាឡូកាបូន និងស៊ុលភួអ៊ិចសាភ្លុយអរីត
- ប្រភពផ្សេងទៀត

គ្រឿងរំលាយ និងការប្រើប្រាស់ផលិតផលផ្សេងទៀត

កសិកម្ម

- ដំណើរលឿងក្នុងក្រពះសត្វ
- ការគ្រប់គ្រងជីធម្មជាតិ
- វប្បកម្មស្រូវ
- ដីកសិកម្ម
- ការដុតវាលស្មៅសាវ៉ាន
- ការដុតសំណល់កសិកម្មនៅនឹងកន្លែង
- ប្រភពផ្សេងទៀត

សំណល់

- ការចោលសំណល់រឹងលើផ្ទៃដី
- ការគ្រប់គ្រងសំណល់រាវ
- ការដុតសំណល់
- ប្រភពផ្សេងទៀត

*បកប្រែក្រៅផ្លូវការ*

## ឧបសម្ព័ន្ធ B

| ភាគី | ការសន្យាកំហិតនិងកាត់បន្ថយបរិមាណអេមីស្យុង (ភាគរយនៃឆ្នាំមូលដ្ឋាន ឬចន្លោះពេល) |
|---|---|
| អូស្ត្រាលី | ១០៨ |
| អូទ្រីស | ៩២ |
| បែលស៊ិច | ៩២ |
| ប៊ុលការី* | ៩២ |
| កាណាដា | ៩៤ |
| ក្រូអាទី* | ៩៥ |
| សាធារណរដ្ឋឆែក* | ៩២ |
| ដាណឺម៉ាក | ៩២ |
| អេស្តូនី* | ៩២ |
| សហគមន៍អឺរ៉ុប | ៩២ |
| ហ្វាំងឡង់ | ៩២ |
| បារាំង | ៩២ |
| អាល្លឺម៉ង់ | ៩២ |
| ក្រិច | ៩២ |
| ហុងគ្រី* | ៩៤ |
| អាយស្លែន | ១១០ |
| អៀកឡង់ | ៩២ |
| អ៊ីតាលី | ៩២ |
| ជប៉ុន | ៩៤ |
| ឡាតវី* | ៩២ |
| លិកតេនស្តែន | ៩២ |
| លីទុយអានី* | ៩២ |
| លុចសំបួរ | ៩២ |
| ម៉ូណាកូ | ៩២ |
| ហូឡង់ | ៩២ |
| នូវែលសេឡង់ | ១០០ |
| ណ័រវេ | ១០១ |
| ប៉ូឡូញ* | ៩៤ |
| ព័រទុយហ្គាល់ | ៩២ |
| រូម៉ានី* | ៩២ |
| សហព័ន្ធរុស្ស៊ី* | ១០០ |
| ស្លូវ៉ាគី* | ៩២ |
| ស្លូវេនៀ* | ៩២ |
| អេស្ប៉ាញ | ៩២ |
| ស៊ុយអែត | ៩២ |
| ស្វ៊ីស | ៩២ |
| អ៊ុយក្រែន* | ១០០ |
| ចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង | ៩២ |
| សហរដ្ឋអាមេរិច | ៩៣ |

-------------------

*បណ្តាប្រទេសស្ថិតក្នុងដំណើរអន្តរកាលឈានទៅសេដ្ឋកិច្ចទីផ្សារ

*បកប្រែក្រៅផ្លូវការ*

**សេចក្តីសំរេចអនុម័តដោយសន្និសីទបណ្តាភាគី**

**(សម័យប្រជុំពេញអង្គលើកទី ១២ ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ១៩៩៧)**

**សេចក្តីសំរេច 1/CP.3**

**ការអនុម័តពិធីសារក្រុងក្យូតូនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ**

**សន្និសីទបណ្តាភាគី**

បានពិនិត្យមាត្រា ៤ វាក្យខ័ណ្ឌ ២ (ក) និង (ខ) នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ នៅក្នុងសម័យប្រជុំទីមួយ ហើយបានសំរេចថា វាក្យខ័ណ្ឌរងទាំងអស់នេះមិនទាន់គ្រប់គ្រាន់ទេ ។

បានឃើញសេចក្តីសំរេចរបស់ខ្លួន 1/CP.1 ស្តីពី "អាណត្តិក្រុងប៊ែរឡាំង : ការពិនិត្យឡើងវិញនូវលក្ខណៈខ្វះខាតនៃមាត្រា ៤ វាក្យខ័ណ្ឌ ២ (ក) និង (ខ) នៃអនុសញ្ញានេះ រួមទាំងសំណើទាក់ទងនឹងពិធីសារ និងសេចក្តីសំរេចស្តីពីការបន្ត" ដែលមានការឯកភាពដើម្បីចាប់ផ្តើមដំណើរការសំរាប់ជួយពង្រឹងសមត្ថភាពដើម្បីចាត់វិធានការសមស្របសំរាប់ចន្លោះពេលក្រោយឆ្នាំ ២០០០ តាមរយៈការអនុម័តពិធីសារ ឬឯកសារច្បាប់ផ្សេងទៀតនៅសម័យប្រជុំលើកទី ៣ ។

បានឃើញថា គោលដៅមួយនៃដំណើរការនេះគឺដើម្បីពង្រឹងការសន្យាក្នុងមាត្រា ៤ វាក្យខ័ណ្ឌ ២ (ក) និង (ខ) នៃអនុសញ្ញានេះសំរាប់ ប្រទេសឧស្សាហកម្មជឿនលឿន/ភាគីផ្សេងទៀត ក្នុងឧបសម្ព័ន្ធ ១ ដើម្បីចែងឱ្យបានល់អិតនូវគោលនយោបាយ និងវិធានការ និងដើម្បីកំនត់គោលបំណងនៃការកំហិត និងកាត់បន្ថយបរិមាណអេមីស្យុងនៅក្នុងកាលកំនត់មួយ ដូចជានៅឆ្នាំ ២០០៥ ២០១០ និង ២០២០ សំរាប់អេមីស្យុង និងអាងស្រូបកាបូននៃឧស្ម័នផ្ទះកញ្ចក់របស់ពួកគេ ដែលបណ្តាលពីសកម្មភាពមនុស្ស ពីប្រភពផ្សេងៗ និងដែលពុំមានចែងក្នុងពិធីសារក្រុងម៉ុងរ៉េអាល ។

បានឃើញថា យោងតាមអាណត្តិក្រុងប៊ែរឡាំង ដំណើរការនេះនឹងមិនបង្កើតការសន្យាថ្មីបន្ថែមទៀតសំរាប់បណ្តាភាគីដែលមិនមានក្នុងឧបសម្ព័ន្ធ ១ ទេ ប៉ុន្តែបានបញ្ជាក់ឡើងវិញនូវការសន្យាដែលមានស្រាប់ស្របតាមមាត្រា ៤ វាក្យខ័ណ្ឌ ១ និងបន្តអនុវត្តការសន្យាទាំងនោះដើម្បីសំរេចឱ្យបានការអភិវឌ្ឍន៍ដោយចិរភាព ដោយយោងតាមមាត្រា ៤ វាក្យខ័ណ្ឌ ៣ ៥ និង ៧ ។

បានកត់សំគាល់ បណ្តារបាយការណ៍របស់ក្រុមបណ្តោះអាសន្នទទួលបន្ទុកអាណត្តិក្រុងប៊ែរឡាំងនៅក្នុងសម័យប្រជុំទី ៨ របស់ខ្លួន[១] ។

បានពិចារណាដោយវាយតំលៃខ្ពស់នូវរបាយការណ៍បង្ហាញជូនដោយប្រធានក្រុមបណ្តោះអាសន្នទទួលបន្ទុកអាណត្តិក្រុងប៊ែរឡាំង ។

បានកត់សំគាល់ដោយវាយតំលៃខ្ពស់នូវរបាយការណ៍របស់ប្រធានគណៈកម្មាធិការអំពីលទ្ធផលទាំងមូលរបស់គណៈកម្មាធិការនេះ ។

ដោយទទួលស្គាល់តំរូវការរៀបចំដើម្បីឱ្យមានការចូលជាធរមានជាបន្ទាន់នៃពិធីសារក្រុងក្យូតូនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ។

បានដឹងថា មានសេចក្តីប្រាថ្នាចាប់ផ្តើមការងារឱ្យបានទាន់ពេល ដើម្បីផ្តល់ជាមូលដ្ឋានឱ្យមានលទ្ធផលប្រកបដោយជោគជ័យនៃសម័យប្រជុំលើកទី ៤ នៃសន្និសីទបណ្តាភាគី ដែលគ្រោងនឹងធ្វើនៅទីក្រុង ប៊ុយណូសអ៊ែ ប្រទេសអាសង់ទីន ។

១. សំរេចអនុម័តពិធីសារក្រុងក្យូតូនៃអនុសញ្ញាក្របខ័ណ្ឌអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ។

២. ស្នើឱ្យអគ្គលេខាធិការអង្គការសហប្រជាជាតិមាននាទីជាកន្លែងតំកល់ពិធីសារនេះ និងត្រូវបើកសំរាប់ការចុះហត្ថលេខានៅទីក្រុងញូវយ៉ក ពីថ្ងៃទ ១៦ ខែ មិនា ឆ្នាំ ១៩៩៨ ដល់ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៩៩៩ ។

៣. អញ្ជើញភាគីទាំងអស់ក្នុងអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុដើម្បីចុះហត្ថលេខាលើពិធិសារនេះ នៅថ្ងៃទី ១៦ ខែមិនា ឆ្នាំ ១៩៩៨ ឬនៅក្នុងឱកាសឆាប់បំផុត តាមដែលអាចធ្វើបាន នៅក្រោយបរិច្ឆេទនេះ និងដើម្បីតំកល់លិខិតូបករណ៍ផ្តល់សច្ចាប័ន ទទួលយល់ព្រម ឬអនុម័ត ឬចូលជាសមាជិក នៅពេលសមស្រប និងឆាប់បំផុត តាមតែអាចធ្វើបាន ។

៤. អញ្ជើញបណ្តារដ្ឋដែលមិនមែនជាភាគីក្នុងអនុសញ្ញានេះ ដើម្បីផ្តល់សច្ចាប័ន ឬទទួលយកពិធីសារនេះតាមលក្ខខណ្ឌសមស្រប ដោយជៀសវាងការពន្យារពេល ដើម្បីឱ្យរដ្ឋទាំងនោះអាចក្លាយទៅជាភាគីក្នុងពិធីសារនេះ ។

៥. ស្នើឱ្យប្រធាននៃអង្គភាពជំនួយការផ្តល់យោបល់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងប្រធានអង្គភាពជំនួយការអនុវត្ត ដោយពិចារណាអំពីថវិកាដែលបានអនុម័តសំរាប់កម្មវិធីសំរាប់រយៈពេលពីរឆ្នាំ ១៩៩៨-១៩៩៩ និងកម្មវិធីពាក់ព័ន្ធសំរាប់លេខាធិការដ្ឋាន[២] ដើម្បីផ្តល់ការណែនាំដល់លេខាធិការដ្ឋានអំពីការងាររៀបចំចាំបាច់សំរាប់ការពិចារណាពីសំណាក់សន្និសីទបណ្តាភាគី នៅក្នុងសម័យប្រជុំលើកទី ៤ របស់ខ្លួន នូវបណ្តាការងារដូចខាងក្រោម និងត្រូវកំនត់ការងារសំរាប់បណ្តាអង្គភាពជំនួយការឱ្យបានសមស្រប :

(ក) កំនត់វិធី បទបញ្ជា និងគោលការណ៍ណែនាំអំពីសកម្មភាពបង្កដោយមនុស្សពាក់ព័ន្ធនឹងការប្រែប្រួលឧស្ម័នផ្ទះកញ្ចក់ពី ប្រភពនានា និងការចាប់យកដោយអាងស្រូបកាបូនក្នុងដីកសិកម្ម និងក្នុងការប្រែប្រួលការប្រើប្រាស់ដី និងព្រៃឈើ នឹងត្រូវបន្ថែម

---

[១] FCC/AGBM/1995/2 and Corr.1, and Corr.1; FCCC/AGBM/1996/5,8, and 11; FCCC/AGBM/1997/3, 3/Add and Corr.1,5,8 and 8/Add,1.

[២] FCCC/CP/1997/INF.1.

ទៅលើ ឬកាត់ចេញពីបរិមាណកំនត់សំរាប់បណ្តាភាគីក្នុងពិធីសារនេះដែលមានក្នុងឧបសម្ព័ន្ធ ១ នៃអនុសញ្ញានេះ ដូចដែលមានចែងក្នុងមាត្រា ៣ វាក្យខ័ណ្ឌ ៤ នៃពិធីសារនេះ ។

(ខ) កំនត់និយមន័យសំរាប់គោលការណ៍ វិធី បទបញ្ជា និងគោលការណ៍ណែនាំ ជាពិសេសសំរាប់ការផ្ទៀងផ្ទាត់ ធ្វើសេចក្តីរាយការណ៍ ការគណនាពាណិជ្ជកម្មអេមីស្យុង ស្របតាមមាត្រា ១៧ នៃពិធីសារនេះ ។

(គ) ចែងលំអិតអំពីគោលការណ៍ណែនាំសំរាប់ភាគីនីមួយៗក្នុងពិធីសារដែលមានក្នុងឧបសម្ព័ន្ធ ១ នៃអនុសញ្ញានេះ អំពីការផ្ទេរ ឬទទួលយកពីភាគីផ្សេងទៀត នូវចំនួនឯកត្តានៃអេមីស្យុងដែលត្រូវកាត់បន្ថយ បណ្តាលពីគំរោងការដែលមានគោលដៅកាត់បន្ថយអេមីស្យុងដោយសកម្មភាពមនុស្សពីប្រភពនានា ឬបង្កើនអាងស្រូបកាបូននៃឧស្ម័នផ្ទះកញ្ចក់ នៅក្នុងវិស័យណាមួយនៃសេដ្ឋកិច្ច ដូចមានចែងក្នុងមាត្រា ៦ នៃពិធីសារនេះ ។

(ឃ) ក្នុងលក្ខខណ្ឌសមស្រប ពិចារណាធ្វើសកម្មភាពតាមវិធីសាស្រ្តសមស្រប ដើម្បីដោះស្រាយស្ថានភាពរបស់បណ្តាភាគីក្នុងឧបសម្ព័ន្ធ ខ នៃពិធីសារនេះដែលក្នុងនោះគំរោងមួយអាចផ្តល់ផលប៉ះពាល់ជាបន្ទុរដល់បរិមាណអេមីស្យុងនៅក្នុងចន្លោះពេលនៃការសន្យា ។

(ង) វិភាគពីផលវិបាកនៃមាត្រា ១២ វាក្យខ័ណ្ឌ ១០ នៃពិធីសារនេះ ។

៦. <u>អញ្ជើញ</u>ប្រធានអង្គភាពជំនួយការផ្តល់យោបល់វិទ្យាសាស្រ្ត និងបច្ចេកវិទ្យា និងប្រធានអង្គភាពជំនួយការអនុវត្ត ដើម្បីធ្វើសំណើរួមគ្នាទៅអង្គភាពទាំងនោះ នៅក្នុងសម័យប្រជុំលើកទី ៨ អំពីការកំនត់ការងារសំរាប់អង្គភាពទាំងនេះ សំរាប់ធ្វើការងារចាំបាច់ដើម្បីជួយបង្កលទ្ធភាពដល់សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ នៅក្នុងសម័យប្រជុំទី ១ របស់ខ្លួន ក្រោយពេលដែលពិធីសារនេះចូលជាធរមាន និងដើម្បីបំពេញមុខការដែលពិធីសារនេះបានកំនត់សំរាប់ការប្រជុំនេះ ។

## សេចក្តីសំរេច 2/CP.3
## បញ្ហាវិធីសាស្រ្តពាក់ព័ន្ធនឹងពិធីសារក្យូតូ

### សន្និសីទបណ្តាភាគី

<u>បានឃើញ</u>សេចក្តីសំរេច 4/CP.1 និង 9/CP.2

<u>ដោយគាំទ្រ</u>ការសំរេចនៃអង្គភាពជំនួយការផ្តល់យោបល់វិទ្យាសាស្រ្ត និងបច្ចេកវិទ្យា នៅក្នុងសម័យប្រជុំលើកទី ៤ [9] ។

១. <u>អះអាងឡើងវិញ</u>ថាបណ្តាភាគីគួរប្រើគោលការណ៍ណែនាំសំរាប់ធ្វើសារពើភ័ណ្ឌជាតិនៃឧស្ម័នផ្ទះកញ្ចក់ របស់ក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកកិច្ចការប្រែប្រួលអាកាសធាតុ ដែលបានកែសំរួលនៅឆ្នាំ ១៩៩៦ សំរាប់ធ្វើការប៉ាន់ប្រមាណ និងធ្វើសេចក្តីរាយការណ៍អំពីអេមីស្យុងដោយសកម្មភាពមនុស្សពីប្រភពនានា និងការចាប់យកតាមរយៈអាងស្រូបឧស្ម័នផ្ទះកញ្ចក់ ដែលពុំមានចែងក្នុងពិធីសារក្រុងម៉ុងរ៉េអាល់ ។

២. <u>អះអាង</u>ថាអេមីស្យុងពិតប្រាកដនៃឧស្ម័នអ៊ីដ្រូភ្លុយអរ៉ូកាបូន ឧស្ម័នពែរភ្លុយអរ៉ូកាបូន និងឧស្ម័នស៊ុលភួរិចសាភ្លុយអរីដ គួរតែមានការប៉ាន់ប្រមាណក្នុងករណីដែលមានទិន្នន័យ និងប្រើប្រាស់សំរាប់ធ្វើសេចក្តីរាយការណ៍អំពីអេមីស្យុង ។ បណ្តាភាគីគួរតែប្រឹងប្រែងដើម្បីបង្កើតប្រភពទិន្នន័យ ។

៣. <u>អះអាងឡើងវិញ</u>ថាសក្តានុពលនៃកំនើនកំដៅពិភពលោក ប្រើប្រាស់ដោយបណ្តាភាគីគួរតែជាបរិមាណដែលផ្តល់ដោយក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកកិច្ចការប្រែប្រួលអាកាសធាតុ នៅក្នុងរបាយការណ៍វាយតំលៃលើកទី២របស់ខ្លួន ("1995 IPCC GWP value") ដោយផ្អែកលើផលនៃឧស្ម័នផ្ទះកញ្ចក់សំរាប់កំឡុងពេល ១០០ ឆ្នាំ ដោយរាប់បញ្ចូលទាំងភាពមិនប្រាកដប្រជាពាក់ព័ន្ធជាច្រើនទាក់ទងនឹងការប៉ាន់ប្រមាណសក្តានុពលកំនើនកំដៅពិភពលោក ។ លើសពីនេះ ក្នុងគោលបំណងនៃការផ្តល់ពតិមាន បណ្តាភាគីអាចប្រើប្រាស់ចន្លោះពេលមួយផ្សេង ដូចដែលមានបញ្ជាក់នៅក្នុងរបាយការណ៍វាយតំលៃលើកទី ២ ។

៤. <u>បានឃើញ</u>ថានៅក្នុងអត្ថបទកែសំរួលឆ្នាំ ១៩៩៦ នៃគោលការណ៍ណែនាំ សំរាប់ការធ្វើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ របស់ក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកកិច្ចការប្រែប្រួលអាកាសធាតុ បរិមាណអេមីស្យុងកើតពីឥន្ធនៈលក់ទៅឱ្យនាវា ឬយន្តហោះសំរាប់ប្រើប្រាស់ក្នុងការដឹកជញ្ជូនអន្តរជាតិមិនគួររាប់បញ្ចូលក្នុងបរិមាណសរុបសំរាប់ប្រទេសមួយទេ ប៉ុន្តែត្រូវរាយការណ៍ដោយឡែក និងអំពាវនាវឱ្យក្រុមជំនួយការផ្តល់យោបល់វិទ្យាសាស្រ្ត និងបច្ចេកវិទ្យាដើម្បីធ្វើសេចក្តីលំអិតបន្ថែមស្តីពីការរាប់បញ្ចូលអេមីស្យុងទាំងនោះទៅក្នុងសារពើភ័ណ្ឌសរុបសំរាប់បណ្តាភាគី ។

៥. <u>សំរេច</u>ថាអេមីស្យុងពីដំណើរប្រតិបត្តិការពហុភាគីអនុលោមតាមធម្មនុញ្ញសហប្រជាជាតិ នឹងមិនត្រូវរាប់បញ្ចូលទៅក្នុងបរិមាណសរុបសំរាប់ប្រទេសមួយទេ ប៉ុន្តែត្រូវរាយការណ៍ដោយឡែក រីឯអេមីស្យុងផ្សេងទៀតពាក់ព័ន្ធនឹងប្រតិបត្តិការនឹងត្រូវបញ្ចូលទៅក្នុងបរិមាណអេមីស្យុងសរុបសំរាប់ប្រទេសនៃភាគីមួយ ឬបណ្តាភាគីដែលពាក់ព័ន្ធ ។

[9] FCCC/SBTA/1996/20, paras, 30 and 54

*បកប្រែក្រៅផ្លូវការ*

## សេចក្តីសំរេច 3/CP.3
## ការអនុវត្តន៍មាត្រា ៤ វាក្យខ័ណ្ឌ ៨ និង ៩ នៃអនុសញ្ញា

*សន្និសីទបណ្តាភាគី*

កត់សំគាល់បណ្តាខក្នុងមាត្រា ៤ វាក្យខ័ណ្ឌ ៨ និង ៩ នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ។

កត់សំគាល់ផងដែរនូវខក្នុងមាត្រា ១៣ នៃអនុសញ្ញានេះ និងខក្នុងវាក្យខ័ណ្ឌ ១ (ខ) នៃ "អណត្តិក្រុងប៊ែរឡាំង"[*] ។

១. ស្នើថា នៅក្នុងសម័យប្រជុំទី ៨ របស់ខ្លួន អង្គភាពជំនួយការអនុវត្ត ត្រូវរៀបចំធ្វើអត្តសញ្ញាណ និងកំនត់បញ្ហាសកម្មភាពចាំបាច់សំរាប់បំពេញតាមតំរូវការនៃបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ ដែលចែងក្នុងមាត្រា ៤ វាក្យខ័ណ្ឌ ៨ និង ៩ នៃអនុសញ្ញា ដែលកើតឡើងពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និង/ឬផលប៉ះពាល់បណ្តាលពីវិធានការឆ្លើយតប ។ បញ្ហាគួរពិចារណារួម មានវិធានការពាក់ព័ន្ធនឹងការផ្តល់មូលនិធិ ការធានារ៉ាប់រង និងការផ្ទេរបច្ចេកវិទ្យា ។

២. ស្នើផងដែរឱ្យអង្គភាពជំនួយការអនុវត្តធ្វើសេចក្តីរាយការណ៍ទៅសន្និសីទបណ្តាភាគីអំពីលទ្ធផលនៃដំណើរការនេះ នៅក្នុងសម័យប្រជុំលើកទី ៤ របស់ខ្លួន ។

៣. ស្នើឱ្យសន្និសីទបណ្តាភាគីធ្វើសេចក្តីសំរេចស្តីពីវិធានការដោយយោងតាមសេចក្តីសន្និដ្ឋាន និងអនុសាសន៍នៃដំណើរការនេះ នៅក្នុងសម័យប្រជុំលើកទី ៤ របស់ខ្លួន ។

---

[*] សេចក្តីសំរេច 1/CP.1.

### របាយការណ៍នៃសន្និសីទបណ្តាភាគីអំពីសម័យប្រជុំលើកទី ៣ របស់ខ្លួន
### តារាង : អេមីស្យុងឧស្ម័នកាបូនិចសរុបនៃបណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ នៅឆ្នាំ ១៩៩០ សំរាប់គោលបំណងនៃមាត្រា ២៥ នៃពិធីសារក្យូតូ[a]

| ភាគី | អេមីស្យុង (Gg) | ភាគរយ |
|---|---|---|
| អូទ្រីស | ៥៩.២០០ | ០.៤ |
| បែលស៊ិច | ១១៣.៤០៥ | ០.៨ |
| ប៊ុលហ្គារី | ៨២.៩៩០ | ០.៦ |
| កាណាដា | ៤៥៧.៤៤១ | ៣.៣ |
| សាធារណរដ្ឋឆែក | ១៦៩.៥១៤ | ១.២ |
| ដាណឺម៉ាក | ៥២.១០០ | ០.៤ |
| អូស្ត្រាលី | ២៨៨.៩៦៥ | ២.១ |
| អេស្តូនី | ៣៧.៧៩៧ | ០.៣ |
| ហ្វាំងឡង់ | ៥៣.៩០០ | ០.៤ |
| បារាំង | ៣៦៦.៥៣៦ | ២.៧ |
| អាល្លឺម៉ង់ | ១.០១២.៤៤៣ | ៧.៤ |
| ក្រិច | ៨២.១០០ | ០.៦ |
| ហុងគ្រី | ៧១.៦៧៣ | ០.៥ |
| អាយស្លែន | ២.១៧២ | ០.០ |
| អៀរឡង់ | ៣០.៧១៩ | ០.២ |
| អ៊ីតាលី | ៤២៨.៩៤១ | ៣.១ |
| ជប៉ុន | ១.១៧៣.៣៦០ | ៨.៥ |
| ឡាតវី | ២២.៩៧៦ | ០.២ |
| លិចតិនស្តែន | ២០៨ | ០.០ |
| លុចសំបួរ | ១១.៣៤៣ | ០.១ |
| ម៉ូណាកូ | ៧១ | ០.០ |
| ហូឡង់ | ១៦៧.៦០០ | ១.២ |
| ណូវែលសេឡង់ | ២៥.៥៣០ | ០.២ |
| ន័រវេ | ៣៥.៥៣៣ | ០.៣ |
| ប៉ូឡូញ | ៤១៤.៩៣០ | ៣.០ |
| ព័រទុយហ្គាល់ | ៤២.១៤៨ | ០.៣ |
| រូម៉ានី | ១៧១.១០៣ | ១.២ |
| សហព័ន្ធរុស្ស៊ី | ២.៣៨៨.៧២០ | ១៧.៤ |
| ស្លូវ៉ាគី | ៥៨.២៧៨ | ០.៤ |
| អេស្ប៉ាញ | ២៦០.៦៥៤ | ១.៩ |
| ស៊ុយអែត | ៦១.២៥៦ | ០.៤ |
| ស្វីស | ៤៣.៦០០ | ០.៣ |
| ចក្រភពអង់គ្លេសនិងអៀរឡង់ខាងជើង | ៥៨៤.០៧៨ | ៤.៣ |
| សហរដ្ឋអាមេរិក | ៤.៩៥៧.០២២ | ៣៦.១ |
| សរុប | ១៣.៧២៨.៣០៦ | ១០០.០ |

[a]ទិន្នន័យនេះផ្អែកលើព័ត៌មានពីបណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ ដែលបានដាក់ជូនរបាយការណ៍ជាតិដំបូងនៅមុន ឬនៅថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ១៩៩៧ និងត្រូវបានចងក្រងដោយលេខាធិការដ្ឋាននៅក្នុងឯកសារមួយចំនួន A/AC.237/81;FCCC/CP/1996/12/Add.2 និង FCCC/SB/1997/6) ។

*បកប្រែក្រៅផ្លូវការ*

របាយការណ៍មួយចំនួនមានទិន្នន័យអំពីអេមីស្យុង $CO_2$ តាមប្រភព និងការចាប់យកដោយអាងស្រូបកាបូនដោយសារការប្រែប្រួលលើការប្រើប្រាស់ដី និងព្រៃឈើ ប៉ុន្តែដោយសាររបាយការណ៍ទាំងនោះរៀបចំតាមទំរង់ផ្សេងគ្នា ទិន្នន័យទាំងនោះមិនបានដាក់បញ្ចូលនៅទីនេះទេ ។

## សន្ទានុក្រម

| | |
|---|---|
| Ad hoc Group on the Berlin Mandate (AGBM) | ក្រុមការងារបណ្តោះអាសន្ននៃអណត្តិទីក្រុងប៊ែរឡាំង |
| Adverse effect | ផលអវិជ្ជមាន |
| Arbitration | មជ្ឈត្តវិនិច្ឆ័យ |
| Berlin Mandate | អាណត្តិទីក្រុងប៊ែរឡាំង |
| Clean development mechanism | យន្តការអភិវឌ្ឍន៍ស្អាត |
| Climate change | ការប្រែប្រួលអាកាសធាតុ |
| Climate system | ប្រព័ន្ធអាកាសធាតុ |
| Common but differentiated responsibilities | ការទទួលខុសត្រូវរួមគ្នា តែមានកំរិតផ្សេងៗគ្នា |
| Conference of the Parties (CoP) | សន្និសីទបណ្តាភាគី |
| Eligibility | ភាពអាចជ្រើសរើសយកបាន, ភាពមានសិទ្ធិទទួល |
| Emission | អេមីស្យុង, ការបញ្ចេញឧស្ម័ន |
| Emission reduction unit | ឯកតាកាត់បន្ថយអេមីស្យុង |
| Greenhouse effect | ផលផ្ទះកញ្ចក់ |
| Greenhouse gas (GHG) | ឧស្ម័នផ្ទះកញ្ចក់ |
| Intergovernmental Negotiating Committee for a Framework Convention on Climate Change (INC/FCCC) | គណៈកម្មការអន្តររដ្ឋាភិបាលដើម្បីចរចាបង្កើតអនុសញ្ញាក្របខ័ណ្ឌស្តីពីការប្រែប្រួលអាកាសធាតុ |
| Intergovernmental Panel on Climate Change (IPCC) | ក្រុមការងារអន្តររដ្ឋាភិបាល ស្តីពីការប្រែប្រួលអាកាសធាតុ |
| Join implementation | ការអនុវត្តន៍រួមគ្នា |
| Join fulfillment of commitments | កិច្ចអនុវត្តន៍ការសន្យារួមគ្នា |
| Least developed countries | ប្រទេសក្រីក្របំផុត |
| Legally binding commitment | ការសន្យាជាលក្ខណៈច្បាប់ |
| Modalities | ទំរង់ការ ? លក្ខខណ្ឌ ? |
| National communication | របាយការណ៍ជាតិ |
| Precautionary principle | វិធានការបង្ការជាមុន |
| Precursor | សារធាតុនាំមុខ |
| Prediction | ការព្យាករណ៍ |
| Projection | ចំនោល ការព្យាករណ៍ |
| Quantified emission limitation and reduction commitments | ការសន្យាកំហិត និងកាត់បន្ថយបរិមាណអេមីស្យុង |
| Regional economic integration organization | អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ |
| Reservoir | អាងផ្ទុកកាបូន |
| Sink | អាងស្រូបកាបូន |
| Source | ប្រភព |
| Systematic observation | ការសង្កេតយថាក្រម ការសង្កេតជាប្រចាំ |
| Uncertainty | ភាពមិនប្រាកដប្រជា |
| United Nations Development Programme (UNEP) | កម្មវិធីបរិស្ថានសហប្រជាជាតិ |
| World Meteorological Organisation | អង្គការឧតុនិយមពិភពលោក |

# KYOTO PROTOCOL TO THE UNITED NATIONS FRAMEWORK CONVENTION ON CLIMATE CHANGE

**The Parties to this Protocol,**

Being Parties to the United Nations Framework Convention on Climate Change, hereinafter referred to as "the Convention",

In pursuit of the ultimate objective of the Convention as stated in its Article 2,

Recalling the provisions of the Convention,

Being guided by Article 3 of the Convention,

Pursuant to the Berlin Mandate adopted by decision 1/CP.1 of the Conference of the Parties to the Convention at its first session,

**Have agreed as follows:**

## Article 1

For the purposes of this Protocol, the definitions contained in Article 1 of the Convention shall apply. In addition:

1. "Conference of the Parties" means the Conference of the Parties to the Convention.
2. "Convention" means the United Nations Framework Convention on Climate Change, adopted in New York on 9 May 1992.
3. "Intergovernmental Panel on Climate Change" means the Intergovernmental Panel on Climate Change established in 1988 jointly by the World Meteorological Organization and the United Nations Environment Programme.
4. "Montreal Protocol" means the Montreal Protocol on Substances that Deplete the Ozone Layer, adopted in Montreal on 16 September 1987 and as subsequently adjusted and amended.
5. "Parties present and voting" means Parties present and casting an affirmative or negative vote.
6. "Party" means, unless the context otherwise indicates, a Party to this Protocol.
7. "Party included in Annex I" means a Party included in Annex I to the Convention, as may be amended, or a Party which has made a notification under Article 4, paragraph 2(g), of the Convention.

## Article 2

1. Each Party included in Annex I, in achieving its quantified emission limitation and reduction commitments under Article 3, in order to promote sustainable development, shall:

   (a) Implement and/or further elaborate policies and measures in accordance with its national circumstances, such as:

   (i) Enhancement of energy efficiency in relevant sectors of the national economy;
   (ii) Protection and enhancement of sinks and reservoirs of greenhouse gases not controlled by the Montreal Protocol, taking into account its commitments under relevant international environmental agreements; promotion of sustainable forest management practices, afforestation and reforestation;
   (iii) Promotion of sustainable forms of agriculture in light of climate change considerations;
   (iv) Research on, and promotion, development and increased use of, new and renewable forms of energy, of carbon dioxide sequestration technologies and of advanced and innovative environmentally sound technologies;

(v) Progressive reduction or phasing out of market imperfections, fiscal incentives, tax and duty exemptions and subsidies in all greenhouse gas emitting sectors that run counter to the objective of the Convention and application of market instruments;
(vi) Encouragement of appropriate reforms in relevant sectors aimed at promoting policies and measures which limit or reduce emissions of greenhouse gases not controlled by the Montreal Protocol;
(vii) Measures to limit and/or reduce emissions of greenhouse gases not controlled by the Montreal Protocol in the transport sector;
(viii) Limitation and/or reduction of methane emissions through recovery and use in waste management, as well as in the production, transport and distribution of energy;

b) Cooperate with other such Parties to enhance the individual and combined effectiveness of their policies and measures adopted under this Article, pursuant to Article 4, paragraph 2(e)(i), of the Convention. To this end, these Parties shall take steps to share their experience and exchange information on such policies and measures, including developing ways of improving their comparability, transparency and effectiveness. The Conference of the Parties serving as the meeting of the Parties to this Protocol shall, at its first session or as soon as practicable thereafter, consider ways to facilitate such cooperation, taking into account all relevant information.

2. The Parties included in Annex I shall pursue limitation or reduction of emissions of greenhouse gases not controlled by the Montreal Protocol from aviation and marine bunker fuels, working through the International Civil Aviation Organization and the International Maritime Organization, respectively.

3. The Parties included in Annex I shall strive to implement policies and measures under this Article in such a way as to minimize adverse effects, including the adverse effects of climate change, effects on international trade, and social, environmental and economic impacts on other Parties, especially developing country Parties and in particular those identified in Article 4, paragraphs 8 and 9, of the Convention, taking into account Article 3 of the Convention. The Conference of the Parties serving as the meeting of the Parties to this Protocol may take further action, as appropriate, to promote the implementation of the provisions of this paragraph.

4. The Conference of the Parties serving as the meeting of the Parties to this Protocol, if it decides that it would be beneficial to coordinate any of the policies and measures in paragraph 1(a) above, taking into account different national circumstances and potential effects, shall consider ways and means to elaborate the coordination of such policies and measures.

**Article 3**

1. The Parties included in Annex I shall, individually or jointly, ensure that their aggregate anthropogenic carbon dioxide equivalent emissions of the greenhouse gases listed in Annex A do not exceed their assigned amounts, calculated pursuant to their quantified emission limitation and reduction commitments inscribed in Annex B and in accordance with the provisions of this Article, with a view to reducing their overall emissions of such gases by at least 5 per cent below 1990 levels in the commitment period 2008 to 2012.

2. Each Party included in Annex I shall, by 2005, have made demonstrable progress in achieving its commitments under this Protocol.

3. The net changes in greenhouse gas emissions by sources and removals by sinks resulting from direct human-induced land-use change and forestry activities, limited to afforestation, reforestation and deforestation since 1990, measured as verifiable changes in carbon stocks in each commitment period, shall be used to meet the commitments under this Article of each Party included in Annex I. The greenhouse gas emissions by sources and removals by sinks associated with those activities shall be reported in a transparent and verifiable manner and reviewed in accordance with Articles 7 and 8.

4. Prior to the first session of the Conference of the Parties serving as the meeting of the Parties to this Protocol, each Party included in Annex I shall provide, for consideration by the Subsidiary Body for Scientific and Technological Advice, data to establish its level of carbon stocks in 1990 and to enable an estimate to be made of its changes in carbon stocks in subsequent years. The Conference of the Parties serving as the meeting of the Parties to this Protocol shall, at its first session or as soon as practicable thereafter, decide upon modalities, rules and guidelines as to how, and which, additional human-induced activities related to changes in greenhouse gas emissions by sources and removals by sinks in the

agricultural soils and the land-use change and forestry categories shall be added to, or subtracted from, the assigned amounts for Parties included in Annex I, taking into account uncertainties, transparency in reporting, verifiability, the methodological work of the Intergovernmental Panel on Climate Change, the advice provided by the Subsidiary Body for Scientific and Technological Advice in accordance with Article 5 and the decisions of the Conference of the Parties. Such a decision shall apply in the second and subsequent commitment periods. A Party may choose to apply such a decision on these additional human-induced activities for its first commitment period, provided that these activities have taken place since 1990.

5. The Parties included in Annex I undergoing the process of transition to a market economy whose base year or period was established pursuant to decision 9/CP.2 of the Conference of the Parties at its second session shall use that base year or period for the implementation of their commitments under this Article. Any other Party included in Annex I undergoing the process of transition to a market economy which has not yet submitted its first national communication under Article 12 of the Convention may also notify the Conference of the Parties serving as the meeting of the Parties to this Protocol that it intends to use an historical base year or period other than 1990 for the implementation of its commitments under this Article. The Conference of the Parties serving as the meeting of the Parties to this Protocol shall decide on the acceptance of such notification.

6. Taking into account Article 4, paragraph 6, of the Convention, in the implementation of their commitments under this Protocol other than those under this Article, a certain degree of flexibility shall be allowed by the Conference of the Parties serving as the meeting of the Parties to this Protocol to the Parties included in Annex I undergoing the process of transition to a market economy.

7. In the first quantified emission limitation and reduction commitment period, from 2008 to 2012, the assigned amount for each Party included in Annex I shall be equal to the percentage inscribed for it in Annex B of its aggregate anthropogenic carbon dioxide equivalent emissions of the greenhouse gases listed in Annex A in 1990, or the base year or period determined in accordance with paragraph 5 above, multiplied by five. Those Parties included in Annex I for whom land-use change and forestry constituted a net source of greenhouse gas emissions in 1990 shall include in their 1990 emissions base year or period the aggregate anthropogenic carbon dioxide equivalent emissions by sources minus removals by sinks in 1990 from land-use change for the purposes of calculating their assigned amount.

8. Any Party included in Annex I may use 1995 as its base year for hydrofluorocarbons, perfluorocarbons and sulphur hexafluoride, for the purposes of the calculation referred to in paragraph 7 above.

9. Commitments for subsequent periods for Parties included in Annex I shall be established in amendments to Annex B to this Protocol, which shall be adopted in accordance with the provisions of Article 21, paragraph 7. The Conference of the Parties serving as the meeting of the Parties to this Protocol shall initiate the consideration of such commitments at least seven years before the end of the first commitment period referred to in paragraph 1 above.

10. Any emission reduction units, or any part of an assigned amount, which a Party acquires from another Party in accordance with the provisions of Article 6 or of Article 17 shall be added to the assigned amount for the acquiring Party.

11. Any emission reduction units, or any part of an assigned amount, which a Party transfers to another Party in accordance with the provisions of Article 6 or of Article 17 shall be subtracted from the assigned amount for the transferring Party.

12. Any certified emission reductions which a Party acquires from another Party in accordance with the provisions of Article 12 shall be added to the assigned amount for the acquiring Party.

13. If the emissions of a Party included in Annex I in a commitment period are less than its assigned amount under this Article, this difference shall, on request of that Party, be added to the assigned amount for that Party for subsequent commitment periods.

14. Each Party included in Annex I shall strive to implement the commitments mentioned in paragraph 1 above in such a way as to minimize adverse social, environmental and economic impacts on developing country Parties, particularly those identified in Article 4, paragraphs 8 and 9, of the Convention. In line with relevant decisions of the Conference of the Parties on the implementation of those paragraphs, the Conference of the Parties serving as the meeting of the Parties to this Protocol shall, at its first session, consider what actions are necessary to minimize the adverse effects of climate change and/or the

impacts of response measures on Parties referred to in those paragraphs. Among the issues to be considered shall be the establishment of funding, insurance and transfer of technology.

**Article 4**

1. Any Parties included in Annex I that have reached an agreement to fulfil their commitments under Article 3 jointly, shall be deemed to have met those commitments provided that their total combined aggregate anthropogenic carbon dioxide equivalent emissions of the greenhouse gases listed in Annex A do not exceed their assigned amounts calculated pursuant to their quantified emission limitation and reduction commitments inscribed in Annex B and in accordance with the provisions of Article 3. The respective emission level allocated to each of the Parties to the agreement shall be set out in that agreement.

2. The Parties to any such agreement shall notify the secretariat of the terms of the agreement on the date of deposit of their instruments of ratification, acceptance or approval of this Protocol, or accession thereto. The secretariat shall in turn inform the Parties and signatories to the Convention of the terms of the agreement.

3. Any such agreement shall remain in operation for the duration of the commitment period specified in Article 3, paragraph 7.

4. If Parties acting jointly do so in the framework of, and together with, a regional economic integration organization, any alteration in the composition of the organization after adoption of this Protocol shall not affect existing commitments under this Protocol. Any alteration in the composition of the organization shall only apply for the purposes of those commitments under Article 3 that are adopted subsequent to that alteration.

5. In the event of failure by the Parties to such an agreement to achieve their total combined level of emission reductions, each Party to that agreement shall be responsible for its own level of emissions set out in the agreement.

6. If Parties acting jointly do so in the framework of, and together with, a regional economic integration organization which is itself a Party to this Protocol, each member State of that regional economic integration organization individually, and together with the regional economic integration organization acting in accordance with Article 24, shall, in the event of failure to achieve the total combined level of emission reductions, be responsible for its level of emissions as notified in accordance with this Article.

**Article 5**

1. Each Party included in Annex I shall have in place, no later than one year prior to the start of the first commitment period, a national system for the estimation of anthropogenic emissions by sources and removals by sinks of all greenhouse gases not controlled by the Montreal Protocol. Guidelines for such national systems, which shall incorporate the methodologies specified in paragraph 2 below, shall be decided upon by the Conference of the Parties serving as the meeting of the Parties to this Protocol at its first session.

2. Methodologies for estimating anthropogenic emissions by sources and removals by sinks of all greenhouse gases not controlled by the Montreal Protocol shall be those accepted by the Intergovernmental Panel on Climate Change and agreed upon by the Conference of the Parties at its third session. Where such methodologies are not used, appropriate adjustments shall be applied according to methodologies agreed upon by the Conference of the Parties serving as the meeting of the Parties to this Protocol at its first session. Based on the work of, inter alia, the Intergovernmental Panel on Climate Change and advice provided by the Subsidiary Body for Scientific and Technological Advice, the Conference of the Parties serving as the meeting of the Parties to this Protocol shall regularly review and, as appropriate, revise such methodologies and adjustments, taking fully into account any relevant decisions by the Conference of the Parties. Any revision to methodologies or adjustments shall be used only for the purposes of ascertaining compliance with commitments under Article 3 in respect of any commitment period adopted subsequent to that revision.

3. The global warming potentials used to calculate the carbon dioxide equivalence of anthropogenic emissions by sources and removals by sinks of greenhouse gases listed in Annex A shall be those accepted by the Intergovernmental Panel on Climate Change and agreed upon by the Conference of the Parties at its third session. Based on the work of, inter alia, the Intergovernmental Panel on Climate Change and advice provided by the Subsidiary Body for Scientific and Technological Advice, the

Conference of the Parties serving as the meeting of the Parties to this Protocol shall regularly review and, as appropriate, revise the global warming potential of each such greenhouse gas, taking fully into account any relevant decisions by the Conference of the Parties. Any revision to a global warming potential shall apply only to commitments under Article 3 in respect of any commitment period adopted subsequent to that revision.

### Article 6

1. For the purpose of meeting its commitments under Article 3, any Party included in Annex I may transfer to, or acquire from, any other such Party emission reduction units resulting from projects aimed at reducing anthropogenic emissions by sources or enhancing anthropogenic removals by sinks of greenhouse gases in any sector of the economy, provided that:

   (a) Any such project has the approval of the Parties involved;

   (b) Any such project provides a reduction in emissions by sources, or an enhancement of removals by sinks, that is additional to any that would otherwise occur;

   (c) It does not acquire any emission reduction units if it is not in compliance with its obligations under Articles 5 and 7; and

   (d) The acquisition of emission reduction units shall be supplemental to domestic actions for the purposes of meeting commitments under Article 3.

2. The Conference of the Parties serving as the meeting of the Parties to this Protocol may, at its first session or as soon as practicable thereafter, further elaborate guidelines for the implementation of this Article, including for verification and reporting.

3. A Party included in Annex I may authorize legal entities to participate, under its responsibility, in actions leading to the generation, transfer or acquisition under this Article of emission reduction units.

